D159501 (DC-Cam)

1729

ឆ្នាំទី ... លេខ ... ១៥ រៀល

សប្តាហ៍ ទី ១០ – ១៦ មីនា ១៩៦៩

ជាតិ សាសនា រាជបល្ល័ង្ក

# អ្នកជាតិនិយម

LE NATIONALISTE

## ពិធីសម្ពោធព្រះវិហារនិង បញ្ចុះសីមា វត្តជម្ពូព្រឹក្ស ស្រុកព្រែកតាមាក់ខេត្តកណ្តាល



MAG
0393

# LE MAGASIN D'ETAT

## *VOUS OFFRE:*

**AU MAGASIN PREAH MONIVONG :**

219 *A — Boulevard Preah Monivong — Tél.* 2.2618

— ses légumes et fruits sélectionnés
— sa boucherie
— ses charcuteries fines
— son épicerie
— son choix de pâtisseries cambodgiennes
— son salon de thé
— **ET SA BOULANGERIE**

**AU MA…TAT-DANCING :**
**(Poch…ng) Tél. 3.2801**

— sa salle climatisée
— son hall entièrement réaménagé
— son orchestre jeune et dynamique
— de nombreuses et jeunes hôtesses

**AU SHOPPING CENTER**
**DE L'AEROGARE DE POCHENTONG :**

*Tous les produits de l'artisanat khmer:*

— bijouterie
— agenterie
— soierie
— vannerie
— estampage
— sculpture sur bois
— articles de bronze etc...
— à sa boutique conditionnée dans la salle de départ
— et au hall d'exposition de la salle de transit de l'aérogare.

**A L'INDEPENDANCE HOTEL :**
**(Sihanoukville)**

— vue magnifique sur la mer
— ses luxueuses chambres climatisées
— et aussi 13 chambres économiques confortables

**AU MAGASIN PREAH KOSSOMAK :**

17 *Vithei Preah Kossomak — Tél.* 3. 3800 — 3. 3803
3. 3810

**Rez de chaussée**

— ses parfums et produits de beauté
— son rayon de bonneterie et de lingerie
— des appareils électro-ménagers
— des récepteurs de radio et de télévision
— de nouveaux disques des meilleurs chanteurs khmers et étrangers
— des articles de bazar
— son agence de voyage

**1er étage :**

— son rayon de tissus
— ses articles d'argenterie et d'artisanat khmer
— **SON SALON DE THE PANORAMIQUE**

**2ème étage :**

— **SA RICHE LIBRAIRIE**
— ses articles de sport
— son rayon de jouets

**AU RESTAURANT DE LA PLAGE :**
**(Sihanoukville)**

— ses fruits de mer
— ses menus économiques
— un service soigné

**Et partout**

— *Des qualités garanties*
— *Des prix raisonn…*
— *Un meilleur a…*
— *Un…ian…*

QPK 1729

ជាតិ សាសនា ព្រះមហាក្សត្រ

# អ្នកជាតិនិយម

LE NATIONALISTE

ក្រុមនិពន្ធ នឹង អភិបាលដ្ឋាន ស្ថិតនៅលេខ ៨៦
វិថីតេជោដំឌិន ភ្នំពេញ
ទូរស័ព្ទលេខ ២-៣២៣៨

ចាងហ្វាងនិងនិពន្ធនាយក : ភី-ធៀនឡាយ

ក្រុមអ្នកនិពន្ធ :

ការិយាល័យនិពន្ធ : អ៊ូរ-ដាន់, តែ-ជុន, អាន-ម៉េងហ៊ុន, ប៊ុត-រុណ, ម៉ែន-ទន់, ហួរ-ភួង,

អ្នកនិពន្ធ : ហ៊ែល-ស៊ុំផា, ហ្សង់-ម៉ីយែរ, អ្នកអង្គម្ចាស់ ស៊ីសុវត្ថិ-សុវណ្ណវេត, ឈិន-ជុន, អ៊ឹង-ប៊ុនហោ, គុយ-ពៅ, សហជីវិនី ពេជ-សល់, ដា ប៉ូ, សាយ-វេត, សឿ-គាន, ប៉ែន-ភី, កៅ-លន់, ហេង-ទូច

អ្នកគូររូបតុក្កតាថ្ងៃ : ហ៊ុយ-ហែម, ញ៉ឹក-នឹម, យុត-យុន, គ្រឿង-យ៉ិន,

## អភិបាលដ្ឋាន

អ្នកអភិបាល : លី-គីមហេង

ហេរញ្ញិក : កុប-សន

ការិយាល័យអភិបាលនិងពាណិជ្ជកម្ម : ឡឹក-ធុន

ការិយាល័យផាវប្រចាំខែ-ឆ្នាំ : ខម-សារី

ការិយាល័យចែកទៅបណ្ណាគារ : ស៊ុំ-ម៉េត

ការិយាល័យចែកផ្សាយ : ប្រាក់-ម៉ៃ

រៀបតុបតែងទំព័រ : យុត-យុន, វ៉ូ-សំអុល, ព្រុំ-ម៉ិះ

បោះពុម្ពនៅ

រោងពុម្ពសង្គមរាស្ត្រនិយម

### តម្លៃជាវ

១ ខែ ... ៦០៖០០ : ៦ ខែ ...៣៥០៖០០

៣ ខែ ... ១៧៧៖០០ : ១ ឆ្នាំ ... ៧០០៖០០

– ក្នុងការជាវទស្សនាវដ្ដី «អ្នកជាតិនិយម» នេះ សូមស្ដេចយាង និងអញ្ជើញទៅទាក់ទងនៅភ្នំពេញ នៅផ្ទះលេខ ៨៦ វិថីតេជោដំឌិន និងនៅទីរួមខេត្ត នៅសាលាខេត្តនានា ។

ការបង់តម្លៃជាវអាចបង់ជាអាណត្តិប្រៃសណីយ៍-អាណត្តិធនាគារ មូលប្បទានប័ត្រ ឬបញ្ចូលប្រាក់នេះ ទៅក្នុងធនាគារនិងធនាគារ ... មានគណនីអ្នកជាតិនិយមលេខ :

ធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម លេខ D 347

...នាគារឥណទានជាតិ លេខ 40-2087

...ជាតិ លេខ ...

... សាលា...

# បញ្ជីអត្ថបទ

## បច្ចុប្បន្នភាព

ទំព័រ

– ជោគជ័យខាងផ្លូវចិត្តរបស់ខ្មែរ . . . . . . . . . . ៤
– ព្រះសន្និសីទសារពត៌មានកាលពីថ្ងៃទី ៦-៣-៦៩. . . . . . . ៥
– ពិធីបញ្ចុះខណ្ឌសីមាវត្តជម្ពូព្រឹក្ស ខេត្តកណ្ដាល . . . . . . ៦
– ពិធីសម្ភោធពីឡាហ៊ាននៃភូមិន្ទសាកលវិទ្យាល័យកំពង់ចាម . . . . ៨
– សម្ដេចឪទ្រង់យាងទៅថ្វាយបង្គំព្រះតេជព្រះគុណ មេគណខេត្តកោះកុង. ១១
– ពិធីជប់លៀងជូនជាកិត្តិយសចំពោះឯ.ឧ. នីកូឡាយ-ប៉ាតូលីចេវ . . ១២
– បច្ចុប្បន្នភាពផ្សេងៗ . . . . . . . . . . . ១៤
– បញ្ហាក្នុងប្រទេស និងក្រៅប្រទេស . . . . . . . . ១៦

## សភានិងច្បាប់

– មានអ្វីថ្មែកនៅរដ្ឋសភា ដោយសហជីវិន គុយ-ពៅ . . . . . . ២៤
– សំបុត្រកំណើតនៃកូនចិញ្ចឹម ដោយសហជីវិន ភី-ធៀនឡាយ . . . ២៦

## វប្បធម៌ សុជីវធម៌ និងវិទ្យាសាស្ត្រ

– ថ្នាំទឹកភ្នែកទៀត ដោយសហជីវិន ហ៊ែល-ស៊ុំផា . . . . . . . ២៨
– សេចក្ដីក្លាហាន (តនិងចប់) ដោយសហជីវិន ដា-ប៉ូរ . . . . . ៣០
– សុជីវធម៌ក្នុងក្របខណ្ឌរាជការ ដោយលោកស្រី ភី-ធៀនឡាយ . . ៣២
– ឧត្តុនិយមវិទ្យា ដោយសហជីវិន ហេង-ទូច . . . . . . . ៣៤
– នេះជាមេរៀនមួយ (ត) ដោយសហជីវិន ម៉ែន-ទន់ . . . . . . ៣៦

## ការងារ និង សង្គមកិច្ច

– ពិធីបំពាក់មេដាយជូនលោករ៉េណេ-ឌេរល៊ិន-ហ្សាំងហ្សូ . . . . . ៣៩
– ទស្សនាបរនៃឯកឧត្ដម ឧត្ដមសេនីយឯក ញ៉ឹក-ជូឡុង . . . . . ៤០
– កិច្ចការនានាជាប្រយោជន៍ជាតិ . . . . . . . . . . ៤២
– សកម្មភាពនៃក្រុមអន្តរាគមន៍កសិកម្មសម្ដេចឪ . . . . . . ៤៤
– ការលើកទំនប់ទឹកអូរអំពាន ខេត្តព្រៃវែង . . . . . . . ៤៨
– សមិទ្ធិថ្មីនៃសង្គមនៅខេត្តកណ្ដាល . . . . . . . . ៥០

## ផ្សេងៗ

– លិខិតថ្លែងអំណរចំពោះព្រះមហាករុណាទិគុណនៃសម្ដេចឪ . . . ៥២
– សមាជិកថ្មីនៃមហាចលនាជាតិសង្គមរាស្ត្រនិយម . . . . . . ៥៤
– ការសម្ងាត់ . . . . . . . . . . . . . . . ៥៧

**អ្នកជាតិនិយម មានគោលបំណងចង់ឱ្យមាន ប្រយោជន៍ដល់មិត្តអ្នកអាន ឱ្យមិត្តអ្នកអាន បានជ្រាបពត៌មាន និងចូលចិត្តផង ។**

**Le but de Neak cheat Niyum est d'informe[r] ses lecteurs, de les intéresser et de leur plaire.**

# ជោគជ័យ ខាងផ្លូវចិត្តរបស់ខ្មែរ

ព្រះហឫទ័យថ្មីដ៏សប្បុរសនៃសម្ដេចព្រះប្រមុខរដ្ឋចំពោះអ្នកទោសអាមេរិកាំង ៤ នាក់ ដែលបានរួចខ្លួនតាំងពីម្សិលម៉្ងៃនោះ បានធ្វើឱ្យប្រទេសយើងមានជ័យជំនះមួយថ្មីទៀតខាងផ្លូវចិត្ត ។ ជោគជ័យនេះឋិតនៅក្នុងក្របខ័ណ្ឌនៃទស្សនៈពុទ្ធសាសនា ដែលយើងបានប្រកាន់ដ៏ខ្ជាប់ខ្ជួន ។ ដូចសម្ដេចបានទ្រង់រំលឹកក្នុងសន្និសីទសារពត៌មានរបស់ព្រះអង្គ កាលពីថ្ងៃទី ៦ មីនាស្រាប់ ការណ៍ដែលសំខាន់ជាងគេចំពោះយើង គឺជោគជ័យខាងផ្លូវចិត្តលើសហរដ្ឋអាមេរិក ទោះបីយើងមិនសង្ឃឹមថា មហាប្រទេសនេះនឹងកែប្រែអាកប្បកិរិយាចំពោះយើងក្ដី ។ យ៉ាងហោចណាស់ក៏ប្រជារាស្ត្រអាមេរិកាំងអាចវិនិច្ឆ័យបានដ៏ត្រឹមត្រូវ ចំពោះអាកប្បកិរិយាដ៏ទន់ភ្លន់របស់ខ្មែរ និងអាកប្បកិរិយារបស់រដ្ឋាភិបាលខ្លួនដែរ ។ យើងឆ្លើយតបទៅនឹងអំពើឈ្លានពានដោយការអត់ឱនសន្ដោស និងដោយសេចក្ដីសប្បុរស ។ មួយទៀត យើងបានរក្សាអ្នកទោសនេះដោយគំនិតមនុស្សធម៌ហាក់ដូចជាភ្ញៀវរបស់យើង ហើយអ្នកទោសនេះបានរួចខ្លួនទៅជួបមុខគ្រួសារមុនពេលដែលខ្លួនសង្ឃឹមនោះទៅទៀត ។ ដូច្នេះ ពេលនេះគួរតែមតិមហាជនអាមេរិកាំងគិតពិចារណាចំពោះសប្បុរសធម៌ដ៏ប្រពៃរបស់ខ្មែរ ហើយធ្វើការសន្និដ្ឋានខ្លួនឯងផងចុះ ។

បានជាយើងសុំឱ្យធ្វើសន្និដ្ឋានយ៉ាងនេះ ព្រោះអំពើឈ្លានពាន មិនទាន់ចប់ទេនៅព្រំដែនខ្មែរ ។ ពិតហើយថា យើងពុំដែលទម្លាក់ទោសទៅលើទាហានអាមេរិកាំង ដែលយើងចាប់បាននោះទេហើយស្របតាមគំនិតព្រះពុទ្ធសាសនា, យើងពុំដែលមានបំណងចង់ឱ្យទាហានអាមេរិកាំងនេះទទួលទោសដោយត្រូវជាប់គុកឱ្យបានយូរពេលវេលានោះឡើយ ។ ក្នុងការដោះលែងនេះទៀត យើងគ្មានសុំអ្វីច្រើនទេ គឺគ្រាន់តែសុំឱ្យប្រធានាធិបតី និចសុន សរសេរលិខិតផ្ទាល់ខ្លួនលោក មកថ្វាយសម្ដេចព្រះប្រមុខរដ្ឋខ្មែរតែប៉ុណ្ណោះ ។ ពេលនេះ គួរតែរាស្ត្រអាមេរិកាំងស្គាល់តម្លៃនៃអាកប្បកិរិយា ដ៏ទន់ ភ្លន់របស់ខ្មែរហើយ ទោះបីសារពត៌មានអាមេរិកាំងសរសេរបង្កាច់ប្រទេសកម្ពុជានាំឱ្យខ្លួនយល់ខុសក្ដី ។ តោងរាស្ត្រអាមេរិកាំងដឹងថាកម្ពុជាពុំប្រកែកទេចំពោះការស្រុះស្រួលជាមួយនឹងសហរដ្ឋអាមេរិក ប៉ុន្តែ ឱ្យមហាអំណាចនេះមានចិត្តស្មោះផង ប្រសិនបើខ្លួនចង់ជាជាមួយខ្មែរកុំល្បួតែមាត់ ។ ការបញ្ឈប់ជាស្ថាពរនូវ អំពើឈ្លានពានមកលើទឹកដីខ្មែរ ហើយការទទួលស្គាល់ព្រំដែនបច្ចុប្បន្នរបស់ប្រទេសកម្ពុជា នឹងបង្ហាញឱ្យឃើញថាសហរដ្ឋអាមេរិក ពិតជាចង់កាន់គំនិតថ្មីចំពោះយើង។ទោះបីយ៉ាងណាក្ដី ជោគជ័យ ខាងផ្លូវចិត្តក៏នៅខាងខ្មែរស្រេចទៅហើយ ជោគជ័យដែលរឹតតែបញ្ជាក់ម្ដងថែមទៀត នូវគំនិតដ៏ខ្ពង់ខ្ពស់របស់កម្ពុជាចំពោះការទាក់ទងរវាងប្រជារាស្ត្រនានាដោយមិនប្រកាន់រើសអើងអ្វីឡើយ ។

០

(ស្រង់ពីទីភ្នាក់ងារ

# ព្រះសន្និសីទសារពត៌មាន
# នៃសម្តេចឪព្រះប្រមុខរដ្ឋនៅព្រះដំណាក់ចំការមន



កាលពីថ្ងៃទី ៦ មីនា ១៩៦៩ សម្តេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់សព្វព្រះរាជហឫទ័យធ្វើសន្និសីទសារពត៌មានមួយ នៅព្រះតំណាក់ចំការមន ។

ក្នុងឱកាសនោះ មានឥស្សរជននិងអ្នកសារពត៌មានខ្មែរ-បរទេស ជាច្រើនរូបបានអញ្ជើញទៅចូលរួមផង ។

សម្តេចឪជាអម្ចាស់ទ្រង់មានព្រះរាជបន្ទូលបញ្ជាក់អំពីបញ្ហាសំខាន់ៗ ជាច្រើន មានបញ្ហាៈទុកឯកឧត្តម លន់-នល់ ឲ្យនៅបន្តកិច្ចជានាយករដ្ឋមន្ត្រីស្តីទីតទៅទៀត, ត្រូវទុករដ្ឋសភាឲ្យនៅដដែល ជាកិច្ចបង្រួបបង្រួមជាតិ, ត្រូវតែពង្រីកនិងស្ថាបនាសណ្ឋាគារ ដើម្បីឲ្យបានរីកចម្រើនខាងវិស័យទេសចរ, ត្រូវបង្កើនខាងរបរកសិកម្ម ។

ក្រៅអំពីនេះ សម្តេចឪទ្រង់បញ្ជាក់ថែមទៀត អំពីការឈ្លានពានចូលមកទឹកដីខ្មែរនៃទាហានយៀកសៀម-យួន-លាវ ហើយព្រះអង្គទ្រង់ប្រកាសជាឧឡារិក ថាពិតជាមិនបណ្តោយឲ្យសត្រូវលេបស្រុកយើងបានដោយងាយជាដាច់ខាត ។. ត្រង់កាសែតអាមេរិកាំងវាលួចបរិហារថាព្រះអង្គម្ចាស់ ន.នរទីបោ្ត ឬ ន.រណរិទ្ធ ត្រូវបានជាព្រះតំណវង្សនោះ សម្តេចឪទ្រង់មានព្រះបន្ទូលថា រឿងនេះគឺជាកិច្ចការរបស់ក្រុមប្រឹក្សាព្រះរាជបល្ល័ង្កតាំងស្រុង ពុំមែនសម្រេចលើព្រះអង្គទេ ដែលត្រូវជ្រើសរើសស្តេចសោយរាជ្យ ឬប្រមុខរដ្ឋ ។



ក្នុងឱកាសដែលសម្ដេចឪទ្រង់ស្ដេចយាងដល់ទីនោះ ជួនចាស់ទាំងឡាយបានថ្វាយពរសា្វគមន៍ចំពោះព្រះអង្គថា សូមសម្ដេចឪទ្រង់មានព្រះជន្មាយុជាងមួយរយឆ្នាំ

# ពិធីបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តជម្ពូព្រឹក្ស ស្រុកខ្សាច់កណ្ដាល ខេត្តកណ្ដាល



សម្ដេចឪទ្រង់ថ្វាយបង្គំព្រះតេជព្រះគុណ មេគណដោយសេចក្ដីគោរពដ៏ជ្រាលជ្រៅជាទីបំផុត

កាលពីព្រឹកថ្ងៃសុក្រទី ៧ ខែមីនា១៩៦៩ សម្ដេចឪទ្រង់បានស្ដេចយាងទៅជាព្រះអធិបតីបញ្ចុះខណ្ឌសីមា ព្រះវិហារវត្តជម្ពូព្រឹក្ស សង្កាត់ស្វាយរមៀត ស្រុកខ្សាច់កណ្ដាលក្នុងខេត្តកណ្ដាល ។

នៅពេលនោះ បន្ទាប់ពីធ្វើពិធីផ្សេងៗជាបឋមរួចមក សហជីវិន ទឹម-ជុន ប្រតិភូរាជរដ្ឋាភិបាលនៃខេត្តកណ្ដាល និងអ្នកតំណាងគណៈកម្មការស្ថាបនាព្រះវិហារ បានថ្លែងសុន្ទរកថាជាបន្តបន្ទាប់គ្នា រៀបរាប់ពីសមិទ្ធិនានានៅក្នុងខេត្តកណ្ដាល ដែលបានរីកចំរើនជាអតិបរមា និងរៀបរាប់ពីប្រវត្តិនៃការស្ថាបនាព្រះវិហារវត្ត ជម្ពូព្រឹក្សនេះ ។ល។

តមក សម្ដេចឪទ្រង់បានថ្លែងព្រះសង្កថាមួយបញ្ជាក់ពីនយោបាយ សង្គមរាស្ត្រនិយម ដែលធ្វើឲ្យបានចំរើនខាងផ្នែកពុទ្ធចក្រ ក៏ដូចខាងផ្នែកអាណាចក្រដែរ ព្រមទាំងបាន [illegible] ចំរើននៃប្រទេសកម្ពុជាយើង ដែលបានធ្វើឲ្យប្រទេសនានាជាច្រើនក្នុងលោកថ្លែងកោតសរសើរ ហើយបានចាត់ទុកថា នយោបាយនៃប្រទេសកម្ពុជា បានជាគំរូដ៏ល្អដល់ប្រទេសនានាក្នុងលោក ។ល។

នៅទីបំផុត សម្ដេចឪទ្រង់ បាន ថ្លែង សរសើរ ដល់សហជីវិន ទឹម-ជុន និងទ្រង់បានថ្លែងអំណរគុណចំពោះព្រះសង្ឃមានជាអាទិ៍ គឺព្រះតេជៈព្រះគុណ គាន់-ឯល មេគណខេត្តកណ្ដាល ដែលបានរួបរួមជាមួយព្រះសង្ឃ និងក្រុមពុទ្ធបរិស័ទខំប្រឹងស្ថាបនាសមិទ្ធិនានា ខាងពុទ្ធចក្រ និងខាងអាណាចក្រឲ្យបានចំរើន ។ សម្ដេចឪទ្រង់បានបញ្ជាក់ទៀតថា លទ្ធិសង្គមនិយមព្រះពុទ្ធសាសនា គឺជាលទ្ធិដ៏ល្អបរិសុទ្ធ បើពលរដ្ឋខ្មែរបានគោរពយ៉ាងខ្ជាប់ខ្ជួននោះ ប្រទេសជាតិយើងនឹងបា [illegible] បានចំរើនជានិច្ច ។ល។

[illegible] ះចប់ព្រះសង្កថាដ៏វែងពីរោះ [illegible] ទ្រង់បានស្ដេចយាងចូលទៅ



សម្លេងទះដៃនិងសម្លេងជយឃោសន៍ បានផ្ទុះឡើងយ៉ាងទ្រហឹងអឹងកង អំពីសំណាក់កូនចៅ ថ្វាយចំពោះសម្ដេចឪ



សម្ដេចឪទ្រង់ថ្វាយបង្គំព្រះសង្ឃដែលមានព្រះជន្មវស្សាចាស់ជាងគេ ហើយ ចង់ឃើញព្រះអង្គជាយូរណាស់មកហើយ

ក្នុងព្រះវិហារ ហើយព្រះអង្គទ្រង់បានស្ដេចយាងកាត់ឬសសីមា ។ ក្នុងខណៈនោះព្រះសង្ឃក៏បានស្វាធ្យាយន៍ធម៌ និងឧបាសក-សិកា បានធ្វើពិធីដាលំដាប់លំដោយ តាមគន្លងព្រះពុទ្ធសាសនា ក្នុងកិច្ចសម្ពោធព្រះវិហារ ។

ក្រោយដែលចប់កិច្ចការសព្វគ្រប់ហើយ សម្ដេចឪទ្រង់បានស្ដេចយាងថ្វាយបង្គំព្រះសង្ឃ និងលាប្រជាពលរដ្ឋ យាងនិវត្តមកកាន់រាជធានីភ្នំពេញវិញ ដោយព្រះសុវត្ថិភាព ។

យើងសូមបញ្ជាក់ថា នៅក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាក្នុងព្រះវិហារនៅវត្តជម្ពូព្រឹក្ស នេះ សម្ដេចឪទ្រង់សព្វព្រះរាជហឫទ័យចូលកុសលបុណ្យចំនួន ២០.០០០ រៀល និងព្រះរាជទានប្រាក់ចំនួន ១០០.០០០ រៀលសំរាប់ស្ថាបនាផ្លូវថ្នល់ដាត់ ព្រមទាំងព្រះរាជទានចបកាប់ចំនួន ១០០ ចប និងម៉ាស៊ីនបូមទឹក ១ គ្រឿងសំរាប់សង្កាត់ស្វាយរមៀត ស្រុកខ្សាច់កណ្ដាល ក្នុងខេត្តកណ្ដាលនេះ ។



សហជីវិន ទឹម-ឌុង ប្រតិភូរាជរដ្ឋាភិបាលប្រចាំខេត្តកណ្ដាល ថ្លែងសុន្ទរកថាថ្វាយព្រះពរស្វាគមន៍ចំពោះសម្ដេចឪ



សម្ដេចឪទ្រង់បូជាគ្រឿងសក្ការៈថ្វាយព្រះរតនត្រៃក្នុងព្រះវិហារ



សម្ដេចឪ ទ្រង់ពិនិត្យផលិតផលសិប្បកម្មខាងតម្បាញ នៅព្រែកតាមាក់ (កណ្ដាល)



រូបទាំងអស់នេះ ជាសេនាសនៈរបស់ដូនជី ទាំងឡាយសំរាប់ចំរើនភាវនាធម៌

# ពិធីសម្ពោធកីឡដ្ឋាន នៅទីក្រុងកំពង់ចាម

ផិទាធី ១



សម្ដេចព្រះពុទ្ធសាសនូបត្ថម្ភក៍ ព្រះអង្គទ្រង់សម្ដែងការរីករាយចំពោះព្រះសង្ឃ ដែលមានព្រះគ្រូមេគណខេត្តកំពង់ចាមខាងគណៈមហានិកាយគង់ខាងដើមអាសន៍ និងព្រះគ្រូខាងគណៈធម្មយុត្តិកនិកាយគង់នៅជាបន្ទាប់ៗ

កាលពីព្រឹកថ្ងៃអាទិត្យទី ៩ មីនា ១៩៦៩ សម្ដេចឪទ្រង់បានស្ដេចយាងទៅកាន់ខេត្តកំពង់ចាម ដើម្បីទ្រង់ជាព្រះអធិបតីសម្ពោធកីឡដ្ឋានថ្មីមួយ ដែលស្ថិតនៅក្នុងបរិវេណនៃសាកលវិទ្យាល័យភូមិន្ទកំពង់ចាម ។

នៅពេលនោះ បន្ទាប់ពីសម្ដេចឪទ្រង់បានស្ដេចយាងប្រថាប់លើព្រះពន្លាពិសេស ...ចហើយ ក្រុមកីឡាករកីឡាការិនីគ្រប់ផ្នែក ... និងមកពីវិទ្យាល័យនិងមហាវិទ្យាល័យនានា បានដើរដង្ហែរជាក្បួននៅក្នុងទីលានកីឡា នាមុខព្រះពន្លាពិសេស ។



ប្រជាពលករចូលមកសម្ដែងការរីករាយចំពោះសម្ដេចឪ

បន្ទាប់ពីបានធ្វើពិធីផ្សេងៗ តាមប្រពៃណីរួចហើយ សហជីវិន ស្រី-រីន អភិបាលខេត្តកំពង់ចាម និងសហជីវិន វ័ណ្ណ-មូលីវ័ណ្ណ រដ្ឋមន្ត្រីក្រសួងអប់រំជាតិ បានថ្លែងសុន្ទរកថាជាបន្តបន្ទាប់គ្នា រៀបរាប់ពីការរីកចំរើនខាងវិស័យកីឡានៅក្នុងព្រះរាជាណាចក្រកម្ពុជា និងរៀបរាប់ពីប្រវត្តិនៃការស្ថាបនាកីឡដ្ឋានថ្មី ដែលត្រូវធ្វើពិធីសម្ពោធនេះ ។ នៅទីបំផុត សហ.ស្រី-រីន និងសហជីវិន វ័ណ្ណ-មូលីវ័ណ្ណ បានបញ្ជាក់ថា លោកនឹងខំព្យាយាមពង្រីកវិស័យកីឡានេះឲ្យកាន់តែបានចំរើនថែមទៀតស្របទៅតាមព្រះមាគ៌ានយោបាយនៃសម្ដេចឪ ។

លុះចប់សុន្ទរកថានេះហើយ ក្រុមកីឡាករ កីឡាការិនី បានធ្វើសច្ចាប្រណិធាននៅចំពោះព្រះភក្ត្រនៃសម្ដេចឪ ជាព្រះបិតាកីឡាជាតិ ។

តមក សម្ដេចឪទ្រង់បានថ្លែងព្រះសន្ដកថាមួយមានអត្ថរសនិងអត្ថន័យយ៉ាងជ្រាលជ្រៅជាទីបំ... ដូចយើងបានដកស្រង់ខ្លះតាលសំ...ានន័យដូចតទៅ ៖

## ព្រះទស្សនកិច្ច នៃសម្ដេចឪ



សម្ដេចព្រះបិតាកីឡាជាតិ ទ្រង់ព្រះសណ្ដាប់ពាក្យសច្ចាប្រណិធាន របស់កីឡាករ



សហជីវិនវណ្ណ មូលីវណ្ណ ថ្លែងសុន្ទរកថារៀបរាប់ពីការលូតលាស់ខាងវិស័យកីឡា



សហជីវិនស្រី-វើន អភិបាលខេត្ត ថ្លែងសុន្ទរកថាថ្វាយព្រះពរស្វាគមន៍ ចំពោះសម្ដេចឪ





កីឡាករទាំង ២ ភេទ បានធ្វើព្យុហយាត្រាតាមក្រុមៗយ៉ាងស្វាហាប់ ថ្វាយសម្ដេចឪ **ទ្រង់ទត**

ជាបឋមសម្ដេចឪទ្រង់បានថ្លែងថា ព្រះអង្គ មានព្រះរាជហឫទ័យ សប្បាយរីករាយ យ៉ាងខ្លាំង ដោយបានជួបព្រះសង្ឃ មានព្រះតេជៈព្រះគុណមេគណ-អនុគណ និងព្រះតេជៈព្រះគុណចៅអធិការជាដើម ព្រមទាំងមានព្រះរាជហឫទ័យសប្បាយរីករាយដោយបានមករួមក្នុងពិធីនេះ ។ ម្យ៉ាងទៀតព្រះអង្គមានព្រះរាជហឫទ័យសប្បាយរីករា[illegible]ស់ ដោយបានឃើញ សមិទ្ធិ[illegible]សាលា[illegible]ជាតិ មានទីលានកីឡាជាដើម បានរីកចំរើនជាអតិបរមា ។ ការចំរើនទាំងនេះ គឺសុទ្ធតែជាស្នាព្រះហស្តនៃព្រះសង្ឃ និងជាស្នាដៃនៃពលរដ្ឋខ្មែរ ដែលបានស្ថាបនាឡើងតាមមាគ៌ានយោបាយសង្គមរាស្ត្រនិយម ។ ប្រទេសកម្ពុជាយើង មានអគារសិក្សា យ៉ាងច្រើន តាំងបឋមសិក្សា រហូតដល់ឧត្ដមសិក្សា សម្រាប់ផ្ដល់ចំណេះវិជ្ជាដល់យុវជន-យុវតីខ្មែរយើង ឲ្យបានចេះដឹងគ្រប់ៗគ្នា ហើយនៅពេលជាមួយគ្នាយើងក៏បានពង្រីកខាងវិស័យកីឡាឲ្យបានរីកចំរើនដូចគ្នាដែរ ។ ហេតុបានជាយើងខំពង្រីកខាងវិស័យកីឡាផងនេះ ដោយហេតុថា បើយុវជន-យុវតីមានតែតម្រេះវិជ្ជាប៉ុណ្ណោះហើយគ្មានកំឡាំងកាយរឹងប៉ឹងទេ យើងក៏ពុំអាចការពារឯករាជ្យអព្យាក្រឹត - បូរណភាពទឹកដីឲ្យបានមាំទាំដែរ ។ ម្យ៉ាងទៀតវិស័យកីឡានេះ យើងបានខិតខំហាត់រៀនឲ្យបានខ




សម្តេចព្រះបិតាសមិទ្ធិជាតិទ្រង់កាត់ខ្សែបូរជាកិច្ចសម្ពោធសមិទ្ធិនានា ▲
លើរូបភាព



ទិដ្ឋភាពគួរជាទីមនោរម្យនៃទីលានហាត់ការភូមិន្ទសាកលវិទ្យាល័យ កំពង់ចាម ។ ▲
ខាងមុខគឺទីលានបាល់បោះ

ជាបាន លើកកិត្តិនាម-កិត្តិយសនៃប្រទេសកម្ពុជាយើងមួយផ្នែកយ៉ាងធំ ។ នៅក្នុងសកលលោកទាំងមូល មានប្រទេសជាច្រើនណាស់ គេបាននិយមផ្នែកកីឡានេះ ដូចប្រទេសកម្ពុជាយើងដែរ ។ នៅប្រទេសកម្ពុជាយើង ព្រះអង្គទ្រង់ព្រះរាជបញ្ជាឲ្យក្រសួងអប់រំជាតិ បញ្ចូលវិស័យកីឡានេះទៅក្នុងកម្មវិធីសិក្សា តាំងពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ។ តាំងពីបានអនុវត្តវិស័យកីឡានេះមក ឃើញថាក្រុមកីឡាករ-កីឡាការី យើងបានប្រកួតប្រជែងជាលក្ខណៈអន្តរជាតិ នៅក្នុងប្រទេសដូចជានៅពេលបើកកីឡាហ្គាណឹហ្វូជាដើម ព្រមទាំងប្រកួតប្រជែងកីឡាជាលក្ខណៈអន្តរជាតិនៅឯបរទេសនោះឃើញថា បានទទួលជោគជ័យជាទីពេញចិត្ត បណ្តាលឲ្យប្រទេសនានាកោតសរសើរ ពីការចំរើនលូតលាស់យ៉ាងឆាប់រហ័សនៃកីឡាជាតិយើង ។ល។ ហេតុនេះសូមពលរដ្ឋជាកូនចៅ ពិសេសគឺយុវជន-យុវតីខំប្រឹងហាត់រៀនកីឡានេះឲ្យបានគ្រប់ៗគ្នា និងឲ្យបានខ្លាំងពូកែឡើងថែមទៀត ដើម្បីឲ្យរូបកាយយើងបានធំធាត់ និងរឹងប៉ឹងផង, ដើម្បីទទួលយកជ័យជំនះថែមទៀតក្នុងផ្នែកកីឡាអន្តរជាតិផង ។ នៅទីបញ្ចប់ សម្តេចឪទ្រង់បានបញ្ជាក់ថា សព្វថ្ងៃនេះមានជនបរទេសគឺជនជាតិយួន គេចូលមកនៅក្នុងប្រទេសកម្ពុជាយើងកាន់តែច្រើនឡើងៗ ។ ការណ៍ដែលចូលមកនេះ គឺប្រាកដជាគេមានបំណង អាថ៌កំបាំងអ្វីមួយ ក្នុងរឿងទឹកដីយើងហើយ ។ ការណ៍ដែលជនជាតិយួនចូលមកនេះគឺព្រះអង្គមានព្រះរាជហឫទ័យព្រួយបារម្ភចំពោះទឹកដីយើង ដោយខ្លាចរបេះរបាចថ្ងបាត់បង់ដូចប្រទេសចម្ប៉ា ។ ដូច្នេះ ព្រះអង្គសូមទាញសម្បជញ្ញៈពលរដ្ឋ ពិសេសគឺយុវជន-យុវតីជាកូនចៅ ឲ្យប្រឹងប្រែងស្មារតី និងចិត្តគំនិតឲ្យមែនទែន គឺពលរដ្ឋជាកូនចៅគោងនាំគ្នាទៅនៅលើដីទំនេរៗ តាមខេត្តដែលនៅទល់ដែន ដើម្បីកុំឲ្យជនបរទេសចូលមក តាំងទីលំនៅលើទឹកដីទំនេររបស់យើង ។ បើពលរដ្ឋជាកូនចៅធ្វើតាមព្រះអង្គប្រាកដជាជនបរទេសទាំងនោះ ពុំអាចដណ្តើមយកទឹកដីយើងបានឡើយ ។ល។

លុះចប់ព្រះសន្ទរកថាដ៏សែនពីរោះនេះហើយ សម្តេចឪទ្រង់បានប្រគេនបច្ច័យចំពោះព្រះសង្ឃអស់ជាច្រើនពាន់រៀល និងព្រះរាជទានប្រាក់ដល់ក្រុមកីឡាមហាវិទ្យាល័យនីមួយៗគឺក្រុមៗចំនួន៥០.០០០រ សម្រាប់ធ្វើជាសោហ៊ុយ និងសម្រាប់ទិញសម្ភារៈផ្សេងៗ សម្រាប់កីឡារបស់ខ្លួន ។

តមក សម្តេចឪទ្រង់បានស្តេចយាងកាត់ខ្សែបូរសម្ពោធទីលានកីឡា និងកាត់ខ្សែបូរសម្ពោធដោយរូបភាពនូវទីលានកីឡាផ្សេងៗ ដែលកើតមានឡើងក្នុងខេត្តកំពង់ចាម ។

លុះចប់កិច្ចការសព្វគ្រប់តាមកម្មវិធីនេះហើយ សម្តេចឪទ្រង់បានលាមន្ត្រីរាជការ និងពលរដ្ឋជាកូនចៅ យាងទៅកាន់ព្រះរាជដំណាក់ក្នុងក្រុងកំពង់ចាម ដោយព្រះសុវត្ថិភាព ។

# ព្រះទស្សនកិច្ចនៃសម្តេចឪ
# នៅ
# ខេត្តកោះកុង



កាលពីថ្ងៃអង្គារទី ៤ មីនា ១៩៦៩ ក្នុងពេលព្រះអង្គទ្រង់បំពេញព្រះទស្សនកិច្ចនៅក្នុងខេត្តកោះកុងនោះ សម្តេចសហជីវិនព្រះប្រមុខរដ្ឋ ទ្រង់សព្វព្រះរាជហឫទ័យ ស្តេចយាងទៅថ្វាយបង្គំព្រះតេជព្រះគុណមេគណខេត្តកោះកុង នៅក្រុងខេមរភូមិន្ទ ។

នៅឱកាសនោះមានឧបាសក-ឧបាសិកាចំណុះជើងវត្តនៃព្រះអង្គបានមករង់ចាំក្រាបបង្គំគាល់សម្តេចឪជាម្ចាស់យ៉ាងអធិកអធ័មផង ។





# ពិធីជប់លៀងជូនជាកិត្តិយសចំពោះឯកឧត្តម នីកូឡៃ-ប៉ាតូលីតចេវ



ឯកឧត្តម នីកូឡាយ-ប៉ាតូលីតចេវ បានទទួលនូវព្រះហស្តសម្ពស្សអំពីសម្តេចព្រះប្រមុខរដ្ឋ

កាលពីល្ងាចថ្ងៃព្រហស្បត៍ទី ៦ មីនា ១៩៦៩ នៅព្រះដំណាក់ចំការមន សម្តេចសហជីវិនព្រះប្រមុខរដ្ឋ បានទ្រង់សព្វព្រះហឫទ័យប្រោសប្រទានការជប់លៀងសាយភត្តដោយសិទ្ធស្នាលមួយជូនជាកិត្តិយស ចំពោះឯកឧត្តម នីកូឡាយ ប៉ាតូលីតចេវ ជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មក្រៅប្រទេស នៃសហភាពសាធារណរដ្ឋសង្គមនិយម សូវៀត និងចំពោះគណៈប្រតិភូពាណិជ្ជកម្មក្រៅប្រទេសនៃស-ស-ស-ស ។

រីឯឯកឧត្តម សែរហ្គេយ៍ គូឌ្រីយ៉ាវស្តេវ ជាឯកអគ្គរដ្ឋទូតនៃសហភាពសូវៀត ប្រចាំក្រុងភ្នំពេញ ក៏បានអញ្ជើញចូលរួមក្នុងបណ្តាភ្ញៀវទាំងឡាយដែរ ដោយមានសហការីទាំងឡាយរបស់លោក នៅតាមផង ។

ចំណែកសហជីវិន គួង-ម៉ាវហ្គាំងជានាយកក្រុមនិពន្ធ នៃខុទ្ទកាល័យ សម្តេចព្រះប្រមុខរដ្ឋ ក៏បានទទួលសេចក្តីសូមអញ្ជើញនៅចូលរួមក្នុងឱកាសជប់លៀងនេះផងដែរ ។

បដិសណ្ឋារកិច្ចនេះ បានប្រព្រឹត្តទៅប្រកបដោយបរិយាកាសស្និទ្ធស្នាល និងរីករាយជាពិសេស ហើយបានត្រូវបញ្ចប់ដោយការប្តូរវត្ថុជាអនុស្សាវរីយ៍ទៅវិញទៅមក ។ សម្តេចសហជីវិន បានទ្រង់ប្រោសប្រទានចំពោះឯកឧត្តម នីកូឡាយ ប៉ាតូលីតចេវ ព្រមទាំងចំពោះសមាជិកទាំងឡាយនៃគណៈប្រតិ



ឯកឧត្តម នីកូឡាយ-ប៉ាតូលីតចេវ និងឯកឧត្តមឯកអគ្គរដ្ឋទូតសូវៀតបាន ទទួលនូវ[illegible]អំពីសម្តេចឳ



សម្ដេចឪនិងឯកឧត្ដមនីកូឡាយ-ប៉ាតូលីតចេវ ព្រមទាំងភ្ញៀវកិត្តិយសទាំងឡាយ បានលើកកែវឡើងប្រសិទ្ធីចំពោះប្រជាជាតិទាំងពីរ ដោយមិត្តភាពយ៉ាងជាប់ខ្ជួន

ភូរបស់លោក នូវគ្រឿងប្រាក់ប្រកបដោយក្បាច់ចម្លាក់ជាស្នាដៃនៃពួកសិប្បករយើង ហើយព្រះអង្គបានទ្រង់ទទួលពីភ្ញៀវដ៏ឆ្នើមរបស់ព្រះអង្គ នូវកាមេរ៉ាថតសម័យទំនើបបំផុតមួយគ្រឿងសំរាប់ថតខ្សែភាពយន្តទំហំ-១៦ ម-ម ដែលធ្វើនៅសហភាពសូវៀត ។

គួរយើងពោលបញ្ជាក់ថា ក្នុងឱកាសបដិសណ្ឋារកិច្ចពិធីនេះ ឯកឧត្ដម នីកូឡាយ ប៉ាតូលីតចេវ បានអះអាងបញ្ជាក់ជាច្រើនលើកច្រើនគ្រា ក្នុងនាមរដ្ឋាភិបាលរបស់លោក នូវកិច្ចគាំទ្រយ៉ាងមុឹងមាត់របស់សហភាពសូវៀត ចំពោះនយោបាយជាតិខ្មែរ ដែលប្រកាន់ខ្ជាប់នូវឯករាជ្យ អព្យាក្រឹត និងអហង្ការ ដែលទាក់ទងនឹងអធិបតេយ្យភាពនៃព្រំប្រទល់ដែនរបស់ខ្លួនតែរម្មយ ។

o
o o



សម្ដេចឪទ្រង់ទទួលនូវកាមេរ៉ាថតទំនើបបំផុត ១ គ្រឿងសំរាប់ថតខ្សែភាពយន្ត អំពីឯកឧត្ដមនីកូឡាយ-ប៉ា[illegible]ចេវ

សាលាក្រុ



ឯកឧត្ដមនីកូឡាយ-ប៉ាតូលីតចេវបានទទួលនូវវត្ថុអនុស្សាវរីយ៍ដ៏មានតម្លៃ អំពីសម្ដេចឪ គឺគ្រឿងប្រាក់ប្រកបដោយក្បាច់ចម្លាក់ជាស្នាដៃនៃសិប្បករខ្មែរយើង

# បច្ចុប្បន្នភាព ដោយ រូបភាព





ឯកឧត្តម នីកូឡាយ-ប៉ាតូលីតចេវ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មសូវៀត បាន អញ្ជើញទស្សនាសារមន្ទីរជាតិ កាលពីថ្ងៃទី ៧ មីនា ១៩៦៩

នៅថ្ងៃដដែលនោះ ភ្ញៀវដ៏ឧត្តមរបស់យើង បានទស្សនាព្រះបរមរាជវាំង ទៀត ក្រោមការណែនាំនៃអ្នកអង្គម្ចាស់នរោត្តម-កន្តុល





លោកស្រីហ្គុលដា-ម៉ែរ (*Golda Meir*) ជានាយករដ្ឋមន្ត្រីបាត់តាំង អ៊ីស្រាអែល ជំនួសឯ.ឧ. ឡឺវី-អេស្កុល ដែលទើបនឹងទទួលមរណភាព ។

នៅក្នុងរូបនេះ នៅឱកាសបំពេញទស្សនកិច្ចក្នុងប្រទេសកម្ពុជា កាលពីខែកុម្ភៈ ១៩៦២ លោកស្រីហ្គុលដាម៉ែរដែលពេលនោះនៅកាន់ដំណែងជារដ្ឋមន្ត្រីក្រសួងការបរទេសនៅឡើយ បានចូលក្រាបបង្គំគាល់សម្តេចសហជីវិនព្រះប្រមុខរដ្ឋ នៅព្រះដំណាក់ចំការមន ។

# បច្ចុប្បន្នភាព ដោយ រូបភាព






ពិធីដោះលែងឈ្លើយអាមេរិកាំង ៤ នាក់ នៅក្រសួងការបរទេស ក្រោមអធិបតីភាពនៃសហជីវិន ណៃ-ភ៉ឡង់ពាំង ជាតំណាងអ្នកអង្គម្ចាស់រដ្ឋមន្ត្រីក្រសួងការបរទេស(ថ្ងៃទី ១១ មីនា ១៩៦៩)





ការចែកទស្សនាវដ្ដី «កម្ពុជា» និងស្បែកជើងឲ្យដល់ឈ្លើយអាមេរិកាំងទាំង ៤ រូបនោះ នៅស្ថានទូតអូស្ត្រាលី (ថ្ងៃទី ១២-៣-៦៩)



ការចេញដំណើរពីចំណតអាកាសយានពោធិ៍ចិនតុង នៃ ឈ្លើយអាមេរិកាំង ៤ នាក់ ដែលទើបនឹងរួចពីការឃុំឃាំង ដោយសេចក្ដីប្រោសប្រណីនៃសម្ដេចសហជីវិន ព្រះប្រមុខរដ្ឋ (១[illegible]៩)



ស.ហ. អ៊ុំ-ផាន់

# សូមគោរព ទង់ជាតិខ្មែរផង !

ប្រទេសទាំងឡាយក្នុងលោក ទាំងធំទាំងតូច សុទ្ធតែមានទង់ជាតិ សម្រាប់ជាតំណាង, ជានិមិត្តរូបនៃប្រទេសរបស់ខ្លួន ។ នៅក្នុងពិធីការផ្សេងៗ ដូចជាពិធីបុណ្យជាតិ, ពិធីសម្ពោធសមិទ្ធិនានាជាដើម គេតែងតែបានដោតទង់ជាតិ និងធ្វើពិធីគោរពទង់ជាតិនៅពេលនោះផង ។ ក្នុងពិធីគោរពទង់ជាតិនេះមិនត្រឹមតែពលរដ្ឋជាម្ចាស់ប្រទេស ដែលមានភារៈ និងករណីយកិច្ចធ្វើការគោរពប៉ុណ្ណោះទេ គឺអាណិកជនបរទេសដែលបានមករស់នៅក្នុងប្រទេសគេនោះ ក៏ត្រូវគោរពទង់ជាតិនៃប្រទេសនោះផងដែរ ។

**នៅប្រទេសកម្ពុជាយើងៗមានទង់ជាតិមានសញ្ញារូបប្រាសាទអង្គរ ដែលជាតំណាង, ជានិមិត្តរូបនៃប្រទេសកម្ពុជា មានតាំងពីច្រើនសតវត្សមកហើយ — ហើយក្នុងពិធីការផ្សេងៗ ដូចជាពិធីបុណ្យ, ពិធីសម្ពោធសមិទ្ធិនានាជាដើម គឺបានដោតទង់ជាតិ, ធ្វើពិធីគោរពទង់ជាតិ បានទៅជាប្រពៃណីដ៏ប្រសើររបស់ជាតិខ្មែរយើង ។ លុះមកដល់សម័យសង្គមរាស្ត្រនិយម យើងនេះ សមាជជាតិបានសម្រេចថែមទៀតឲ្យធ្វើពិធីគោរពទង់ជាតិនៅគ្រប់សាលារៀន នៅគ្រប់មន្ទីររាជការ,** គ្រប់ក្រុមហ៊ុនជាតិ នៅពេលព្រឹក-ល្ងាច និងនៅគ្រប់រោងល្ខោន, រោងភាពយន្ត នៅមុនពេលបើកសំដែង និងបញ្ចាំងភាពយន្ត ព្រមទាំងបានសំរេចឲ្យតាំងព្រះបរមឆាយាល័ក្ខណ៍ នៃសម្ដេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង, និងសម្ដេចព្រះប្រមុខរដ្ឋ នៅក្នុងសាលារៀន, នៅក្នុងមន្ទីររាជការនានា, នៅក្នុងរោងល្ខោន និងនៅក្នុងរោងភាពយន្តទៀតផង ។

**ពិធីគោរពទង់ជាតិដែលប្រារព្ធ**ឡើងក្នុងពិធីធំៗ ជាប្រពៃណីនោះ គឺបានប្រព្រឹត្តទៅយ៉ាងទៀងទាត់ ។ ឯពិធីគោរពទង់ជាតិ នៅគ្រប់សាលារៀន, នៅគ្រប់មន្ទីររាជការ, នៅគ្រប់រោងល្ខោនរោងភាពយន្ត និងការតាំងព្រះបរមឆាយាលក្ខណ៍ទៅតាមសេចក្ដីសំរេចនៃសមាជជាតិនោះ គឺរាជរដ្ឋាភិបាលបានបង្គាប់ — បញ្ជាឲ្យទទួលគោរពទៅហើយដែរ ដែលសព្វថ្ងៃនេះនៅកន្លែងភាគច្រើនសុទ្ធសឹងតែបានគោរពដោយម៉ត់ចត់គួរឲ្យសរសើរ ។ ឯនៅកន្លែងខ្លះដែលឮថាពុំទាន់បានគោរពដោយម៉ត់ចត់និងទៀងទាត់នោះ គឺមានពិតមែន ប៉ុន្តែការនេះ យើងនៅតែពុំសូវមានទំនាស់ចិត្តពេកទេ ព្រោះយើងនៅមានសង្ឃឹមថា គង់តែមានការគោរពដោយម៉ត់ចត់និងទៀងទាត់នៅពេលដ៏ឆាប់ខាងមុខនេះជាពុំខាន ។ ឯកន្លែងដែលធ្វើឲ្យយើងមានទំនាស់ចិត្តដ៏ហួសប្រមាណនោះគឺ **នៅត្រង់សាលារៀនឯកជនបរទេស ដូចជាសាលាមិស, សាលាដេការតេ។ល។ និងសាលាឯកជនបរទេសចិន-យួន ព្រមទាំងរោងចក្រធំៗរបស់ឯកជនដែលមានតាំងនៅក្នុងប្រទេសកម្ពុជាយើង ឃើញថាពុំទាន់មានធ្វើពិធីគោរពទង់ជាតិ ព្រមទាំងពុំសូវឃើញមានតាំងព្រះបរមឆាយាលក្ខណ៍** ឲ្យដូចសាលារៀនរបស់រាជការខ្មែរយើងនៅឡើយទេ ។ ការដែលពុំព្រមធ្វើនេះ នាំឲ្យពលរដ្ឋខ្មែរយើងធ្វើការសន្និដ្ឋានបានច្រើនដំពូក ។

ជាការណ៍ពិតណាស់នៅប្រទេសកម្ពុជាយើងនេះរាជរដ្ឋាភិបាលខ្មែរមិនត្រឹមតែផ្ដល់សិទ្ធិ-សេរីភាពឲ្យពលរដ្ឋខ្មែរបានរស់នៅយ៉ាងសម្បូរសប្បាយ និងបានសុខសាន្តប៉ុណ្ណោះទេ គឺបានផ្ដល់ឲ្យជនជាតិបរទេសទាំងអស់ ដែលបានមករស់នៅក្នុងស្រុកខ្មែរ មានសិទ្ធិសេរីភាពក្នុងការរស់នៅយ៉ាងសម្បូរសប្បាយ និងបានសុខសាន្តដូចពលរដ្ឋខ្មែរដែរ ។ នេះបញ្ជាក់ឲ្យឃើញថាជាតិខ្មែរសុទ្ធតែមានចិត្តជាមនុស្សធម៌ បាន[illegible]ពិត អាសូរ ស្រឡាញ់រាប់អាន-ជួយផ្ដល់សេចក្ដីសុខឲ្យជនបរទេសជាមិត្តដូចជាជនជាតិខ្មែរដែរ គឺមិនមែនមានចិត្តអាក្រក់ជួជាតិ ដូចជាជនជាតិខ្លះដែលនៅជិតខាងនៃប្រទេសយើងឡើយ ។ ដូច្នេះ គួរណាស់តែជនបរទេស(សាលាឯកជននិងរោងចក្រឯកជនបរទេស)ទាំងនេះនាំគ្នាគោរពទៅតាមទំនៀមទម្លាប់-ច្បាប់ខ្មែរខ្លះផង គឺសូមឲ្យសិស្សានុសិស្សនៅសាលារៀន និងបុគ្គលិកធ្វើការនៅក្នុងរោងចក្រធំៗរបស់ខ្លួនគោរពទង់ជាតិ និងចេះច្រៀងបទនគររាជខ្មែរ ព្រមទាំងតុបតែងតាំងព្រះបរមឆាយាលក្ខណ៍ នៅគ្រប់បន្ទប់សាលារៀនរបស់ខ្លួនផង ។ ឯរោងចក្រឯកជនជាតិខ្មែរយើង គឺជាការចាំបាច់ត្រូវតែធ្វើពិធីគោរពទង់ជាតិខ្មែរ នៅពេលព្រឹក-ល្ងាច និងឲ្យបុគ្គលិកចេះច្រៀងបទនគររាជ ហើយនិងរៀបចំតែងតាំងព្រះបរមឆាយាលក្ខណ៍ព្រះមហាក្សត្រខ្មែរយើងឲ្យបានម៉ត់ចត់ និងបានល្អ ដើម្បីជាគំរូដល់ជនបរទេស ។

**តាមយើងដឹងនិងជាការណ៍**ប្រាកដប្រជាផង គឺសាលាឯកជនទាំងអស់ សុទ្ធតែស្ថិតនៅក្រោមអំណាចច្បាប់ខ្មែរ, និងសាលាឯកជនខ្លះ ដូចជាសាលាមិស, សាលា

## ប្រហារលុះត្រាក្ស័យ

### (នៅប្រទេសអារ៉ាប់រួម)

ក្នុងសប្តាហ៍កន្លងទៅនេះ ប្រទេសអារ៉ាប់រួមនិងប្រទេសអ៊ីស្រាអែល បានបើកឆាកប្រយុទ្ធគ្នាយ៉ាងសាហាវលើសពីពេលណាទាំងអស់ៗ ខាងយោធាអ៊ីស្រាអែល បានប្រើយន្តហោះ, កាំភ្លើងធំ, រថក្រោះ បាញ់ឆ្លងកាត់ព្រែកជីកស៊ុយអេ មកលើដែនដីប្រទេសអេហ្ស៊ីបបណ្តាលឲ្យកក្រើកទឹកដី ។ ចំណែកខាងប្រទេសអេហ្ស៊ីប ក៏បានបាញ់កាំភ្លើងធំតបតទៅវិញព្រួសរហាក់ប៉ីដូចជារន្ទះទាំង ៨ ទិស ខ្ទេចអស់ព្រៃព្រឹក្សា និងមនុស្សព្រមទាំងសម្ភារៈរបស់ប្រទេសអ៊ីស្រាអែលយ៉ាងច្រើន ដែលយើងបានស្រង់យកមកដំរាបលោកអ្នកឲ្យបានជ្រាបថា៖ កាំភ្លើងធំរបស់ប្រទេសអេហ្ស៊ីប ដែលបានបាញ់ទៅលើប្រទេសអ៊ីស្រាអែលនេះ បានធ្វើឲ្យទាហានអ៊ីស្រាអែលស្លាប់ ១០០ នាក់, ខូចខាតរថក្រោះ ៣១ គ្រឿង, ប៉ុស្តិ៍ត្រួតពិនិត្យ ១១ កន្លែង, ប៉ម ២៣, រថយន្តកាំមីញ៉ុង ១៣ គ្រឿង, រថយន្តដឹកគ្រាប់រំសេវ ៦ គ្រឿង, កាំភ្លើងធំ ៤ ដើម, កន្លែងដាក់កាំភ្លើងធំចំនួន ២ កន្លែង និងកន្លែងដាក់កាំភ្លើងធំបាញ់យន្តហោះ ២ កន្លែងទៀតៗ ខាងប្រទេសអេហ្ស៊ីបវិញ ក៏មានការខូចខាតយ៉ាងធ្ងន់ដែរ គឺមានស្លាប់ ៣ នាក់ ត្រូវរបួស ១៣ នាក់ អន្តរាយផ្ទះជាច្រើន ៗ ការដែលថាប្រទេសអេហ្ស៊ីបខូចខាតធ្ងន់នោះ គឺនៅត្រង់គ្រាប់កាំភ្លើងធំរបស់អ៊ីស្រាអែល បានបាញ់ទៅត្រូវលោកឧត្តមសេនីយ៍អាប់ដែលមូនិមរីយ៉ាដជានាយសេនាធិការនៃកងកម្លាំងអេហ្ស៊ីប បណ្តាលឲ្យលោកទទួលមរណភាពភ្លាម ៗ លោកយ៉ាដជាដៃស្តាំលោកណាសែរ ៗ ឥឡូវប្រទេសទាំង ២ គឺអេហ្ស៊ីប និងអ៊ីស្រាអែលកំពុងតែខឹងដាក់គ្នា ហើយការវាយប្រហារឆ្លងកាត់ព្រែកជីកស៊ុយអេក៏នៅតែប្រព្រឹត្តទៅជាដរាបទៀត ។ ក្នុងឱកាសដង្ហែសពលោកឧត្តមសេនីយ៍យ៉ាដទៅបញ្ចុះនៅក្រុងគែរនោះមានមនុស្សជាង ១ លាននាក់បានចូលរួមរួមក្នុងពិធីដ៏សែនក្រៀមក្រំនេះ ។ គិតទៅតាំងពីលោកស្រីម៉េរឡេងធ្វើជារដ្ឋមន្ត្រីទី ១ ប្រទេសអ៊ីស្រាអែលមក ភ្លើងសង្គ្រាមនៅមជ្ឈិមបូព៌ា បានរីកឡើងដូចគេដុះប្រេងសាំងលើអណ្តាតភ្លើងដែលកំពុងឆេះ ។



សហជីវិន ឈិន-ផុន

○

## ខាត់ឆ្វេងខាត់ស្តាំ

### (នៅប្រទេសអ៊ីស្រាអែល)

ប្រទេសអ៊ីស្រាអែលពុំមែនធ្វើសង្គ្រាមតែជាមួយប្រទេសអេហ្ស៊ីបទេ ប្រទេសអ៊ីស្រាអែលបានបាញ់តគ្នាជាមួយនិងប្រទេសហ៊្សីក ជាទី ➤

---

ដេការតិ៍ ៗលៗ មានកូនខ្មែរយ៉ាងច្រើនចូលទៅរៀនផងដែរ ។ ជាការណ៍ប្រាកដប្រជាថែមទៀត ពិធីគោរពទង់ជាតិ គឺជាពិធីដ៏ឧត្តមរបស់ខ្មែរ ប៉ុន្តែក៏ពុំមែនជាពិធីមានទម្ងន់ធ្ងន់ធ្ងរ មានការលំបាករហូតដល់ទៅជនបរទេសជាមិត្តទាំងនេះធ្វើពុំកើតសោះឡើយ ។ បើជនបរទេសជាមិត្តមានចិត្តគំនិតល្អចំពោះខ្មែរនោះ ប្រាកដជាអាចធ្វើពិធីគោរពទង់ជាតិខ្មែរនេះបានដោយងាយ ហើយបានម៉ត់ចត់ទៀតផង [illegible]កដប្រជាទៀតផង ៗ

ដូច្នេះ ក្នុងរឿងធ្វើពិធីគោរពទង់ជាតិខ្មែរ ឲ្យសិស្សានុសិស្សច្រៀងបទនគររាជខ្មែរ និងឲ្យគុបតែងតាំងព្រះបរមធាយាលក្ខណ៍នៃព្រះមហាក្សត្រខ្មែរ ដែលសាលាឯកជនបរទេសជាមិត្តបានធ្វើខ្លះហើយ (បើមាន) និងពុំទាន់បានធ្វើនោះ គឺពលរដ្ឋខ្មែរអ្នកជាតិនិយម ដែលមានខ្លួនយើងរួមជាមួយផង សូមធ្វើសំណូមពរ និងសូមសង្ឃឹមថា ប្រាកដជាមិត្តបរទេសនៃយើង ផ្នែកខាងលើនេះ នឹងបានធ្វើតាមតម្រាប់សាលារៀនរបស់រាជការខ្មែរជាពុំខាន ៗ បើបានធ្វើតាមនោះហើយ ពលរដ្ឋខ្មែរដែលមានខ្លួនយើងរួមផង សូមថ្លែងនូវសេចក្តីសរសើរយ៉ាងស្មោះ ៗ ផ្ទុយទៅវិញ បើជនបរទេសជាមិត្តនៃយើងពុំគោរពតាមទំនៀមទំលាប់ច្បាប់របស់ខ្មែរត្រង់ដំពូកខាងលើនេះផងទេ ប្រាកដជាខ្មែរពុំសូវពេញចិត្ត ហើយជាពិសេសគឺខ្មែរពុំព្រមបណ្តោយឲ្យមិត្តបរទេសណាយកទឹកដីនៃប្រទេសកម្ពុជា ធ្វើជាទីលាននយោបាយរកផលប្រយោជន៍សំរាប់ប្រទេសដើមរបស់ខ្លួនឡើយ និងពុំបណ្តោយឲ្យជនបរទេសណាបង្កើតរដ្ឋនៅក្នុងប្រទេសកម្ពុជាជាដាច់ខាត ។

រឿងនេះ យើងសូមធ្វើសំណូមពរផងដែរចំពោះក្រសួងមានសមត្ថកិច្ច ជាអាទិ៍គឺក្រសួងអប់រំជាតិ និងក្រសួងសន្តិសុខជាតិសូមមេត្តាពិនិត្យឲ្យមែនទែន ដើម្បីឲ្យច្បាប់ខ្មែរមានអានុភាពទៅលើជនជាតិបរទេសដែលរស់នៅក្នុងប្រទេសខ្មែរ គឺឲ្យជនបរទេសទាំងនេះគោរពច្បាប់ខ្មែរឲ្យបានម៉ត់ចត់ដូចជាខ្មែរយើងផង ៗ

**អ៊ូរ-ផាន់**

ទៀត ៗ តាមប្រទេសអ៊ីស្រាអែលថា ខ្លួនពុំបានបាញ់ប្រទេសហ្ស៊កដានីមុនទេ គឺយោធាហ្ស៊កដានីបានបាញ់ទៅលើប្រទេសអ៊ីស្រាអែល ទើបយោធាអ៊ីស្រាអែលខ្ទាក់គ្រាប់កាំភ្លើងដៃ និងគ្រាប់រ៉ុក្កែតទៅលើកងកម្លាំងហ្ស៊កដានី ដើម្បីកុំឲ្យខាងហ្ស៊កដានីថាខ្លួនកំសាក ៗ គ្រាន់បើដែរ យោធាអ៊ីស្រាអែលចេះទប់ខ្លួនបានហ្នឹងហ្ន៎ គឺថាវាយប្រទេសអេហ្ស៊ីបផង, វាយប្រទេសហ្ស៊កដានីផង, វាត់តែទាំងអស់ឲ្យតែប្រទេសណាហ៊ានបាញ់ទៅលើប្រទេសអ៊ីស្រាអែល តែ . . . តែចុះដីដែលអ៊ីស្រាអែលយកពីប្រទេសអារ៉ាប់នោះតើគិតយ៉ាងណា ៗ ៗ!

០

## យ័ក្សត្រួតពល

### (នៅប្រទេសយួនខាងត្បូង)

កងអាទិត្យកន្លងទៅនេះ ពួករដ្ឋការក្រុងព្រៃនគរបានរៀបចំតុកៅអី, ស្រា, ស្រី, ទាហាន, គ្រឿងអាវុធគ្រប់បែបយ៉ាងចាំទទួលចៅហ្វាយមកប៉ាលខ្លួន គឺលោកម៉ែលវិនលែរដ៍ ជារដ្ឋលេខាធិការក្រសួងការពារប្រទេសអាមេរិកាំង ដែលនឹងមកត្រួតពិនិត្យទាហាននានានៅប្រទេសយួនខាងត្បូង ៗ លុះលោកលែរដ៍នេះមកដល់ ធីវ និងគីបាននាំក្រសុះជើង ៣ ជើង ៤ ទៅក្រាបវន្ទាទទួលចៅហ្វាយខ្លួនប្រៀបបាននិងខ្ញុំបំរើដែលឃើញចៅហ្វាយនាយមកពីផ្សារ ៗ គ្រាន់តែលោកលែរដ៍នេះចុះដល់ដីយួនព្រៃនគរភ្លាមពរស្វាគមន៍នៃគ្រាប់កាំភ្លើងរបស់ពួកវៀតកុងក៏បានបន្ទឺឡើងរហើយៗនិងស្ទឹកត្រចៀកបណ្ដាលឲ្យលោកធីវនាំចៅហ្វាយនាយទៅកាន់វិមានប្រធានាធិបតីនៅព្រៃនគរយ៉ាងប្រញាប់ប្រញាល់ស្ទើរតែលោកលែរដ៍ចង់ទៅជាខ្យល់គនៅលើរថយន្ត ៗ ក្រោយពីបានសំរាកបាត់ពុលយន្តហោះបាត់ខ្យល់គមក លោកលែរដ៍ក៏ចាប់ផ្ដើមពិនិត្យមើលស្ថានការណ៍យោធានៅប្រទេសយួនខាងត្បូង រួចលោកក៏គ្រវីក្បាល ត តាត់ដូចតឹកកែពុលកំបោរបៀកមួរ ព្រោះឃើញបញ្ជីខ្មៅគឺបញ្ជីមរណៈនៃយោធាអាមេរិកាំងក្រាសដូចសៀវភៅវចនាធិប្បាយបារាំង-ខ្មែរ ព្រមទាំងឮសូរតែគ្រាប់បែកក្បាល, គ្រាប់បែករ៉ុក្កែតរបស់ពួកវៀតកុងបាញ់ពាសពេញទឹកដីយួនខាងត្បូងទៀត ៗ បើបែរទៅមើលមុខយោធាអាមេរិកាំងវិញគ្មានឃើញអ្នកណា ១ សប្បាយចិត្តទេ ព្រោះពួកនេះយល់ឃើញថា លោកលែរដ៍ប្រាកដជាមកឲ្យបញ្ជាដល់នាយទាហានខ្លួនដើម្បីឲ្យបន្តការប្រយុទ្ធជាមួយពួកវៀតកុងជាមិនខានៗ យោធាអាមេរិកាំងបានដឹងណាស់ទៅហើយថា ពួកខ្លួនពុំអាចយកជ័យពីពួកវៀតកុងបានទេ ព្រោះពស្រួយយួនស្ទើរតែទាំងអស់សុទ្ធតែវៀតកុងទៅហើយ ម៉្លោះហើយមានផ្លូវអ្វីនឹងយកជ័យជំនះកើត? លោកលែរដ៍បានស្ថិតនៅប្រទេសយួនខាងត្បូងចំនួន ៤ ថ្ងៃ ហាក់បីដូចជា ៤ សតវត្ស ព្រោះមកពីលោកដេកក៏ពុំបាន អង្គុយក៏ពុំសុខ លេបនំបុ័ងដូចលេបដែកគោល ព្រោះភ័យខ្លាចតែខ្លួនលោកយកឆ្អឹងមកទុកនៅព្រៃនគរ ៗ មុននឹងចេញដំណើរទៅក្រុងវ៉ាស៊ីនតោន លោកលែរ បានត្រូវអ្នកកាសែតដាន់មាត់ប្រាប់គេថា៖ ទាហានអាមេរិកាំងពិតជាបានចូលទៅក្នុងប្រទេសលាវមែន តែចូលជួយយោធាអាមេរិកាំងដែលស្ថិតនៅប្រទេសលាវស្រាប់ប៉ុណ្ណោះ ៗ លុះគេសួរថា តើទាហានដែលចូលទៅនោះមានចេញប្រតិបត្តិការទេ? លោកលែរដ៍ លេបទឹកមាត់រួចគ្រវីក្បាលដោយពុំមានចេញវាចាឡើយ សង្គ្រាមនៅប្រទេសយួនខាងត្បូងគ្មានសញ្ញាណាបង្ហាញឲ្យឃើញថានឹងរលត់ទៅឆាប់ទេ ៗ

០

## មិនខ្លាច មិនស្លុត មិនញរញើត មិនហាន

### (នៅប្រទេសចិនប្រជាមានិត)

ចាប់តាំងពីមានកើតឧប្បត្តិហេតុរវាងប្រទេសចិន និងសហភាពសូវៀតមក ក្រុងប៉េកាំងបានបញ្ជូនទាហានចំនួន ៥ លាននាក់ ឲ្យទៅកាន់ព្រំដែនចិន-សូវៀត ដើម្បីរៀបចំក្នុងការប្រយុទ្ធ ៗ ទាហានចិនទាំងនោះមានចិត្តក្លៀវក្លាក្លាហានណាស់ គឺមិនខ្លាច មិនស្លុត មិនញញើតក្នុងការប្រយុទ្ធឡើយ តែមិនហានចូលដីសូវៀតទេ ដោយខាងសូវៀត គេបានដាក់ទ័ពដូចចិនដែរ ៗ សភាពតានតឹងរវាងចិន-សូវៀតនោះរនៅតែតឹងតែងជានិច្ច ហើយពលរដ្ឋនៃប្រទេសនីមួយៗក៏បានបះបោរធ្វើបាតុកម្មប្រឆាំងនឹងស្ថានទូតរៀងៗប្រទេសដែរ ៗ តាមពិនិត្យមើលទៅបើចិនហានវាយសូវៀតប្រាកដជាសូវៀតហានវាយចិនដែរហើយបើមានការវាយគ្នាជាថ្មីនោះប្រាកដជាមានស្លាប់ទាំងសងខាងមិនខានឡើយៗ បើយ៉ាងដូច្នេះតើអ្នកណាបានចំណេញ? ច្បាស់ជាមហាអសុកខាងលោកសេរីហើយដែលបានចំណេញដោយឃើញពួកកំព័ន្ធខាងក្រហមទាំងពីរនាក់ស្លាប់ និងខ្សោយកម្លាំង ៗ ណ្ហើយឈប់ឈ្លោះគ្នាទៅព្រោះកាន់លទ្ធិក្រហមដូចគ្នាទេតើ ?

០

០ ០

**ឈិន-ផុន**




**សម្តេចឪ–** បើជំពាក់ម្លឹងៗ សហជីវិនរកប្រាក់សងរោងពុម្ពឯណាបាន។ បើគេមិនសងទេ ត្រូវឱ្យបោះបន្ថយចំនួន ហើយកុំផ្ញើការសែតទៅឱ្យទៀត ។

**Samdech Euv.**— Réduisez le nombre de tirage et ne servez plus ceux qui ne paient pas. Compris Sahachivin ?

# សេចក្តីអំពាវនាវ

តាមបញ្ជីដែលគណនេយ្យករអ្នកជាតិនិយម បានស្រង់រៀងរាល់ខែដូចខាងលើនេះ ឃើញថាប្រាក់បំណុលរបស់សារពត៌មានអ្នកជាតិនិយម មានចំនួនច្រើនហួសហេតុពេក ពុំអាចឱ្យសារពត៌មាននេះរស់រានមានជីវិតតទៅទៀតបានឡើយ ។

អាស្រ័យហេតុនេះ ទីចាត់ការសារពត៌មានអ្នកជាតិនិយម សូមអំពាវនាវដល់សហជីវិនប្រតិភូរាជរដ្ឋាភិបាល និងសហជីវិនអភិបាលក្រុង-ខេត្ត ដែលនៅមានជំពាក់អ្នកជាតិនិយម សូមមេត្តាចាត់ឱ្យធ្វើបញ្ជីស្រង់នាមអ្នកជាវដែលពុំទាន់បានសងប្រាក់តម្លៃជាវតាំងពីឆ្នាំ ១៩៦៥ មកទល់នឹងចុងឆ្នាំ ១៩៦៨ នោះ ផ្ញើទៅទីចាត់ការសារពត៌មានអ្នកជាតិនិយមដើម្បីនឹងបានចាត់ការទៅតាមផ្លូវច្បាប់ ។

សូមអរគុណ

# ព្រះមេត្តាប្រោសប្រណីនៃសម្ដេចឪ

## ជំនួយសង្គ្រោះនៃក្រុមសង្គហជាតិ

អំពីមូលនិធិនៃក្រុមសង្គហជាតិ ដែលព្រះអង្គទ្រង់ជាព្រះប្រធាននោះ សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ បានទ្រង់សព្វព្រះហឫទ័យ ប្រោសប្រទានព្រះអំណោយជាប្រាក់ដោយមានចំនួនដូចតទៅ៖

— ប្រាក់ ៤.២០០រៀលចំពោះឈ្មោះ សួង-ស៊ុម និងនាងជិម-ជិន ជាប្ដីប្រពន្ធ នៅទួលម្កាក់ សង្កាត់លលកស ស្រុកបាកាន ខេត្តពោធិ៍សាត់ ដែលបានទទួលរងគ្រោះពីអំពើលួចប្លន់ កាលពីថ្ងៃទី ៣ កញ្ញា ១៩៦៨

— ប្រាក់ ៣.០០០រៀល ចំពោះនាងទៀង-វុន នៅស្វាយជ្រុំស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង ដោយឈ្មោះមាស-ម៉ៃ ជាប្ដីបានបង់កសម្លាប់ខ្លួន កាលពីថ្ងៃទី ៩ វិច្ឆិកា ១៩៦៨,

— ប្រាក់ ៣.៥០០រៀល ចំពោះនាងញឹក-ទារ នៅរំដួល ខេត្តស្វាយរៀង ដែលបានទទួលរងគ្រោះពីអគ្គីភ័យកាលពីថ្ងៃទី២២ កក្កដា ១៩៦៨ ។

°

° °

— ២.០០០ រៀល ចំពោះឈ្មោះ ទុ-ប៉ាន់ នៅកំពង់ពពិល ស្រុកពាមរ៉ក៍ ខេត្តព្រៃវែង ដោយគ្រាប់ពីរក្បាលរបស់ឈ្មោះនេះបានត្រូវខ្ទុះបាញ់ស្លាប់ កាលពីថ្ងៃទី១០ តុលា ១៩៦៨ ។

— ២.០០០ រៀល ចំពោះឈ្មោះ ឃុន-គុន ជាអ្នកស្រុកនៅសង្កាត់ជាឃ្លាំង ស្រុកព្រៃវែង ដោយប្រពន្ធឈ្មោះនាងយក់-ណេង បានទទួលមរណភាពដោយគ្រាប់បែក កាល ...៣ ១៩៦៨ ។

— ៤.០០០ រៀល ចំពោះឈ្មោះ ណុន-នាត ដែលមានកូនម្នាក់ក្នុងបន្ទុក ហើយដោយប្រពន្ធឈ្មោះនាង សួន-យ៉ាង និងគ្រាប់ពីរក្បាល បានទទួលមរណភាព និងស្លាប់ដោយខ្ទុះបាញ់ កាលពីថ្ងៃទី ៣ តុលា ១៩៦៨ ។

— ៣.០០០រៀល ចំពោះនាងយឹម-អេង នៅសង្កាត់បន្ទាយចក្រី ខេត្តព្រៃវែង ដោយប្ដីរបស់នាងឈ្មោះ ចាន់-ខេង បានទទួលមរណភាពដោយខ្ទុះបាញ់ កាលពីថ្ងៃទី ១១ តុលា ១៩៦៨ ។

—២.០០០រៀលចំពោះឈ្មោះស៊ុំ-កួយ នៅសង្កាត់ដដែលនេះ ដោយប្រពន្ធរបស់ខ្លួន ឈ្មោះនាងសេន-ប្រេង បានទទួលមរណភាពក្នុងកាលៈទេសៈដដែលនេះដែរ

— ១.០០០រៀល ចំពោះព្រះសង្ឃព្រះនាមពេជ-អាន អាយុ ២១វស្សា ដែលត្រូវរបួសធ្ងន់ ដោយខ្ទុះបាញ់នោះ ។

— ៤.០០០រៀល ចំពោះនាង កែវ-ម៉ៅ ដែលមានកូនពីរនាក់ក្នុងបន្ទុក ជាអ្នកស្រុកនៅសង្កាត់កាហែង ស្រុកសំពៅមាស ខេត្តកំពង់ស្ពឺ ដោយប្ដីរបស់នាងឈ្មោះ ទួន-ឈាង បានទទួលមរណភាពដោយគ្រោះថ្នាក់ចរាចរ កាលពីថ្ងៃទី ២៥ មេសា ១៩៦៨ ។

— ២.០០០ រៀល ចំពោះនាង ផូ-អឿន ដែលមានកូន ៧ នាក់ក្នុងបន្ទុក នៅសង្កាត់ និងស្រុកសំពៅមាស ខេត្តកំពង់ស្ពឺ ដោយប្ដីរបស់នាងឈ្មោះសុក-មាស ជាមនុស្សពិការ ហើយក្រខ្សត់ខ្សោយផង ។-

— ១.០០០រៀល ចំពោះឈ្មោះ នា-ជិន នាង និងប្រពន្ធឈ្មោះនាង កំន់-ធូ ជាអ្នកស្រុកនៅសង្កាត់ក៏ងចាស់ ស្រុកឧត្ដុង្គ ខេត្តកំពង់ស្ពឺ ដោយកូនស្រីរបស់អ្នកទាំងពីរនាក់នេះ ឈ្មោះនាង នា ចាន់ថេង អាយុ ១៤ ឆ្នាំ ទទួលមរណភាព ដោយលង់ទឹកកាលពីថ្ងៃទី ២៩ កញ្ញា ១៩៦៨ ។

៣.០០០រ ប្រទានទៅឈ្មោះប៉ែន ស៊ុន នៅសង្កាត់តាសាល ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាជនទីទ័លក្រ ដែលមានទុក្ខ ដោយនាងអាំ ធុន ជាភរិយាត្រូវទទួលមរណភាព កាលពីថ្ងៃទី១០ សីហា ១៩៦៨ ចំនួន ៥ ថ្ងៃបន្ទាប់ពីសម្រាលកូន ដោយទុកកុមារតូចៗ ៣ នាក់នៅក្នុងបន្ទុកប្ដី ។

១.០០០រ ប្រទានទៅប្ដី-ប្រពន្ធឈ្មោះ ផាន់ សេន និងនាង សួន សយ នៅសង្កាត់ស្តុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ដែលត្រូវទទួលរងគ្រោះដោយអគ្គិភ័យ កាលពីថ្ងៃទី៣ កញ្ញា ១៩៦៨ ។

៥.០០០រ ប្រទានទៅប្ដី-ប្រពន្ធឈ្មោះ គី សុខ និងនាង ណាំ នៅសង្កាត់ស្តុក ស្រុកសំពៅមាស ដែលមានទុក្ខដោយកូនឈ្មោះ សុខ គង់ ហៅក្រង់ ជាជីវពលអាយុ ២២ ឆ្នាំ បានទទួលមរណភាព កាលពីថ្ងៃទី ១២ វិច្ឆិកា ១៩៦៨ ដោយគ្រោះថ្នាក់ចរាចរ ។

°

° °

## ព្រះអំណោយនៃសម្ដេចព្រះប្រមុខរដ្ឋសម្រាប់ស្ថាបនាជាតិ

សម្ដេចសហជីវិន ព្រះប្រមុខរដ្ឋបានទ្រង់សព្វព្រះហឫទ័យប្រោសប្រទាន ប្រាក់ បេទ្យា សា... ជាតិចំនួន៤៣១.០៥៦ ...

ជាព្រះអំណោយ សម្រាប់ឲ្យធ្វើការឆារលំអទីក្រុងសៀមរាប ប្រគល់ជូនទៅសហជីវិនអ៊ុង-គ្រពុំផ្កា ។

ៜ

## ព្រះអំណោយដ៏សំខាន់នៃ សម្ដេចឪ ប្រគេនចំពោះព្រះសង្ឃ និងវត្តនៅក្រុងខេមរភូមិន្ទ

កាលពីថ្ងៃទី ៩ មីនា ១៩៦៩ វេលាម៉ោង ១១,៣០ នាទី សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ បានទ្រង់សព្វព្រះហឫទ័យយាងទៅថ្វាយបង្គំព្រះតេជព្រះគុណមេគណខេត្តកោះកុង នៅក្នុងវត្តនៃព្រះអង្គ ឯក្រុងខេមរភូមិន្ទ ។

នៅក្នុងឱកាសនោះ សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ បានទ្រង់ប្រោសប្រទានចំពោះព្រះតេជព្រះគុណមេគណនោះ និងចំពោះព្រះសង្ឃឯទៀតៗ នូវព្រះអំណោយជាច្រើន ដូចតទៅ :

– ម៉ាស៊ីនអគ្គិសនី មួយគ្រឿង,

– ត្រីខប្រអប់ធ្វើក្នុងខែត្រកោះកុង ចំនួនបីឡាំង,

– ផ្លែឈើផ្សេងៗ,

– តែជាំនៅគិរីរម្យ និងបច្ច័យជាង ៦.០០០ រៀល សម្រាប់សេចក្ដីត្រូវការនានានៃព្រះសង្ឃ និង ១០.០០០ រៀល សម្រាប់ឲ្យស្ថាបនាសាលាបាលីបង្ហើយ ។

សម្ដេចសហជីវិនព្រះប្រមុខរដ្ឋ បានទ្រង់ទទួលព្រះភារកិច្ចស្ថាបនាមន្ទីរជាជម្រកព្រះបដិមាករបុរាណ ដែលបានរកឃើញនៅកោះកាពិ ហើយទ្រង់បានព្រះបញ្ជាទៅសហជីវិនអភិបាលខេត្ត ឲ្យក្រាលថ្មបាយក្រៀមតាមផ្លូវនានាក្នុងបរិវេណវត្ត ។

ៜ

## ព្រះអំណោយនៃសម្ដេចឪ នូវម៉ាស៊ីនភ្លើងមួយគ្រឿង ជូនសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ

កាលពីថ្ងៃសៅរ៍ទី ៨ មីនា នៅវេលាម៉ោង ១០ សហជីវិនរៀម ស៊ុផុន នាយកខុទ្ទកាល័យនៃសម្ដេចព្រះប្រមុខរដ្ឋ ជាព្រះរាជតំណាងដ៏ខ្ពង់ខ្ពស់នៃសម្ដេចសហជីវិន បានប្រគល់ម៉ាស៊ីនភ្លើងមួយគ្រឿង ដែលអាចដឹកនាំចុះឡើងបាន មានកម្លាំង ៧៥ គីឡូវ៉ាត់ ចំពោះសហជីវិនហង្ស ធុនហាក់ ជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដោយមានព្រឹទ្ធបុរសនៃមហាវិទ្យាល័យនានា និងនិស្សិតនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈចូលរួមផង ។

ៜ

ដំណាំទាំងនេះហើយ
ដែលនាំឱ្យយើងបាន
ភោគផលច្រើន

**Ce sont ces cultures qui nous rapportent**



# សកម្មភាពនៃក្រុមកាកបាទក្រហមខ្មែរ



អ្នកម្នាង ម៉ូនិក-សីហនុ ប្រធាននៃក្រុមកាកបាទក្រហមខ្មែរ

កាលពីថ្ងៃទី៧មីនា១៩៦៩គណៈប្រតិភូមួយនៃកាកបាទក្រហមខ្មែរ បានអញ្ជើញទៅមន្ទីរពេទ្យព្រះកេតុមាលា និងមន្ទីរពេទ្យយោធាព្រះមុនីវង្ស ដើម្បីជូនពរសុខសាធុការ សូមឲ្យជាសះស្បើយយ៉ាងឆាប់រហ័សចំពោះអ្នករងគ្រោះដោយអំពើនៃពួកខ្មាំង ព្រមទាំងដើម្បីប្រគល់ជូនទៅអ្នកទាំងនោះនូវអីវ៉ាន់មួយកញ្ចប់គ្នាម្នាក់ៗ ដែលមានសារុង១ កន្សែង១ ប្រាសដុសធ្មេញ១ ថ្នាំដុសធ្មេញ១ ប្រអប់ និងសាប៊ូ១ដុំផង ព្រមទាំងនូវប្រាក់ជាជំនួយសង្គ្រោះដូចតទៅ៖

— ៧០០ រៀលចំពោះឈ្មោះលន់-យ៉ន ជាភ្នាក់ងារថ្នាក់លេខ១ នៃកងរក្សាខេត្ត ដែលមកពីប៉ុស្តិ៍ទួលសង្កែ ស្រុកកំចាយមារ ខេត្តព្រៃវែង,

— ១.០០០ រៀលក្នុងម្នាក់ៗ ចំពោះនាយទោ ទិត-ព្រុំ និងភ្នាក់ងារថ្នាក់លេខ១ ផាន-ផូ ដែលមកពីរបេក ស្រុកមេមត់ ខេត្តកំពង់ចាម

— ១.០០០ រៀលចំពោះឈ្មោះញិប-ម៉ុន ពលបាលថ្នាក់លេខ ២ ដែលមកពីបាវិត ខេត្តស្វាយរៀង

— ៧០០ រៀល ចំពោះព្រឹទ្ធបាលឯក ឯក-សន ដែលមកពីបាវិត ខេត្តស្វាយរៀង

សមាសភាពនៃគណៈប្រតិភូកាកបាទក្រហមខ្មែរនេះមានដូចតទៅ :

— លោកស្រី ធូក-ផ្ញាំ ទិន-ចាន់សរុឡុង-ទូច អ៊ុត-សួង និងលោកស្រី គុយ-តៅ ព្រមទាំងសហជីវិនអនុសេនីយឯក ទេព-សុភ្ញ្ញ ។

សហជីវិនវេជ្ជបណ្ឌិត សូ-ឡុំនិងសហជីវិនអនុសេនីយឯកផាត់-មេងលី ខាងមន្ទីរពេទ្យយោធាព្រះមុនីវង្ស ក៏បានចូលរួមក្នុងពិធីប្រគល់អំណោយកាកបាទក្រហមខ្មែរនេះដែរ ។

ㆍ

នៅខេត្តកណ្តាល កាលពីថ្ងៃទី ៤មីនា ១៩៦៩ គណៈកម្មាធិការនៃកាកបាទក្រហមខ្មែរខេត្ត នៅក្រោមអធិបតីភាពនៃសហជីវិនទឹម-ដុង បានផ្តល់ជំនួយសង្គ្រោះជាប្រាក់ ២.០០០រ០០ ចំពោះគ្រួសាររបស់នាយទោគិម-វង្ស ដែលបានបាត់បង់ជីវិតដោយអំពើឈ្លានពានរបស់ អាមេរិកាំង-វៀតណាមខាងត្បូង កាលពីថ្ងៃទី ១០ មករា ១៩៦៩ នៅសង្កាត់សំពៅពូន ។

ㆍ

កាលពីថ្ងៃទី ៧ មីនា ១៩៦៩ អ្នកអង្គម្ចាស់ នរោត្តម-ចន្ទនារីវង្ស ទ្រង់បានប្រទានព្រះអំណោយជាប្រាក់ចំនួន ១០.០០០ រៀល ចំពោះអ្នកម្នាងម៉ូនិក សីហនុ ប្រធានកាកបាទក្រហមខ្មែរ សម្រាប់ឲ្យយកទៅចំណាយធ្វើការងារស្ថាបនាអគារមន្ទីរពេទ្យ នៃកាកបាទក្រហមខ្មែរ ។

ម្យ៉ាងទៀត លោកស្រី ហាក់-ម៉ុងហេង ក៏បានជូនអំណោយជាប្រាក់ ៥.០០០ រៀល ចំពោះកាកបាទក្រហមខ្មែរ សម្រាប់ឲ្យយកទៅចំណាយ ស្ថាបនាអគារ មន្ទីរពេទ្យនោះដែរ ។

ក្នុងនាមនៃកាកបាទក្រហមខ្មែរ និងក្នុងនាមនៃអ្នកម្នាង អ្នកម្នាង ម៉ូនិក សីហនុ ប្រធាន បានសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅថ្វាយអ្នកអង្គម្ចាស់ នរោត្តម-ចន្ទនារីវង្ស និងជូនលោកស្រីហាក់-ម៉ុងហេង ចំពោះសន្តានព្រះហឫទ័យ សន្តានចិត្តជ៏សប្បុរសនេះ ។

ㆍ

ក្នុងឆ្នាំ ១៩៦៩ នេះ កាកបាទក្រហមខ្មែរបានស្ថាបនាអគារមន្ទីរពេទ្យមួយ ខ្នង ដែលមានគ្រែចំនួន ៦០ នៅលើទីដីជាប់នឹងវិថីជ័យវ៌្មនទី ៧ ក្រុងភ្នំពេញ ។

អគារមន្ទីរពេទ្យនោះ នឹងត្រូវភ្ជាប់ជាអគារឧបសម្ពន្ធទៅនឹងមន្ទីរពេទ្យយោធា ព្រះមុនីវង្ស សម្រាប់ទទួលព្យាបាលអ្នករងគ្រោះដោយសង្គ្រាម ។

ㆍ

## អំណោយចំពោះក្រុមកាកបាទក្រហមខ្មែរ

កាលពីថ្ងៃទី ៦ មីនា ១៩៦៩ លោកនិងលោកស្រីបណ្ឌិតហ័ព្រហ្ម ប៉ាតេ ព្រមទាំងលោកស្រីស៊ុយ ហ្វាន ប៉ាតេនៅក្រុងក្រាកសនៃប្រទេសបារាំង បានផ្ញើមកជូនអ្នកម្នាងម៉ូនិក សីហនុ ជាប្រធាននៃក្រុមកាកបាទក្រហមខ្មែរនូវអំណោយប្រាក់ ៥.០០០ រៀល ជាវិភាគទានសម្រាប់កិច្ចការសង្គ្រោះ

ផ្សេងៗ ។

ក្នុងនាមនៃក្រុមកាកបាទក្រហមខ្មែរ និងនាមផ្ទាល់របស់អ្នកម្នាង អ្នកម្នាងម៉ូនិក សីហនុ ជាប្រធាន បានសម្ដែងជូនចំពោះសប្បុរសជនទាំងនោះ នូវអំណរគុណយ៉ាងជ្រាលជ្រៅបំផុតរបស់អ្នកម្នាង ចំពោះកាយ-វិការដ៏ថ្លៃថ្លាក្រៃលែងនេះ ។

## អំណោយជាប្រាក់ចំនួន ១៤.៤០០ រៀល នៃអ្នកម្នាង ម៉ូនិក សីហនុ ចំពោះទារិកាគារ នៅព្រះដំណាក់ឫស្សីចំការមន ភ្នំពេញ

សហជីវិនី ទិប-ម៉ម រដ្ឋមន្ត្រីក្រសួងសាធារណសុខាភិបាល សង្គមកិច្ច និងការ-ងារ បានផ្ញើទៅជូនអ្នកម្នាង ម៉ូនិក សីហនុ នូវលិខិតមួយច្បាប់ចុះថ្ងៃទី ២៨ កុម្ភៈ ១៩៦៩ មានសេចក្ដីដូចតទៅ ។

ជំរាបអ្នកម្នាង សូមទានជ្រាប,

ខ្ញុំមានសេចក្ដីរីករាយជាពន្លឹក ក្រោយពីបានទទួលប្រាក់អំណោយដ៏សប្បុរសរបស់អ្នកម្នាង ចំនួនដប់បួនពាន់បួនរយរៀល ១៤.៤០០៛០០ សម្រាប់បើកឲ្យស្ត្រីបំរើពីរនាក់ នៅទារិកាគារព្រះដំណាក់ឫស្សីចំការមន ក្នុងឆ្នាំ ១៩៦៩ ។

ទឹកចិត្តប្រកបដោយសប្បុរសធម៌របស់អ្នកម្នាងចំពោះភ័ព្វវាសនានៃទារក និងកុមារកំព្រាទាំងឡាយនេះ ពិតជាវិភាគទានមួយផ្នែកធំដល់ក្រសួងខ្ញុំ និងជាពិសេស ដល់ជាតិផង ។

ចំពោះកាយវិការដ៏ប្រពៃពោរពេញទៅដោយព្រហ្មវិហារធម៌នេះ ក្នុងនាមនៃស្ត្រីបំរើនៃទារកទាំងអស់ នៅទារិកាគារនៃក្រសួងសង្គមកិច្ច និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមសម្ដែងជូនអ្នកម្នាង នូវអំណរគុណដ៏ជ្រាលជ្រៅ និងសូមប្រសិទ្ធិពរជ័យសិរីមង្គលដ៏បវរគ្រប់ប្រការ សូមអ្នកម្នាងបានស្គាល់តែសេចក្ដីសុខ-ចំរើនរុងរឿងសមប្រកបតាមពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមអ្នកម្នាងមេត្តាទទួលសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

## ប្រាក់ចំណូលអឡូមាស កាកបាទក្រហមខ្មែរ ឆ្នាំ ១៩៦៨

ពិធីអឡូមាសសម្រាប់ឆ្នាំ ១៩៦៨ ដែលគណៈកម្មាធិការកាកបាទក្រហមខ្មែរ ខេត្តក្រចេះ បានរៀបចំធ្វើឡើងក្រោមអធិបតីភាពនៃសហជីវិន សុិន-បុប្ផាគោនោះ បានប្រាក់ចំណូលទាំងអស់ចំនួន ៤៤.៩៤១ រៀល ជាវិភាគទានស្ម័គ្រចិត្តរបស់បុគ្គលិកនៃក្រុមរាជ-ការសាលាស្រុក និងគ្រឹះស្ថានសិក្សាដូចតទៅ :

— សាលាបឋមសិក្សា ៥.៥៣៣៛០០
— វិទ្យាល័យព្រះកុសុមៈ ៧៦៧៛០០
— ស្នងការដ្ឋានក្រុមព្រះនគរបាលក្រុង ១៧.២៣២៛០០
— ស្នងការដ្ឋានក្រុមព្រះនគរបាលជាតិ ២.២៧៥៛០០
— ការិយាល័យអាករ ១.៥៧៥៛០០
— សាលាស្រុកក្រចេះ ៣.៣២៥៛០០
— សាលាស្រុកស្នួល ៣.៦៥៩៛០០
— សាលាស្រុកឆ្លូង ៥.៤៦២៛០០
— សាលាស្រុកព្រះប្រសប់ ៣.៤១៥៛០០
— សាលាស្រុកសំបូរ ៥.៦៩៨៛០០

៤៩.៩៤១៛០០



# មានអ្វីប្លែក នៅរដ្ឋសភា



សហជីវិន គុយ-ពៅ

កាលពីថ្ងៃទី ២១ ខែកុម្ភៈ គ.ស.១៩៦៩ វេលាម៉ោង៩ព្រឹក រដ្ឋសភាបានបើកសម័យប្រជុំក្រោមអធិបតីភាពនៃសហជីវិនឡុង-បូរេត ប្រធានសម័យប្រជុំ ដើម្បីពិនិត្យនូវសេចក្ដីព្រាងច្បាប់ស្ដីពីការអនុញ្ញាតឲ្យបើកឥណទានបណ្ដោះអាសន្នមុនការអនុមតិថវិកាជាតិការិយបរិច្ឆេទ ១៩៦៩ សម្រាប់ខែកុម្ភៈ

ចំពោះបញ្ហាខាងលើនេះ រដ្ឋសភាបានពិភាក្សាអស់ពេលយ៉ាងយូរក៏បានអនុមតិតាមសេចក្ដីព្រាងរបស់រដ្ឋាភិបាល ដែលមានសេចក្ដីដូចខាងក្រោមនេះ៖

« ច្បាប់អនុញ្ញាត ឱ្យបើកឥណទានបណ្ដោះអាសន្នមុនការអនុមតិ ថវិកាជាតិការិយបរិច្ឆេទ ១៩៦៩ »

មាត្រា ១ : មុននឹងថវិកាជាតិ ការិយ-បរិច្ឆេទ ១៩៦៩ បានអនុមតិ ត្រូវបើកឥណ-ទានបណ្ដោះអាសន្នមួយភាគដប់ពីរ "១/១២" នៃឥណទានដែលចុះក្នុងថវិកាជាតិ ការិយបរិច្ឆេទ១៩៦៨ សំរាប់ចំណាយអចិន្ត្រៃយ៍និងចាំបាច់នៃខែ កុម្ភៈ គ-ស ១៩៦៩ ដែលមានចំនួនសរុប ប្រាំរយប៉ែតសិបបីលានបីរយសាមសិបពាន់រៀល "៥៨៣.៣៣០.០០០៛" ។

ឥណទានទាំងនេះ ត្រូវបានបែងចែកតាមក្រសួងដូចតទៅ៖

| | |
|---|---|
| — រដ្ឋសភា | ២.២៨២.១០០៛ |
| — ក្រុមប្រឹក្សាព្រះរាជាណាចក្រ | ៥៩៣.៨០០៛ |
| — ទីស្ដីការនាយករដ្ឋមន្ត្រី និងកីឡា | ៦.០៩៤.២០០៛ |
| — ក្រសួង ការងារ | ៨១៨.០០០៛ |
| — ក្រសួង សង្គមកិច្ច | ១.៥២៤.៥០០៛ |
| — ក្រសួង ផែនការ | ១.២១៨.៩០០៛ |
| — ក្រសួង ឧស្សាហកម្ម | ៥៨០.២០០៛ |
| — ក្រសួង ប្រៃសណីយ៍និងទូរគមនាគមន៍ | ៦.២៤៧.៤០០៛ |
| — ក្រសួង ការបរទេស | ១០.៤០៩.៨០០៛ |
| — ក្រសួង មហាផ្ទៃ | ១០.៥៣២.២០០៛ |
| — ក្រសួង សន្តិសុខជាតិ | ៦.៤២៨.៦០០៛ |
| — ក្រសួង ការពារលើផ្ទៃប្រទេស | ៣៣.៨៥១.១០០៛ |
| — ក្រសួង ឃោសនាការ | ៤.៦២៩.០០០៛ |
| — ក្រសួងទេសចរណ៍ | ១.៣៤៤.៤០០៛ |
| — ក្រសួង អប់រំជាតិ | ១២៦.៩៦៦.៦០០៛ |
| — ក្រសួង ពាណិជ្ជកម្ម | ៨៦២.៩៥០៛ |
| — ក្រសួង កសិកម្ម | ២០.០៥៦.៧៥០៛ |
| — ក្រសួង យុត្តិធម៌ | ៣.៥៧៤.០០០៛ |
| — ក្រសួង ធម្មការ | ១.៦៣០.៨០០៛ |
| — ក្រសួង សាធារណសុខាភិបាល | ២៩.៥៨០.៩០០៛ |
| — ក្រសួង សាធារណការ | ១៨.៨៥៨.៨០០៛ |
| — ក្រសួង ហិរញ្ញវត្ថុ | ១៥១.៨៣៨.០០០៛ |
| — ក្រសួង ការពារប្រទេស | ១៤៣.៤០៧.០០០៛ |
| | ៥៨៣.៣៣០.០០០៛ |

មាត្រា ២: ច្បាប់នេះត្រូវប្រកាសទុកជាការប្រញាប់ ។

កាលពីថ្ងៃទី ២៥ ខែកុម្ភៈ គ.ស.១៩៦៩ វេលាម៉ោង៩ព្រឹក រដ្ឋសភាបានបើកសម័យប្រជុំក្រោមអធិបតីភាពនៃឯកឧត្ដមចេង-ហេង ប្រធានរដ្ឋសភា ដើម្បីពិភាក្សានូវសេចក្ដីព្រាងច្បាប់ពីរ គឺ៖

១— ការកំរិតបៀវត្សប្រចាំឆ្នាំ តាមលក្ខន្តិកៈនៃនាយរាជតម្រួត ។

សេចក្ដីព្រាងច្បាប់ទី១នេះ រដ្ឋសភាបានពិភាក្សាជជែកពិភាក្សាអស់ពេលយ៉ាងយូរ ក៏បានអនុម័តតាមសេចក្ដីកែសម្រួលនៃគណៈកម្មការ ដូចមានខាងក្រោមនេះ៖

## ច្បាប់ទី ១

### អត្ថបទនៃសេចក្ដីព្រាងច្បាប់ ក្រោយដែលគណៈកម្មការបានកែសម្រួល

« ច្បាប់ស្ដីពីការកំរិតបៀវត្សប្រចាំឆ្នាំតាមលក្ខន្តិកៈនៃនាយរាជតម្រួត »

មាត្រាមួយ— តារាងបៀវត្សប្រចាំឆ្នាំតាមលក្ខន្តិកៈ នៃនាយរាជតម្រួតដែលបានកំណត់ដោយព្រះរាជក្រមលេខ ៨១២-ន.ស ចុះថ្ងៃទី ៨ ខែ កញ្ញា គ.ស. ១៩៥៣ កែប្រែដោយព្រះរាជក្រមលេខ ៨៣២ន.ស ចុះថ្ងៃ ១៨ ខែ ធ្នូ គ.ស. ១៩៥៣ កំរិតបៀវត្សតាមលក្ខន្តិកៈប្រចាំឆ្នាំ បុគ្គលិកគ្រប់ទំណូករាជការក្នុងព្រះរាជាណាចក្រ ត្រូវកែប្រែ ហើយត្រូវយកតារាងតែមួយដូចតទៅនេះ មកជំនួសវិញ ។

ង— កងរាជតម្រួត

១៦— ក្របខ័ណ្ឌនៃនាយ រាជតម្រួត

| ឋានន្តរសក្តិនិងលំដាប់ថ្នាក់ | សន្ទស្សន៍ | បៀវត្សប្រចាំឆ្នាំ |
|---|---|---|
| វរសេនីយឯកជាន់ទី ២ | ៦៦០ | ៩៩.០០០៛ |
| វរសេនីយឯកជាន់ទី ១ | ៦១៤ | ៩២.១០០៛ |
| វរសេនីយទោជាន់ទី ២ | ៥៧២ | ៨៥.៨០០៛ |
| វរសេនីយទោជាន់ទី ១ | ៥៣០ | ៧៩.៥០០៛ |
| វរសេនីយត្រីជាន់ទី ៣ | ៤៩០ | ៧៣.៥០០៛ |
| វរសេនីយត្រីជាន់ទី ២ | ៤៥៤ | ៦៨.១០០៛ |
| វរសេនីយត្រីជាន់ទី ១ | ៤២០ | ៦៣.០០០៛ |
| អនុសេនីយឯកជាន់ទី៣ | ៣៨៨ | ៥៨.២០០៛ |
| អនុសេនីយឯកជាន់ទី២ | ៣៥៦ | ៥៣.៤០០៛ |
| អនុសេនីយឯកជាន់ទី ១ | ៣២៨ | ៤៩.២០០៛ |
| អនុសេនីយទោជាន់ទី២ | ៣០០ | ៤៥.០០០៛ |
| អនុសេនីយទោជាន់ទី ១ | ២៧៤ | ៤១.១០០៛ |
| អនុសេនីយត្រី | ២៤៨ | ៣៧.២០០៛ |

មាត្រា២– បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

២– ការកំរិតបាត់ថ្នាក់សន្ទស្សន៍ នៃបុគ្គលិកនៃនាយរាជតម្រួត ។

សេចក្តីព្រាងច្បាប់នេះ រដ្ឋសភាបាន អនុម័តតាមសេចក្តីកែសម្រួល របស់គណៈកម្មការ ដូចមានខាងក្រោមនេះ៖

## ច្បាប់ទី២

### អត្ថបទនៃសេចក្តីព្រាងច្បាប់ ក្រោយដែលគណៈកម្មការបានកែសម្រួល

"ច្បាប់ស្តីពីការកំរិតបាត់ថ្នាក់សន្ទស្សន៍នៃនាយរាជតម្រួត"

មាត្រាមួយ.– ការបាត់ថ្នាក់សន្ទស្សន៍នៃនាយរាជតម្រួត ដែលមានចែងនៅក្នុងឧបសម្ពន្ធ ទី១ នៃព្រះរាជក្រម លេខ ១៨០៨ ន-ស- ចុះថ្ងៃទី ២៦ខែ សីហា គ.ស.១៩៥៣ ស្តីពីការបាត់ថ្នាក់ សន្ទស្សន៍ ក្នុងក្របខ័ណ្ឌបុគ្គលិកនៃមន្ត្រីរដ្ឋបាលក្នុងព្រះរាជាណាចក្រ ដែលបំពេញដោយព្រះរាជក្រមលេខ ៨៣១-ន-ស. ចុះថ្ងៃទី ១៨ ខែ ធ្នូ គ.ស ១៩៥៣ ត្រូវកែប្រែ ហើយត្រូវយកការបាត់ថ្នាក់តែមួយដូចតទៅមកជំនួសវិញ ។

#### កងរាជតម្រួត

| ឋានន្តរស័ក្តិ ឬ មុខងារ | សន្ទស្សន៍ | សេចក្តីផ្សេងៗ |
|---|---|---|
| ង– កងរាជតម្រួត | | |
| ១៦– ក្របខ័ណ្ឌនៃនាយរាជតម្រួត | ២៤៨.៦៦០ | |

មាត្រា២.– បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

o

o o

កាលពីថ្ងៃទី ២៦ ខែកុម្ភៈ គ.ស. ១៩៦៩ វេលាម៉ោង១០ព្រឹក រដ្ឋសភាបានបើកសម័យប្រជុំ ក្រោមអធិបតីភាព នៃសហជីវិន ឡុង-បូរេត ជាប្រធានសម័យប្រជុំ ដើម្បីពិនិត្យនិងពិភាក្សានូវសេចក្តីព្រាងច្បាប់ ស្តីពីផែនការ ៥ ឆ្នាំលើកទី២សំរាប់ឆ្នាំ១៩៦៨-១៩៧២ ហើយនិងពីល័ក្ខខ័ណ្ឌ ក្នុងការចាប់ផ្តើមអនុវត្តនូវច្បាប់នេះ ។

ចំពោះសេចក្តីព្រាងច្បាប់នេះ សភាបានពិភាក្សា ចំនួន៣លើកទើបបានសម្រេចតាម សេចក្តីព្រាងកែសម្រួលរបស់គណៈកម្មការ ។

យើងសូមអភ័យទោសដោយពុំបានចុះផ្សាយជូនទាំងស្រុង ព្រោះអត្ថបទវែងពេក យើងគ្រាន់តែបញ្ជាក់គោលធំៗថា ផែនការ ៥ ឆ្នាំលើក ទី ២ សម្រាប់ឆ្នាំ ១៩៦៨-១៩៧២ នេះមាននាមថា **ផែនការព្រះនរោត្តម សុរាម្រិតដែលនឹងត្រូវកសាង អាជីវកសិកម្ម សហគ្រាស ទេសចរណ៍... ។**

**គុយ-ពៅ**




សូមគោរពមិត្តបារាំងដែលគ្មានពាក្យសត្យ
Salut, la France « perfide »!



សហជីវិន ភី-ធៀនឡាយ

# សំបុត្រកំណើតនៃកូនចិញ្ចឹម

តាមសំបុត្រចុះថ្ងៃទី ២៣ ធ្នូ ឆ្នាំ ១៩៦៨ និស្សិត ជា ប្រេម នៅមហាវិទ្យាល័យខាងសិល្បៈនិងមុខរបរ ក្រុងភ្នំពេញ បានស្នើថា:

"ឈ្មោះ (ក) ជាកូនចិញ្ចឹមរបស់ឈ្មោះ (ខ) ហើយឈ្មោះ(ខ)នេះបានចុះបញ្ជីជាតិឲ្យឈ្មោះ (ក) ដាក់ថាជាកូនបង្កើតរបស់ខ្លួនគឺ (ខ-ក) ចុះតាំងពីកុមារ (ក) នៅតូចៗម្ល៉េះ ។ តាមការណ៍ពិតឈ្មោះ (ក) ជាកូនរបស់ឈ្មោះ(គ)ដែលឈ្មោះ(គ)ឲ្យទៅឈ្មោះ(ខ) ចិញ្ចឹមធ្វើជាកូន ។ ក្រោយមកឈ្មោះ(ក)ដឹងថា ការចុះដាក់ជាកូនបង្កើតរបស់ឈ្មោះ (ខ) នេះខុសនឹងសេចក្ដីពិតផង មិនត្រឹមត្រូវតាម [illegible]ប់ ដែលស្ដីពីរឿងសូមកូនគេចិញ្ចឹមផង ឈ្មោះ(ក)ចង់ប្ដឹងសូមឲ្យកែបញ្ជីជាតិរបស់ខ្លួនឲ្យត្រូវតាមរឿងពិត គឺសូមឲ្យដាក់ថា (គ-ក) វិញ" ។ ហេតុនេះនិស្សិតជា-ប្រេម សូមសួរដូចតទៅ :

**សំនួរទី ១**– ឈ្មោះ (ក) មានអំណាចប្ដឹងសូមកែតម្រូវបញ្ជីជាតិរបស់ខ្លួនបានឬទេ? បើបានតើត្រូវប្ដឹងទៅក្រសួងណា ទៅសាលាស្រុកឬសាលាដំបូង?

**ឆ្លើយ.**– ឈ្មោះ (ក) អាចប្ដឹងសូមឲ្យកែសំបុត្របញ្ជីជាតិឲ្យត្រូវទៅតាមសេចក្ដីពិតបាន ប៉ុន្តែក្រោយពីកែហើយឈ្មោះ(ក)អស់មានលក្ខណៈជាកូនចិញ្ចឹម របស់ឈ្មោះ (ខ) ចាប់តាំងពីថ្ងៃដែលកែនោះតទៅ ។ ការប្ដឹងសូមកែ ត្រូវប្ដឹងទៅសាលាដំបូង ប៉ែកអាជ្ញា មិនមែនប្ដឹងទៅសាលាលហុស្រុកទេ ។ បើការដែលចុះដាក់ជាកូនរបស់ឈ្មោះ(ខ)បង្កើតនេះ គ្មានបណ្ដាលឲ្យមានការខូចខាតទេ តុលាការត្រូវផ្ដន្ទាទោសឈ្មោះ (ខ) ដែលប្ដឹងឲ្យចុះកំណើតនេះខុសពីសេចក្ដីពិត ដាក់គុកពី ៦ ថ្ងៃ ទៅ ៣ ខែ និងពិន័យជាប្រាក់ ពី១០៛ ទៅ ១០០៛០០ ឬដាក់តែទោសណាមួយមុខក៏បាន និងត្រូវបង្គាប់ឲ្យកែប្រែសំបុត្របញ្ជីជាតិឲ្យបានត្រឹមត្រូវតាមសេចក្ដីពិតឡើង ។ បើការដែលចុះដាក់ថាជាកូនរបស់ឈ្មោះ (ខ) បណ្ដាលឲ្យមានការខូចខាត ដូចជាទៅដណ្ដើមយកមត៌ករបស់ឈ្មោះ (ខ) បណ្ដាលឲ្យកូនក្មួយរបស់ឈ្មោះ (ខ) ខូចខាតខានបានមត៌កនេះ ឈ្មោះ (ខ) ជាអ្នកប្ដឹងក្លែង ខុសនឹងសេចក្ដីពិត និងឈ្មោះ (ក) ជាអ្នកប្រើសំបុត្រកំណើតក្លែងនោះ ត្រូវមានទោសឧក្រិដ្ឋថ្នាក់ទី ១ តាមបញ្ញត្តិមាត្រា ៣១៧ក្រមព្រហ្មទណ្ឌ ។ លុះដាច់ទោសនេះហើយ សាលាឧក្រិដ្ឋត្រូវបង្គាប់ឲ្យកែប្រែសំបុត្រកំណើតនេះឲ្យបានត្រឹមត្រូវទៅតាមសេចក្ដីពិតបាន ។ ចំពោះការកែប្រែនេះ សាលាខាងប៉ែកអាជ្ញាដែលដាក់ទោស អាចសំរេចឲ្យកែតម្រូវទៅតាមសេចក្ដីពិតដោយខ្លួនឯងបាន ។ បើសាលាប៉ែកអាជ្ញាពុំបានសំរេចឲ្យកែប្រែដោយខ្លួនឯងទេ អ្នកប្ដឹងអាចយករឿងនេះព្រមទាំងសាលក្រមដែលដាក់ទោសទៅប្ដឹង សូមឲ្យសាលារដ្ឋប្បវេណីកែប្រែឲ្យបានតាមបញ្ញត្តិមាត្រា ១៩៣ ក្រមពិតាក្យរដ្ឋប្បវេណី ។

**សំនួរទី ២**– តើអ្នកប្ដឹងត្រូវបំពេញលក្ខណៈដូចម្ដេចខ្លះចំពោះការសុំកែនេះ?

**ឆ្លើយ**– អ្នកប្ដឹងត្រូវធ្វើពាក្យមួយ រាយរាប់រឿងតាមដំណើរ ហើយដាក់ថាសូមកែឲ្យត្រូវតាមសេចក្ដីពិត ។ ពាក្យនេះ ត្រូវបិទតែមប្រ៍ ១០ រៀល ត្រូវភ្ជាស់សំបុត្រកំណើតដែលសុំកែនោះទៅជាមួយផង ហើយយកទៅឡើងដល់ព្រះរាជអាជ្ញា អមសាលាដំបូងក៏បាន ទៅឡើងដល់លោកចាងហ្វាងសាលាដំបូងក៏បាន ។

**សំនួរទី៣**–នៅពេលសុំកែ តើឈ្មោះ (ក) អាចសុំផ្លាស់ឈ្មោះចាស់ចេញ គឺផ្លាស់ (ក) ដាក់ជា (ង)វិញ ឬក៏សុំបន្ថែមឈ្មោះខ្លួនឲ្យវែងបន្តិចបានឬទេ ?

**ឆ្លើយ**– ឈ្មោះដើមដូចជាឈ្មោះ (ក) នេះ ពុំមែនខុសពីសេចក្ដីពិតទេ ជាឈ្មោះដែលត្រឹមត្រូវ ជាសញ្ញាយើហៅសំរាប់មនុស្សម្នាក់ៗ ពុំអាចសុំកែប្រែមកដាក់ឈ្មោះអ្វីផ្សេងទៀតបានឡើយ ។

ការប្ដឹងសូមកែឈ្មោះ ឬបន្ថែមឈ្មោះផ្ទាល់ខ្លួន ជារឿង១ដោយឡែកផ្សេងពីការប្ដឹងឲ្យផ្លាស់ឈ្មោះឪពុក រឈ្មោះនាមត្រកូលឲ្យត្រូវតាមសេចក្ដីពិត ។

បើឈ្មោះ (ក) ចង់ប្តូរឈ្មោះ លុះតែឈ្មោះនោះអាសអាភាស ដូចជាឈ្មោះ (អាចម៍) ឬឈ្មោះសត្វដែលអាក្រក់ ដូចជា (ឆ្កែ) ឬឈ្មោះដូចជន់ក្បត់ជាតិ ដូចជាដាក់ថា (ដាបឈ្លួន) ជាដើម ។ បើឈ្មោះអាក្រក់ដូច្នេះ អ្នកអាចសូមផ្លាស់ឈ្មោះបាន តែត្រូវធ្វើពាក្យសុំទៅព្រះមហាក្សត្រ ឬសម្តេចព្រះប្រមុខរដ្ឋ ព្រះអង្គទ្រង់សម្រេចប្រទានតាមសុំ ឬមិនប្រទានតាមព្រះរាជក្រឹត្យ ។ ក្រៅពីឈ្មោះអាក្រក់ ដូចជាឈ្មោះ (ផ្កា) កែដាក់ជាឈ្មោះ (ផ្លែ) ឈ្មោះ (ឃ្មុំ) ។ល។ ដែលមិនអាក្រក់ទេនោះ ច្បាប់ពុំអនុញ្ញាតឲ្យកែបានទេ ។

បើឈ្មោះ (ក) ចង់បន្ថែមឈ្មោះ អាចប្តឹងសូមតាមសាលក្រម សាលាដំបូងបាន តែត្រូវថែមពាក្យ "ហៅ" គឺជាឈ្មោះ (ក) ត្រូវនៅដូចដើមដដែល គ្រាន់តែថែមថា (ក) ហៅ (ង) បើបន្ថែមដូច្នេះ សាលាដំបូងអាចសម្រេចតាមសាលក្រមឲ្យបាន តែដូចយើងបានបញ្ជាក់មកហើយ ថារឿងសូមបន្ថែមឈ្មោះនេះ ជារឿងផ្សេងពីរឿងសូមកែឈ្មោះឪពុក និងឈ្មោះនាមត្រកូល ក្នុងសំបុត្រកំណើតដែលខុសពីការណ៍ពិត ។ បើចង់សូមបន្ថែមឈ្មោះ ត្រូវធ្វើពាក្យមួយប្តឹងសុំផ្សេងដោយឡែក ។

**សំនួរទី ៤–** បើសុំកែបានហើយ តើឈ្មោះ (ក) អាចសុំកែឈ្មោះក្នុងសញ្ញាប័ត្រដែលមានរួចមកហើយបានឬទេ? សូមរបៀបណា ?

**ឆ្លើយ –** សាលក្រមរបស់តុលាការដែលសម្រេចឲ្យកែ ត្រូវបង្គាប់ឲ្យកែសំបុត្រកំណើតឲ្យបានត្រឹមត្រូវ តាមការណ៍ពិតផង និងបង្គាប់ឲ្យកែលិខិតទាំងឡាយណា ដែលកើតពីលិខិតនោះឲ្យបានស្របទៅតាមលិខិតថ្មីដែលកែប្រែហើយនោះផង ។ លុះបានសាលក្រមនេះមក សាមីខ្លួនយកសាលក្រមនេះ និង ពាក្យមួយឡើងទៅសុំដល់ក្រសួងដែលចេញសញ្ញាប័ត្រឲ្យ ក្រសួងក៏អាចកែសញ្ញាប័ត្រនោះឲ្យស្របតាមសំបុត្រកំណើតកែប្រែនិងតាមបង្គាប់នៃសាលក្រមតុលាការនោះផង ។

**សំនួរទី ៥ -** បើឈ្មោះ (ក) ចេញធ្វើការដោយពុំបានប្តឹងកែបញ្ជីជាតិរបស់ខ្លួនឲ្យត្រូវតាមពិតទេ តើឈ្មោះ (ក) ត្រូវមានទោសឬទេ ? មានត្រឹមថ្នាក់ណា ?

**ឆ្លើយ–** តាមច្បាប់ អ្នកប្រើលិខិតក្លែងត្រូវមានទោសដូចគ្នានិងអ្នកប្រព្រឹត្តក្លែងនោះដែរ ។ ក្នុងករណីនេះឈ្មោះ (ក) ដែលប្រើសំបុត្រកំណើតក្លែងខុសពីសេចក្តីពិតត្រូវមានទោសដែលចង្អុលក្នុងមាត្រា ៤៥ ក្រមរដ្ឋប្បវេណី បើកាលណាគ្មានធ្វើឲ្យខូចខាតអ្វីទេ ត្រូវមានទោសដូចកំរិតក្នុងមាត្រា ៣១៧ ក្រមព្រហ្មទណ្ឌ បើកាលណាការប្រើនេះបណ្តាលឲ្យមានការខូចខាត ដូចយើងបានបញ្ជាក់ក្នុងចម្លើយទី ១ ស្រាប់ ។

**សំនួរទី ៦–** តើអាចប្តឹងសុំកែតម្រូវបានឬទេ នៅពេលមានមុខងារក្នុងរាជការរួចហើយ ? បើមិនបានពីព្រោះអ្វី ?

**ឆ្លើយ–** ឲ្យតែខុសពីសេចក្តីពិត នៅពេលណា ក៏អាចប្តឹងសុំកែតម្រូវឲ្យត្រូវទៅតាមសេចក្តីពិតបានដែរ តែសុំកុំភ្លេចដាក់ក្នុងពាក្យសុំដល់តុលាការ សុំឲ្យកែសំបុត្រកំណើតនោះផង និងសូមឲ្យកែលិខិតផ្សេងៗដែលកើតពីសំបុត្រកំណើតនោះឲ្យបានត្រឹមត្រូវតាមសេចក្តីពិតផង ពីព្រោះក្នុងរឿងរដ្ឋប្បវេណី យើងសុំត្រង់ណាទើបតុលាការសំរេចត្រង់នោះឲ្យ កន្លែងណាដែលយើងមិនសុំតុលាការមិនសំរេចទេ ។

សម្តេចឪ៖ «បើមកលើកក្រោយ មកជាមិត្ត កុំមកជាចោរ...»
Samdech Euv : «REVENEZ EN AMIS et non en VOLEURS...»




តី-ឆៀនឆ

(តពីលេខ មុន)



សហជីវិន ហ៊ែល ស៊ុំផា

# ថ្មរាំ ទឹករាំ ទៀត

នៅស្រុកបារាំង តាមដងភ្នំជាតិកំពោរ មានរូបថ្មល្អៗណាស់ ។ មានរូបខ្លះនោះ ប្រវែងដល់ទៅ១២០ ម៉ែត្រ ហើយ ស្តាឡាក់ **ទីត-ស្តាឡាក់មីត** គេដុះច្រើនប្រាំងដូចព្រៃព្រឹក្សា ។ ខ្លះមានកំពស់ដល់ទៅ ៣០ ម៉ែត្រផង ។ បើនៅអាមេរិកផង គេមិនខ្វះរូបថ្មល្អៗមើលទេ ។ **នៅស្រុកយើងក្រសួងទេសចរណ៍ គួររៀបចំឱ្យបានល្អដូចគេគ្រាន់បានចម្រើនថវិកាជាតិខ្លះផង ។**

សូមមេត្តាកុំបណ្តោយឲ្យគេកាប់ថ្មនៅក្នុងរូងនេះទៅលក់ឲ្យសហគ្រិនឲ្យសោះ ។

នេះគឺ **ថ្មរាំ** ពិត ហើយបើយើងទៅមើល ក៏គ្មានយក្សឯណាស៊ីមនុស្សដូចក្នុងរឿងព្រេងដែរ ។

និយាយពី **ទឹករាំ** វិញ ទឹកនេះគ្មាននៅស្រុកយើងទេ គឺមានតែនៅស្រុកយក្ស ។ យក្សសព្វថ្ងៃនេះមិនមែនស៊ីមនុស្សដូចពីដើមទេ យើងអាចទៅមើលបានដោយសេរី ។

**នៅភ្នំពេញ** យើងគ្រាន់តែឃើញមាន **ទឹកបាញ់ឡើងលើដោយកម្លាំងយន្ត** នៅមុខវត្តបទុមវតីនោះ យើងថាសម្បើមណាស់ទៅហើយៗ យើងថា **ហ្នឹងហើយទឹករាំ ។** ប៉ុន្តែ **បើយើងទៅស្រុកគេវិញ** ដូចជានៅសហរដ្ឋអាមេរិកនិងប្រទេសអង់គ្លេសជាដើម យើងនឹងឃើញមាននៅកន្លែងខ្លះនោះ **ទឹកផុសចេញពីក្នុងដីមក កំពស់រាប់រយម៉ែត្រ បែកជាផ្សែង ហើយបាញ់ត្រង់ទៅលើមេឃ ហើយធ្លាក់មកដល់ក្នុងអាងមួយ** ដោយមិនហូរទៅណាទេ ។

ទឹកដែលផុសចេញនេះ គ្មានគ្រឿងយន្តឯណាជុំទេ គឺមកពីធម្មជាតិពិតៗ ។ យើងត្រូវដឹងថា **នៅខាងក្រោមដីមានដុំថ្មខ្លះក្តៅដូចរងើកភ្លើង** ហើយស្ថិតនៅមិនជ្រៅពីផ្ទៃដីប៉ុន្មានទេ ។ សន្ទាប់ថ្មដែលនៅពីលើដុំថ្មក្តៅនេះ បែកក្រហែងបណ្តាលឲ្យ **ទឹកដែលនៅលើផ្ទៃដីហូរតាមក្រហែងនោះចូលទៅប៉ះដុំថ្មក្តៅនោះ ។** គឺដោយមានទឹកមកតាក់លើដុំថ្មក្តៅនេះហើយដែលបណ្តាលឲ្យថ្មនេះដាក់ទឹកឲ្យបាញ់ទៅលើអាកាស ។ បើរន្ធដែលទឹកបាញ់ទៅនេះរាងតូច ទឹកនោះក៏បាញ់ចេញកាន់តែខ្លាំង ហើយបែកទៅជាចម្ហាយទឹក រេរាំនៅលើអាកាសយ៉ាងសម្បើមអស្ចារ្យ ។ នៅនឹងមាត់រន្ធនេះ មានអាងមួយធំល្មម កើតដោយកម្លាំងទឹកដែលធ្លាក់មកវិញ ដោយចំនួនច្រើន ហើយយូរៗយូរឆ្នាំផង ។ **ទឹកដែលដក់នៅក្នុងអាងនេះ ហូរចូលទៅក្នុងដីប៉ះថ្មក្តៅៗក៏បាញ់បញ្ចេញមកវិញទៀត** ។ នៅក្នុងអាងនេះ **មានថ្មដុះជាស្តាឡាក់ទីត-ស្តាឡាក់មិត** ដូចជាក្នុងរូងថ្មឯទៀតដែរ ហើយទឹកដែលធ្លាក់ពីអាកាសមកដក់ក្នុងអាងនេះក៏នៅតែក្តៅដល់ទៅ ៤៦ អង្សាដែរ ។ អ្នកទេសចរ



ចូលចិត្តទៅមើល ហើយឈរជិតអាងនោះ ដោយគ្មានប្រទះគ្រោះថ្នាក់អ្វីទេ ។

នៅស្រុកគេមិនមែនមានថ្មរាំទឹករាំ តែរបៀបប៉ុណ្ណេះទេ ។ គេមានកន្លែងជាច្រើនទៀត ដែលទឹកស៊ីដីស៊ីថ្ម ឲ្យបានជាទស្សនីយភាពយ៉ាងអស្ចារ្យ គួរឲ្យចង់ទៅមើលជាកំសាន្តផង ជាប្រយោជន៍ផង ព្រោះនៅក្នុងសកលលោកនេះ វត្ថុនិងទីកន្លែងសម្បើមអស្ចារ្យទាំងនោះមានដោយកម្រណាស់ ។

សូមជ្រាបថា ទឹក ដូចជាទឹកសមុទ្រ ទឹកទន្លេ បឹងបួរ ទឹកភ្លៀង ទឹកកក និងសន្សើមកកជាដើម **អាចមានសកម្មទៅលើផែនដីខ្លាំងណាស់**ដែរ ។ វា**អាចបំផ្លាញក៏បាន អាចស្ថាបនាក៏បាន ។ ស្ថាបនា** គឺដូចជានាំយកដីល្បប់ចាក់នៅនឹងមាត់ពាម - ទន្លេជាដើម បណ្ដាលឲ្យដុះផ្ទៃដីលយចូលទៅក្នុងផ្ទៃទឹក ។ **បំផ្លាញ** គឺដូចជាវាកកេរថ្ម កកាយដី ឲ្យទៅជាជ្រលង ឬជាអូរ ។ វាអាចធ្វើយ៉ាងនេះ ព្រោះមានដីខ្សាច់ឬកំទេចថ្មនៅក្នុងទឹកនោះ សម្រាប់ឲ្យវាប្រើប្រាស់ ហាក់ដូចជាវាមានធ្មេញ ឬមានចបប៉ែលជីកដែរ ។ ជីកនោះបន្តិចបន្តួចណាស់ មើលមិនឃើញទេ ប៉ុន្តែយូរទៅជាច្រើនឆ្នាំ ឬច្រើនសតវត្សទៅវាបង្កបង្កើតនិងបំផ្លាញអស់ប៉ុណ្ណាទៅ? បើយើងទៅមើលនៅស្រុកគេ ដូចជានៅអឺរ៉ុបសហរដ្ឋអាមេរិកជាដើម យើងនឹងឃើញមានកន្លែងខ្លះនោះ **ជ្រោះក្លាយទៅជាស្ទឹងៗក្លាយជាទន្លេហូរកាត់ខ្នងភ្នំមួយ** ហើយ**ជីកកកាយដុំថ្មណាដែលផុយៗ** ហើយ**ទុកដុំថ្មណាដែលរឹងៗ**ឲ្យស្ថិតនៅដដែល ។ ដូច្នេះ ក្នុងទាំងមូលបែរទៅជាមាន**ទិដ្ឋភាពយ៉ាងចម្លែក** ហាក់ដូចជាទីក្រុងមួយ ដែលមានសុទ្ធតែគុហាធំសម្បើមៗ ។ កន្លែងដែលធំបំផុតនោះ




ទឹកធ្លាក់ បាក់ប្រាំងទៅតាមដងទន្លេ




មានបណ្ដោយដល់ទៅ ៤០០ គ.ម ហើយជម្រៅមានដល់ពី ១០០០ ទៅ ២០០០ ម. ដីមានពណ៌ក្រហម និងខ្មៅជាស្រទាប់ៗ ។ នៅទីនេះគេរើសបានសំណាកសត្វ និងរុក្ខជាតិគ្រប់យ៉ាង ដែលកើតក្នុងលោកនេះតាំងពីច្រើនសតវត្សមកហើយ ។

បើគ្រាន់តែ **ទន្លេស៊ីដីធម្មតាទេ** នោះមាននៅច្រើនកន្លែងណាស់ ។ ច្រើនបំផុតគឺនៅស្រុកអាហ្វ្រិក ។ នៅអាមេរិកក៏មានសម្បើមណាស់ដែរ ។ នៅកន្លែងទាំងនោះ **ទន្លេហូរកាត់ដីដែលមានជាតិថ្ម** ។ ដូច្នេះហើយ ទឹកទន្លេនេះមិនបណ្ដាលឲ្យសឹកបាតទឹកនេះរហូតទេ ។ វាហូរធម្មតាតាំងពីលើមក ប៉ុន្តែលុះមកដល់ប្រាំងសមុទ្រ **ទឹកនោះធ្លាក់ទៅក្នុងសមុទ្រ ដោយបេះដីប្រាំងនេះឱ្យធ្លាក់ទាំងដុំៗ** លុះគ្រាតែ **ប្រាំងសមុទ្រនេះឆែបបណ្ដោយទៅតាមដងទន្លេ កាន់តែឆ្ងាយទៅៗ ។** មានទន្លេខ្លះវាស៊ីដីថ្មនេះឲ្យឆែបអស់ ១១គ.ម. ក្នុង ៦.០០០ ឆ្នាំ ទឹកដែលធ្លាក់កំពស់ ៦០ម. បន្លឺសូរសន្ធាប់ដូចផ្គរលាន់ ។ គេចូលចិត្តទៅមើល **ទឹកដែលធ្លាក់នេះ** ព្រោះវាធ្លាក់ **សម្បើមអស្ចារ្យ** ហើយ**បែកផ្សែង**ពាសពេញ **បញ្ចេញឥន្ទធនូ**ច្បាស់ក្រឡែតនៅពេលដែលមានបើកថ្ងៃ ។ បណ្ដាកន្លែងអស្ចារ្យទាំងនេះ អ្នកនិពន្ធយើងបានទៅឃើញនឹងភ្នែកជាក់ស្ដែង ហើយបានពណ៌នាតាមវិទ្យាជាតិ និងតាម **ទស្សនាវដ្ដីអក្សរសាស្ត្រ**ជាហូរហែមកហើយ ។ ប៉ុន្តែនឹកស្មានថា ទោះបីថតរូប ឬយករូបគំនូរមកបង្ហាញអស់លោកអ្នក ក៏មិនបានដូចជាវត្ថុពិតៗ ដែលបានទៅឃើញនឹងភ្នែកនោះទេ ។

បើយើងមាន **សារមន្ទីរវិទ្យាសាស្ត្រធម្មជាតិ** ប្រហែលជាគេអាចធ្វើរូបសំណាកឲ្យឃើញវត្ថុសម្បើមទាំងនោះ ទាំងស្រុងជាមិនខាន ។

**រំហ៊ែល ស៊ុំផា**



សហ. ជា-ម៉ូរ

# សេចក្ដីក្លាហាន

បានទទួលរង្វាន់លួងបិត្ត ឆ្នាំ ១៩៦៨

(ត ពីលេខមុន)

## កំណាព្យពាក្យ៩

ហើយឲ្យសត្វកាត់កាល័យពីរូបកាយ
ទំខ្វល់ខ្វាយផ្គង់គំនិតគិតគូចកាន់
គន់ការងារជាប្រយោជន៍យ៉ាងសំខាន់
កុំគិតកាន់ផ្ទាក់ផ្ទមកាយស្ដាយជីវិត ៗ

ត្រូវខិតខំសន្សំខានការងារ
ដែលបានជាផលប្រយោជន៍ប្រពៃពិត
សម្រាប់ខ្លួននិងអ្នកផងទាំងឆ្ងាយជិត
ញុំាងជីវិតឲ្យមានផលជាសាធារណ៍ ៗ

បើមិនអាចសាងប្រយោជន៍សាធារណ៍បាន
ត្រូវគិតអានត្រឹមប្រយោជន៍នៃអាត្មា
ផ្គត់ផ្គង់ប្រាណឲ្យបានរស់ខ្ពស់ថ្លៃថ្លា
លោកចាត់ថាជាការគួរថ្នាក់មធ្យម ៗ

បើអាប់អន់ទន់ទៅទៀតធ្វៀតមិនបាន
មិនអាចជួយស្ទួយលើកប្រាណបានសមរម្យ
ក៏កុំតែឲ្យកង្វល់ដល់សង្គម
កុំនិយមបោកល្បួចប្លន់នាំអន្តរាយ ៗ

ខសំខាន់ព្រះលោកនាថជាតិសាក្យះ
ទ្រង់បញ្ជាក់ថាកិច្ចការផងទាំងឡាយ
អាចកើតមានបានសម្រេចផលឆើតឆាយ
លុះតែកាយកបដោយអង្គបួនប្រការ ៗ

តាមបាលីលោកហៅថាឥទ្ធិបាទ
ជាក្បួនខ្នាតយ៉ាងបញ្ជាន់ក្នុងសាសនា
ជាទីតាំងក្ដីសម្រេចគ្រប់ប្រការ
មានមាត្រាដូចតារៀងថ្លែងតទៅ ៗ

មួយ-ឆន្ទៈគឺស្ម័គ្រស្មោះចំពោះការ
ជាប់ជិតស្និតស្និទ្ធស្នេហាយ៉ាងជ្រាលជ្រៅ
ឥតងាករែរប្រែរាគឃ្លាតចេញក្រៅ
ចងចាំនៅគ្មានរសាយណាយចិន្ដា ៗ

ដូចព្រះអង្គទ្រង់ប៉ុនប៉ងពោធិញាណ
ព្រះទ័យស្មោះត្រោះមិនមានថយប្រាថ្នា
ព្រះបំណងប៉ងលាលាតបារមី
ទោះបិតានិងមហេសីស្រីស្នំផង ៗ

ទំលួងលោមទាមរក្សាយ៉ាងណាក្ដី
គង់ចក្រីឥតបីលះព្រះបំណង
ផ្គង់ព្រះទ័យថ្លៃជាប់ស្អិតឥតមោះហ្មង
ទ្រង់តាំងចងប៉ងជានិច្ចឥតភ្លេចបាន ៗ

ពីរ-វីរិយៈគឺព្យាយាមប្រកបការ
ដោយឧស្សាហ៍ការប្រព្រឹត្តិឥតស្រាកស្រាន្ត
ទោះហត់នឿយព្រួយលំបាកអម្បាលមាណ
គង់ស៊ូទ្រាំពុំឲ្យខានខកការងារ ៗ

ដូចព្រះអង្គទ្រង់ស្វែងរកពោធិញាណ
តាំងប្រណិធានគ្មានថយក្រោយដោយរួញរា
ប្រាំមួយឆ្នាំទ្រាំលំបាកយ៉ាកអង្គា ៗ
រងវេទនាជាអនន្តពន់ប្រមាណ ៗ

បី-ចិត្តៈស្ម័គ្រសម្រេចប្ដេជ្ញាចិត្ត
ប្រាកដពិតឥតពរែករែកសន្តាន
តាំងចិត្តស៊ប់ប្រារព្ធការជាប្រមាណ
បើមិនបានប្រាណត្រូវប្រាសក៏មិនស្ដាយ ៗ

មិនលះបង់គ្រង់ព្យាយាមតាមឧស្សាហ៍
ដូចសាស្ដាប្ដេជ្ញាមាំពុំរសាយ
ចំពោះញាណគ្មានរវល់នឹងព្រះកាយ
គ្មានជិនណាយធ្លាយព្យាយាមមួយវេលា ៗ

មាត្រាបួនវីមំសាការរិះគិត
ត្រូវពិនិត្យគិតរំពឹងប្រឹងវិចារណ៍
ការកហេតុសង្កេតផលកលកិច្ចការ
ធ្វើយ៉ាងណាឲ្យការដើរប្រសើរបាន ៗ

ដូចព្រះអង្គទ្រង់ស្និងស្នាធ៍សង្កាត់ទំ
គង់សម្ងំក្នុងព្រឹក្សព្រៃទីស្ថសាន
ពិចារណាវេរិះរកប្រាជ្ញាញាណ
ដរាបបានត្រាស់ដឹងច្បាស់ព្រះធម៌ថ្លៃ ៗ

ឥទ្ធិបាទទាំងបួននេះព្រះសាស្ដា
ទ្រង់ទេសនាប្រោសសព្វសត្វទាំងគពត្រៃ
ឲ្យសន្សំទំពើនទាំងយប់ថ្ងៃ
ជាបច្ច័យផ្ដល់គម្រែគ្រប់ប្រការ ៗ

លើកពុទ្ធដីកាមកសំដែងថ្លែងបរិយាយ
ដើម្បីស្រាយពាក្យជៀលត្មះព្រះសាសនា
ដែលអ្នកខ្លះខ្វះគំនិតឥតសិក្សា
ចេះតែថាគ្រៅច្បាប់ក្បួនតាមខ្លួនយល់ ៗ

ឯការពិតច្បាប់សាសនាព្រះសម្ពុទ្ធ
មានប្រយោជន៍វិសេសសុទ្ធផុតសាកល
បើសិនគេគ្នេរប្រព្រឹត្តឲ្យជិតដល់
នឹងបានផលសល់សែនសុខៗថ្លៃថ្លា ៗ

រឿងក្រខ្សត់អត់ទ្រព្យធនទន់ស៊ីរ
មិនគប្បីស្ដីបន្ទោសពុទ្ធសាសនា
ត្រូវបន្ទោសចំពោះប្រាណគ្មានឧស្សាហ៍
មិនចាត់ការតាមលំអានដានកាសិត ៗ

ការស្វែងទ្រព្យតាមច្បាប់ក្បួនពុទ្ធសាសនា
មានពិស្ដារជាច្រើនបែបយ៉ាងវិចិត្រ
តែសូមស្ទះប៉ុណ្ណះចុះព្រោះត្រូវគិត
ត្រូវវិលមករកពិនិត្យរឿងក្លាហាន ៗ

ដែលតាំងទុកជាគោលដើមនៃកាព្យឃ្លោង
ត្រូវតែយោងឈោងយកមកជាប្រមាណ
បញ្ជាក់ហេតុបញ្ជាក់ផលតាមលំអាន
ជូនសន្តានជាសំណាប់ស័ព្ទបរិយាយ ៗ

—

នរជនធ្វើបរកេទ្រព្យធន
មិនទម្រន់បន្ទន់ចិត្តគិតរាយមាយ
ស៊ូប្បូរផ្ចាប់ក្នុងកិច្ចការដោយរីករាយ
ប្រាជ្ញព្រេងនាយឲ្យឈ្មោះថាអ្នកក្លាហាន ៗ

បើបព្វជិតអ្នកប្រព្រឹត្តវត្តព្រហ្មចារ្យ
ត្រូវស្នេហាសីលសិក្ខាយ៉ាងស្មោះស្មាន
ខំប្រព្រឹត្តគិតស្វែងរកធម៌ក្សេមក្សាន្ត
តាមលក្ខណ៍ឋានលំអានក្រិត្យពុទ្ធសាសនា ៗ

មិនរារែកបែកចិត្តផ្សេងវង្វេងផ្លូវ
ខំតម្រង់ផ្លង់តម្រូវផ្លូវសិក្ខា
គំនិតស្ទុងក្នុងធុរៈពីរប្រការ
គឺគន្ថៈវិបស្សនាជាប្រក្រតី ៗ

រម្ងាប់លោភល្មោភក្នុងលាភសក្ការៈ
រាយបំបាក់គ្រឿងទាក់ស្រេះក្នុងលោកិយ
ផុសខាត់ចិត្តឲ្យផូរផង់ផ្លង់ស្មារតី
មានខន្តីក្តីអត់ទ្រាំពុំរាយមាយ ៗ

ចិត្តស្ម័គ្រស្មោះចំពោះត្រង់ការប្រព្រឹត្ត
ទោះជីវិតត្រូវរលត់ផុតរលាយ
ឥតរលឹកនឹករសារាយមាយ
ខំទំលាយរាយទំលុះហ៊ានពុះពារ ៗ

ហ៊ានប៉ុនប៉ងជួងរំលងឧបសគ្គ
និងគ្រោះថ្នាក់ដែលខារខាំងកំងមាគ៌ា
ឥតញញើតឥតញញើមឬរញ្ញាក
ទើបចាត់ជាអ្នកក្លាហានមានគុណគាប់ ៗ

បើយោធាការពារដីបុរីរដ្ឋ
ត្រូវមានចិត្តប្រតិព័ទ្ធតំណែងទ័ព
ស្ម័គ្រប្រព្រឹត្តក្រិត្យវិន័យយ៉ាងជាប់លាប់
ស្តាប់បង្គាប់ដោយទៀងទាត់ឥតខ្ជីខ្ជា ៗ

ចិត្តស្មោះត្រង់ក្នុងករណីការពារជាតិ
មិនរវាតឃ្លាតសណ្តាប់ធ្នាប់យោធា
បូជជីវិតគិតយកជ័យលៃពុះពារ
គ្មានរួញរាអាខ្លាចបច្ចាមិត្រ ៗ

ចូលប្រយុទ្ធសម្លុតខ្មាំងតាំងតដៃ
ទោះត្រូវក្ស័យប្រល័យបង់អង្គជីវិត
គង់មិនរាគង់មិនរែកបែកគំនិត
លះជីវិតគិតទុកឈ្មោះជាទាហាន ៗ

មានមុខការការពារដែនមែនប្រាកដ
ត្រូវតាមបទកំណត់បែបពីបុរាណ
ជាតិទាហានត្រូវតែមានចិត្តហ៊ានហាន
ច្បាំងរុញច្រានបច្ចាមិត្រឲ្យខ្ចាត់ខ្ចាយ ៗ

ការពារជាតិសាសនា និងមហាក្សត្រ
ខំប្រតិបត្តិដោយទៀងទាត់ដូចបរិយាយ
ទើបឈ្មោះថាអ្នកក្លាហានយ៉ាងឆើតឆាយ
ទោះបាត់កាយគង់នៅឈ្មោះពីរោះល្បី ៗ

ក្តីក្លាហានមានអត្ថន័យថ្លៃថ្លាពិត
បើប្រព្រឹត្តបានត្រឹមត្រង់អង្គសេចក្តី
នឹងបានដល់ផលប្រយោជន៍សុខសួស្តី
គបសិរីជ័យមង្គលយ៉ាងទូលាយ ៗ

ព្រោះធម្មតាការរស់នៅត្រូវតស៊ូ
ខំគិតគូរស៊ូឥតរាពារទំលាយ
នូវឧបសគ្គនិងគ្រោះថ្នាក់ទាំងសម្ពាយ
ឲ្យរលាយខ្ចាយរលត់ទើបសុខសាន្ត ៗ

ឧបសគ្គធ្លាប់តែមានគ្រប់ការងារ
បើមិនហ៊ានពានពុះពារដោយក្លាហាន
មុខជាក្រិនមិនសម្រេចបំណងបាន
ត្រូវខកខានបានអំពល់ខ្វល់ចិន្តា ៗ

ពោលពណ៌នាឃ្លាសេចក្តីន័យក្លាហាន
ជូនសន្តានអានពិនិត្យអត្ថវោហារ
ជាសេចក្តីខ្វះស្ទើមមិនពិស្តារ
សូមបញ្ចប់ឈប់ចរចាប៉ុណ្ណេះអើយ ៗ

## និគមវចន

## បទព្រហ្មគីតិ

វីរភាពថាក្លាហាន ជាលំអាននៃអ្នកប្រាជ្ញ
ដែលមានចិត្តអង់អាច មិនរាខ្លាចក្តីនឿយហត់ ៗ
ព្យាយាមប្រកបការ ដោយឧស្សាហ៍យ៉ាងហ្មត់ចត់
តាំងចិត្តពិតប្រាកដ មានអំណត់ឥតរួញរា ៗ
ជនណាព្យាយាមមាំ ស៊ូអត់ទ្រាំធ្វើការងារ
តាមបែបដែលពណ៌នា ជននោះជាអ្នកក្លាហាន ៗ
ក្លាហានបានកេរ្តិ៍ឈ្មោះ បានសក្តិយសខ្ពស់ថ្កើងថ្កាន
បានសុខបានសម្រាន្ត បានក្សេមក្សាន្តគ្រប់វេលា ៗ
តួយ៉ាងខ្មែរសព្វថ្ងៃ សាងនិស្ស័យខាងការងារ
ព្យាយាមខំពុះពារ តាមមាគ៌ាសម្តេចឪ ៗ

ជាព្រះមគ្គុទេសក៍ ថ្ងៃវិសេសដឹកនាំផ្លូវ
ពន្យល់ការខុសត្រូវ ឲ្យស្គាល់ផ្លូវសុខក្សេមក្សាន្ត ៗ
ខ្មែរយើងភ្ញាក់ស្មារតី ខំឃ្មាតខ្មីកសាងប្រាណ
បានសុខបានក្សេមក្សាន្ត បានថ្កើងថ្កានមានកេរ្តិ៍ឈ្មោះ ៗ
ព្រោះតែខ្មែរក្លាហាន តាមលំអានព្រះទ្រង់យស
ដឹកនាំឲ្យខ្ពង់ខ្ពស់ ល្បីកេរ្តិ៍ឈ្មោះគ្រប់ភាព ៗ
ការណ៍នេះបញ្ជាក់បាន ថាក្លាហានមានឫទ្ធា
ត្រូវតែជននានា យកទុកជាគុណគាប់អើយ ៗ

**ចប់**

ផា-ប៊ូរ



# សុជីវធម៌ក្នុងក្រុមខ័ណ្ឌការងារ

លោកស្រី ភី-ធៀនឡាយ

មនុស្សទាំងប្រុសទាំងស្រី តែងលំវែយបំពេញការងារតែងតែទៅប្រកបការងារ នៅកន្លែងមួយជួបជុំចៅហ្វាយនាយមិត្តភក្តិឬអ្នកក្រោមបង្គាប់ៗ សុជីវធម៌បានតម្រូវឲ្យមនុស្សម្នាក់ៗ ប្រកាន់ឬកពាកកិរិយានិងសំដី ឲ្យសមតាមឋានៈខ្លួន ។

**ពីអ្នកធំទៅអ្នកតូច**: អ្នកធំត្រូវនិយាយទៅអ្នកក្រោមបង្គាប់ដោយ ឬរីភាពជានិច្ច ទោះជាក្នុងការស្តីបន្ទោសក៏ដោយ ។

ពិតមែនតែមិនត្រូវប្រកាន់ឬកធ្ងន់ សង្កត់សង្កិនខ្លាំងទៅលើអ្នកតូច ចៅហ្វាយនាយត្រូវតែមានអានុភាពខ្លះ ដើម្បីសំរួលដំណើរការ ។

– អ្នកធំត្រូវជៀសវាងការជជែក វែងវែងយោបល់ជាមួយអ្នកក្រោមបង្គាប់ ។

– បើអ្នកតូចមានការនិយាយ ជាមួយ ទោះបំពេញចិត្តក្តីឬមិនពេញចិត្តក្តី អ្នកធំគួរតែស្តាប់គាត់ផង ដើម្បីឲ្យគ្នាមានសេចក្តីក្លាហាននឹងបញ្ចេញគំនិតល្អរបស់គាត់ ។

– អ្នកធំត្រូវជៀសវាង ការស្និទ្ធស្នាលហួសប្រមាណជាមួយនឹងអ្នកតូច ដែលគ្នាមិនអាចតបវិញបាន ។

– អ្នកធំត្រូវដឹងថា ការសរសើររបស់ខ្លួនចំពោះអ្នកក្រោមបង្គាប់ មានប្រសិទ្ធិភាពជាងការស្តីបន្ទោស ។

– ចៅហ្វាយនាយត្រូវជៀសវាង ការរំខានដល់អ្នកក្រោមបង្គាប់ ដោយឥតប្រយោជន៍ ពីព្រោះគាត់មានកិច្ចការទៀងទាត់[illegible] គាត់មិនអាចធ្វើអ្វីកើតទេ ប្រសិនបើយើងចេះតែរំខានគាត់ ។

**ពីអ្នកតូចទៅអ្នកធំ**: – អ្នកតូចត្រូវប្រកាន់សេចក្តីគោរពជានិច្ចចំពោះចៅហ្វាយនាយ ប៉ុន្តែ មិនត្រូវបន្ទាបខ្លួនហួសពេកទេ ហើយចេះតែធ្វើតាម ចៅហ្វាយ រហូតនោះឡើយ ។

– អ្នកតូចអាចជំទាស់ចៅហ្វាយនាយបាន កាលណាមានការចាំបាច់ក្នុងផលប្រយោជន៍នៃកិច្ចការ, ប៉ុន្តែការវែងជំទាស់នេះ ត្រូវធ្វើឡើងដោយសុភាពបសារ ។

– អ្នកតូចត្រូវចេះនិយាយឲ្យច្បាស់លាស់ហើយឲ្យខ្លីៗ និងចេះគោរពសំរេចចុងក្រោយបង្អស់ របស់ចៅហ្វាយនាយខ្លួន ។ ពីព្រោះមុខងារខ្លួនជាអ្នកធ្វើតាមបង្គាប់គេទេៗ

– ពិតមែនតែដំបូន្មាន និងសេចក្តីណែនាំរបស់ចៅហ្វាយនាយ មានសារៈសំខាន់ដល់អ្នកក្រោមបង្គាប់ តែអ្នកតូចត្រូវដឹងថា អ្នកធំមានកិច្ចការផ្សេងៗជាច្រើនត្រូវបំពេញៗ ដូច្នេះអ្នកតូចត្រូវចៀសវាងកុំរំខានពេលវេលារបស់អ្នកធំ ដោយមិនសមហេតុផល ។

**រវាងអ្នកស្មើភាព**:– ជាមួយសហសេវិក លោក-អ្នកត្រូវប្រកាន់ឬរីភាពជានិច្ចក្នុងពាក្យសំដីនិងអំពើរបស់អស់លោក-អ្នកៗ

– ការគោរពកិច្ចការរបស់សហសេវិកនាំឲ្យមានសមានចិត្តទៅវិញទៅមក ហើយនិងចៀសវាងការរង្កៀសចិត្តគ្នា ។

– ការសំខាន់បំផុត ត្រូវចេះពួតដៃគ្នាធ្វើការ គឺម្នាក់ៗ អ្នកតូចឬអ្នកធំ ត្រូវទាក់ទងគ្នាទៅវិញទៅមក ដើម្បីឲ្យដឹងដំណើរការក្នុងការិយាល័យរួមគ្នា ។ គ្មានអ្នកណាមួយអាចទ្រាំទ្របានទេ ចំពោះមនុស្សដែលធ្វើការលាក់លៀម ហើយរំលោភទៅលើកិច្ចការអ្នកដទៃ ។

– ចូរអ្នកកុំរួញរា ក្នុងការជួយកិច្ចការរបស់សហសេវិកអ្នក ប្រសិនបើអ្នកមានមធ្យោបាយ ។ រីឯខ្លួនអ្នកក៏អាចពឹងពាក់គេវិញបានដែរ ។ នេះជាការបន្ថែមនូវសេចក្តីរីកឃទៅលើប្រសិទ្ធិភាពនៃការងារៗ

– ពិតមែនតែនៅក្នុងក្របខ័ណ្ឌវិជ្ជាជីវៈជាគោលការ, គេមិនត្រូវប្រកាន់គេទេជាស្ត្រីឬប្រុសក៏ដោយ ក៏ប៉ុន្តែ អស់លោកប្រុសៗត្រូវដឹងថា អស់លោកស្រីៗត្រូវបានសេចក្តីសន្តោសប្រណីអំពីយើង ។

– រីឯអស់លោកស្រីៗវិញ សូមកុំប្រើនូវឯកសិទ្ធិស្រីទៅលើគេឲ្យហួសហេតុពេកៗ

## ពិធីការក្នុងការងារ

– អ្នកតូចបើដើរជួបអ្នកធំត្រូវគោរពគេមុនៈ ដោយនិយាយថា «ជំរាបសួរលោក» ឬជំរាបលាលោក (ប៉ុន្តែមិនត្រូវហុចដៃមុនទេ) រួចចៀសផ្លូវទុកកន្លែងឲ្យអ្នកធំដើរទៅមុន ។

– ក្នុងកិច្ចការវិញ អ្នកតូចត្រូវចៀសវាងកុំនិយាយទៅកាន់អ្នកធំមុន លើកលែងតែការណាចាំបាច់ ។

– គេត្រូវនាំអ្នកតូចទៅឲ្យអ្នកធំស្គាល់ជាដរាប ទោះអ្នកក្រោមបង្គាប់នោះជាស្ត្រីក៏ដោយ ។

– ជារបៀបមួយទូទៅ សុជីវធម៌ ក្នុងការ

# សំណើចថ្ងៃនេះ



## លោកបងតា

បានជាគេហៅគាត់ថា លោកបងតា មកពីមានរឿងដូចតទៅ ៖

លោកតា យស មានអាយុ ៦០ប្លាយឆ្នាំ, ហើយគាត់ពោះម៉ាយ សព្វថ្ងៃកំពុងរកប្រពន្ធថ្មីទៀត ហើយសំដៅរកតែអាយុនខ្ចីៗ ល្មមតែខាំពីក្បាលបែកដល់កន្ទុយ ។

ថ្ងៃមួយមានយុវជនមួយក្រុម ដើរអំពាវនាវសួររកអ្នកស្ម័គ្រចិត្តទៅធ្វើការហត្ថកម្មសអាតផ្លូវ ដើម្បីទទួលសម្តេចឪ ដែលព្រះអង្គទ្រង់និងយាងមកសម្ពោធគិលានដ្ឋាន ។ ក្រុមយុវជនបានជួបនឹងលោកតា យស ហើយក៏និយាយសូមឲ្យគាត់ទៅចូលរួមជួយធ្វើការហត្ថកម្មនោះ ប៉ុន្តែលោកតាយើងខំធ្វើដំណើរត្រនៗ ហើយនិយាយសំឡេងញ័រៗតបវិញថា ឱចៅអើយ! តាចាស់ហើយ...ធ្វើការមិនកើតទេ សុំចៅទៅរកគេក្មេងៗ ដែលមានកម្លាំងពលំមាំមួនជួយធ្វើទៅ ! ។ នាយយុវជនស្តាប់បាន រួចក៏បន្តដំណើរទៅបបួលអ្នកឯទៀតៗ។

នៅទិវាដែលសម្តេចឪទ្រង់ស្តេចយាង យុវជន-យុវតី និងប្រជាពលរដ្ឋរង់ចាំថ្វាយបង្គំព្រះអង្គ ចំណែកលោកតា យស ក៏អញ្ជើញទៅរង់ចាំថ្វាយបង្គំសម្តេចឪដែរ ប៉ុន្តែគាត់នៅមិនឃ្លាតឆ្ងាយពីក្រុមយុវតីទេ។ បាកំឡោះស្បៀកពាក់ហ៊ឺហា ហើយដើរគាច់កងដូចតារាភាពយន្តហួសសម័យ ។ ដួនពេលនោះលោកនាយយុវជន បានជួបនិងលោកតា យស ហើយក៏សួរយកសេចក្តីគួរសមថា ឱ! លោកតាអញ្ជើញមកដែរ! ។ លោកតាយស ធ្វើជាពុំឮ ហើយបញ្ចេញទឹកមុខយ៉ាងមាំគួរឲ្យខ្លាច ប៉ុន្តែនាយយុវជនបន្ថែមសំឡេងរិតតែខ្លាំងជាងមុនទៅទៀតថា លោកតា! លោកតាយស!។ ពុទ្ធោអើយ! មិនទាន់បានបន្តសម្តីថាម៉េចទៀតផង ស្រាប់តែលោកតាយើងងាកខ្វាច់ដំឡើងភ្នែកស្លោប៉ុនៗភ្នែកអាត្រាក់ទ័រ ហើយបោះសំឡេងប៉ុនៗផ្គរដើមឆ្នាំថា អញយហោយ អ្ហែងពីអង្កាល់ បានហៅអញតា? ។ នាយយុវជនស្រឡាំងកាំងរកពាក្យឆ្លើយពុំរួច ប៉ុន្តែលោតែនឹកឃើញទាន់ អូអើ! មែនហើយឯងហៅគាត់ខុសកាលៈទេសៈ គឺបើចំពេលធ្វើការហត្ថកម្ម ត្រូវហៅថាតាៗ ប៉ុន្តែ បើនៅចំពោះមុខក្រមុំៗ ត្រូវហៅថាបងៗ ទើបគាប់ចិត្តគាត់ ។

ចំណែកក្រុមយុវតីដែលឈរនៅជាមួយនោះ ក៏នឹកហួសចិត្តដែរ ប៉ុន្តែមាន ៣-៤ នាក់ជាក្មេងឆ្លាត វាដើរមកជិតហើយសួរថា យី! លោកបងអញ្ជើញមកដែរអើតើ? ។ លោកបងហុកបាយសប្បាយចិត្តណាស់ ដៃគាត់លូកហោប៉ៅខោបន្តិច លូកហោប៉ៅអាវបន្តិចហើយផ្ទុះសំណើចហ៊ឹះ ! ហ៊ឹះ ! ស្ទើរបេះធ្មេញឧបអើមកដែរ! ម៉េចស្រស់ស្រួបអីៗ ហើយថ្ងទៅ? ។ យុវតីឆ្លាតក៏ឆ្លើយយ៉ាងស្រទន់ថា: ចា៎ះ នៅទេបង! អស់កម្លាំងណាស់! . . . ។ លោកបងយើងមិនបាច់គិតយូរ ក៏ទាញកាបូបខ្វាក់! ហ៎ះ៥០០រៀលយកទៅចែកគ្នា . . . សម្លេងទះដៃលាន់ប្រាវឡើងៗ យុវតីមួយក្រុមទៀតឮដូច្នោះ ក៏រត់ស្រសំដៅមកដែរ ព្រមទាំងសម្រែក : លោកបង! លោកបង!នៅពួកខ្ញុំទៀត;។ លោកបងយើង ញាក់ចិញ្ចើមព្រើតព្រាយ អូអើ! មែន! ហ៎ះ ៥០០ រៀល យកទៅចែកគ្នា . . .។ ពួកកំឡោះៗចង់យកតម្រាប់តាមក្រមុំៗក៏ស្ទុះមកដែរ ដោយស្រែកថា: លោកបង. នៅពួកខ្ញុំទៀត! ។ លោកបងងាកភ្នែកលើកដៃកហើយថាឈប់! ចាំថ្ងៃក្រោយសម្លេងហ៊ោក៏លាន់គ្រាវឡើង...។

**ម៉ែន-ធន់**

---

ការផ្តល់នូវលក្ខណៈងាយស្រួលជាចាំបាច់ក្នុងការទាក់ទងវិជ្ជាជីវៈ ក៏ដូចជាការទាក់ទងរវាងមនុស្សនិងមនុស្សដែរ ដើម្បីកុំឲ្យមានចរិតឆាំឆ្គងណាមួយអាចបំផ្លាញចរិតផ្សេងៗទៀតបាន ។

— ត្រូវចេះរក្សាមុខរបរនិងទីកន្លែងរបស់អ្នក ដោយត្រូវគោរពមុខរបរនិងទីកន្លែងរបស់អ្នកដទៃ ។

— ត្រូវចេះធ្វើឲ្យគេស្រឡាញ់ តែត្រូវចៀសវាងការស្និទ្ធស្នាលហួសប្រមាណ ។ ហើយចេះធ្វើសហប្រតិបត្តិការជាមួយសហសេវិកតែត្រូវចេះលាក់លៀមការសម្ងាត់ផងដែរ ។

រៀបរៀងដោយលោកស្រី

**គី-ធៀនឡាយ**

អធិការបឋមសិក្សា

(តពីលេខមុន)



# ឧតុនិយមវិទ្យា

## បរិយាកាសនឹងបង្កើតផលអាហារណីយ

### ៥– សីតុណ្ហភាព

បច្ចុប្បន្នកាលនេះ គេមានឯកសារជាច្រើន ស្ដីពីសីតុណ្ហភាពនៅក្នុងផ្នែកផ្សេងៗនៃពិភពលោក ។ ជាការណ៍ពិតណាស់ សីតុណ្ហភាពមានកម្រិតមិនទៀងទាត់ដូចគ្នាទេ ជាពិសេស សីតុណ្ហភាពដែលទ្រទ្រង់ជីវិតរុក្ខជាតិ និងសត្វ ។ ប៉ុន្តែ សីតុណ្ហភាពជាប្រភពដើមក្នុងការសរសេរ អំពីអាកាសធាតុ និងឥទ្ធិពលរបស់វាទៅលើការលូតលាស់នៃកូតគាម ។

រុក្ខជាតិទាំងឡាយនឹងស្វិតស្រពោន ឬងាប់តែម្ដង បើកាលណាសីតុណ្ហភាពចុះមកនៅក្រោមសូន្យ ។ ដើមរុក្ខជាតិខ្លះទៀតមិនដុះទាល់តែសោះ បើសីតុណ្ហភាពមានអត្រាមិនលើសពីកម្រិតអប្បបរមា ដែលកំណត់ទុក «៦អង្សា ជាកម្រិតសន្មតនៅសីតាលុប្រទេស» ។ មានរុក្ខជាតិមួយចំពូកទៀតមិនអាចលូតលាស់ទៅរួច កាលណាធាតុត្រជាក់ និងសើមមិនគ្រប់គ្រាន់ ។ ថ្វីបើការដុះដាលនៃកូតគាម មិនអាចបរិយាយឲ្យបានសព្វគ្រប់ ឬមិនបានគិតដល់ការប្រែប្រួលនៃសីតុណ្ហភាព យើងអាចយកភាគខ្លះរបស់អាកាសធាតុដើម្បីកំណត់នូវភូមិភាគ និងជីវិតនៃកូតគាម ។

សីតុណ្ហភាពនៅក្នុងតំបន់មួយ មានប្រព័ន្ធទាក់ទងទៅកត្តាសំខាន់ៗ ពីរយ៉ាង:

១– តុល្យការរវាងកំដៅព្រះអាទិត្យ និងចំហាយផែនដី ហើយក្នុងចំនួនលើស និងខ្វះវត្ថុធម្មជាតិនៅលើផ្ទៃផែនដីនេះ មានប្រយោជន៍ណាស់ ។

២– គឺការផ្លាស់ប្ដូរភ្លាមៗនៃចរន្តខ្យល់ បក់មកពីភូមិភាគផ្សេងៗ ។ ហើយមានកត្តាបន្ទាប់បន្សំផ្សេងទៀត គឺការប្រែប្រួលនៃសីតុណ្ហភាពនៅលើអាកាស ដូចជានៅពេលយប់មេឃស្រឡះ នៅជិតផែនដីសីតុណ្ហភាពចុះថយទៅតាមកំពស់ក្នុងអត្រា ០,៦៤ អង្សា ក្នុង ១០០ម ។

ដោយយោងទៅតាមការពិចារណាខាងក្រោមនេះ ក្នុងចំណោមផែនទីធាតុអាកាស គេច្រើនយកសីតុណ្ហភាពមធ្យមនៅកំពស់ផ្ទៃសមុទ្រ ។



▲ ស្ថានីយឧតុនិយម កសិកម្ម ▼



ការប្រែប្រួលនៃសីតុណ្ហភាពមធ្យមនៅលើពិភពលោក ផ្លាស់ប្ដូររហ័សបំផុតជាមួយនឹងការផ្លាស់ប្ដូរកំពស់ និងចម្ងាយ ។ បើយើងគិតទៅដល់ការប្រែប្រួលរបស់សីតុណ្ហភាពជាមួយនឹងឧបពេគ្គ យើងអាចសំគាល់ឃើញថា រូបភាពក្នុងទីចរន្តវាតរបស់សីតុណ្ហភាពមានរបៀបផែនដូចជារូបភាពរបស់ចំហាយព្រះអាទិត្យដែរ ។

ផែនដីទទួលកំដៅ និងទទួលធាតុ



...ហ្វានីយ ឧតុនិយមនៅលើសមុទ្រ ។



ពាករណាប ឧតុនិយមទីរួស កំពុងហោះទៅកាន់អវកាស ។

ត្រជាក់ឆាប់ជាងសមុទ្រ ។ ផែនដីក្ដៅជាងសមុទ្រនៅរដូវប្រាំង ហើយត្រជាក់ជាងសមុទ្រនៅសិសិររដូវ ។ ដោយយោងទៅតាមទ្រឹស្ដីខាងលើនេះ មានភូមិភាគខ្លះត្រជាក់ខ្លាំងនៅរដូវប្រាំង ហើយត្រជាក់ល្មមនៅសិសិររដូវ កត្តានេះបណ្ដាលមកពីសកម្មភាពនៃចរន្តវាត ។

នៅខែមករា លើឧត្តរអឌ្ឍគោល សីតុណ្ហភាពយ៉ាងត្រជាក់ បានគ្របដណ្ដប់ស្ទើរតែពាសពេញ ។ តាមផែនទីយើងសង្កេតឃើញខ្សែសមសីតុណ្ហភាព "អ៊ីសូតាម" សូន្យអង្សា ធ្លងកាត់ភូមិភាគអាស៊ីលើខ្សែរនិរលេខ ៣៨ និង ៤២ អង្សា កាត់តាមសមុទ្រខ្មៅ រហូតទៅដល់ព្រំប្រទល់ប្រទេសអាល្លឺម៉ង់ និងប្រទេសស្វិស រួចហើយរត់ឆាកសំដៅទៅទិសឧត្តរ ដោយកាត់តាមភូមិភាគនៃទីក្រុងប៊ែរឡាំង ហើយសំដៅទៅឆ្នេរសមុទ្រព្រំប្រទល់ប្រទេសន័រវែស ។ ខ្សែសីតុណ្ហភាពសូន្យអង្សានេះ លាតសន្ធឹងពីទិសបស្ចិម ធ្លងកាត់ភាគខាងត្បូងប្រទេសអ៊ីស្លង់ដ៍ ឆ្ពោះទៅដល់ទីក្រុងញូវយ៉ក ហើយតម្រង់មកឈូងសមុទ្រអាឡាស្កា ។

ក្នុងខែមករានេះ តំបន់សីតាលុក្នុងពិភពលោក ស្ថិតនៅខាងជើងនៃប្រទេសស៊ីបេរី ដែលគេសង្កេតឃើញសីតុណ្ហភាពអប្បបរមាកម្រិត ៦០ អង្សា ក្រោមសូន្យនៅវែរខូយ៉ង់ ។ ចំណែកឯតំបន់ឧណ្ហាលុក្នុងឧត្តរអឌ្ឍគោលវិញ ស្ថិតនៅក្បែរភូមិឲ្យសខា ។

ផ្ទុយទៅវិញ ខែមករានៅទក្សិណអឌ្ឍគោល រដូវប្រាំងមានប្រពលភាពយ៉ាងខ្លាំង នៅភូមិភាគដីគោកបីកន្លែងគឺ នៅអាមេរិកខាងត្បូង, អាហ្វ្រិកខាងត្បូង និងប្រទេសអូស្ត្រាលី ដែលសីតុណ្ហភាពមធ្យមប្រចាំខែមានកម្រិត ៣០ អង្សា ។ នៅប្រទេសប្រេស៊ីលនាតំបន់ខ្ពង់រាប សីតុណ្ហភាពមធ្យមមានកម្រិតទន់ថយ តែផ្ទុយទៅវិញ នៅវាលរហោស្ថានកាឡាហារី នៅពេលថ្ងៃ សីតុណ្ហភាពមានកម្រិតខ្ពស់ជាអតិបរមារហូតដល់ទៅ ៤៥ អង្សា ។

ក្នុងខែកក្កដា ស្ថានភាពមានលក្ខណៈផ្ទុយគ្នាស្រឡះទៅវិញ ជាពិសេស នៅឧត្តរអឌ្ឍគោល គឺជាស្ទើរតែនៅគ្រប់ភូមិភាគគ្មានសមសីតុណ្ហភាពសូន្យទាល់តែសោះ លើកលែងតែនៅតំបន់ហ្គ្រោអេឡែនចេញ។ ឯសីតុណ្ហភាពក្ដៅជាងគេវិញនៅរដូវនោះ មានតែតំបន់សាហារ៉ានិងនៅវាលរហោស្ថាននៃទ្វីបអាស៊ីប៉ែកនិរតី ។

ដោយសង្ខេបទៅ សីតុណ្ហភាពជាកត្តាមួយយ៉ាងសំខាន់បំផុត ដែលអ្នកកសិករត្រូវតែដឹងមុនពេលចាប់ផ្ដើមធ្វើកសិកម្ម ។

## ៦– មហន្តរាយផ្សេងៗ

គឺជាកិច្ចសំខាន់មួយដែលត្រូវពិនិត្យឲ្យដឹង តើតំបន់ណាខ្លះ ដែលរមែងទទួលគ្រោះថ្នាក់ពីធាតុអាកាសនិយម ដូចជាការរញ្ជួយផែនដី, ការផ្ទុះឡើងនៃភ្នំភ្លើង, ព្យុះសមុទ្រ, ទឹកជំនន់, ព្យុះខ្យល់និងភ្លើងឆេះព្រៃ ។ល។

មហន្តរាយទាំងអស់នេះមិនគ្រាន់តែបណ្ដាលឲ្យមានការខូចខាតដល់ជីវិតមនុស្សនិងផលដំណាំប៉ុណ្ណោះទេ តែជួនកាលគេត្រូវការរយៈពេលជាច្រើនឆ្នាំណាស់ ដើម្បីធ្វើតំបន់ទទួលរងគ្រោះនោះឲ្យមានលទ្ធភាពក្នុងការផ្ដល់នូវផលដំណាំដូចដើមឡើងវិញ ។ មនុស្សយើងមានមធ្យោបាយតិចតួចស្ដួចស្ដើងណាស់ ដើម្បីទប់ទល់នឹងគ្រោះកាចនេះ ហើយដូច្នេះផលដំណាំគ្រប់ប្រភេទត្រូវទទួលរងគ្រោះកាចនេះដោយខានមិនបាន ។ ផលិតផលអាហារណីយ ត្រូវមាននីតិភាពជានិច្ច ប្រសិនបើយើងនឹងជៀសវាងទុរភិក្សភ័យ ក៏ប៉ុន្តែមហន្តរាយ បណ្ដាលពីអាកាសធាតុភូតធ្វើឲ្យមានការប្រែប្រួលអស់រលីង ។

នៅមានត



សហជីវិន
ហេង-ទូច

**ហេង-ទូច**

# នេះហើយ មេរៀន មួយ





សហជីវិន ម៉ែន-ទន់

ដោយបានស្ដាប់ពាក្យសម្បថរបស់លោក ធុន និងពាក្យធានារបស់ តាសួស គួរជាទីទុកចិត្តដូច្នោះហើយ សុមាលី ក៏ព្រមស្រុះស្រួលជួបជុំគ្នាវិញ ។

ពេលនោះ បរិយាកាសដ៏សែនរីករាយក៏កើតមានឡើងនៅក្នុងគ្រួសារលោក ធុន ។ មីងចាប ដែលលបចាំស្ដាប់ និងសង្កេតមើលតាំងពីដំបូងមកនោះ លុះបានដឹងថាលោកប្រុស និងលោកស្រីជានានឹងគ្នាវិញហើយ គាត់មានចិត្តត្រេកអរណាស់ ក៏ផ្ទុះសំណើច ហា! ហា! ព្រមទាំងបន្ទាបចាពីកន្ទៀតទ្វារបន្ទប់ដេកមកថា :

— នី: ខ្ញុំថាអីថា : ពីយប់ម្សិលខ្ញុំយល់សប្តិឃើញ លោកប្រុសនិងលោកស្រីអង្គុយទល់មុខគ្នា ហើយសើចរកគ្នា ខ្ញុំក៏នឹកថាច្បាស់ជាជួបជុំគ្នាវិញពុំខាន ឥឡូវនេះ ជួប[...]មែន ហា! ហា!... ។

— សុមាលី អត់ទ្រាំពុំបានក៏សើចផងដែរ ព្រមទាំងនិយាយឆ្លើយវិញថា : យល់សប្តិមីងធុតមែន ប៉ុន្តែធុតបានតែឃើញរូបហើយនោះទេ ។ ទាំងអស់គ្នាក៏សើចព្រមគ្នាឡើង ។ បន្ទាប់មក មីងចាបលើកតមន្ទា ហុចឲ្យលោក ធុន ហ៎: ទៅប៉ា! ទៅប៉ា! ។ លោក ធុន ក៏ទទួលយកកូន ប៉ុន្តែមិនយូរប៉ុន្មាន មន្ទា បម្រះចេញពីដៃ ព្រោះវាពុំទាន់ស្គាល់ច្បាស់ជានរណានៅឡើយ ។

**ក្រោយដែលបានសំណេះសំណាលលេងពីនេះពីនោះរួចហើយ លោកតាសួសក៏លាទៅទាំងពីរទៅផ្ទះវិញ ដោយនាំយកទាំងជោគជ័យដ៏ជាទីគាប់ប្រាថ្នាទៅជាមួយផង ។ ឯគូស្រករដែលចាស់ដូចជាថ្មីឯណោះក៏ចូលនិទ្រាតាមធម្មតា ប៉ុន្តែលោកធុនពុំទាន់និយាយអំពីរឿងប្រាក់ ១៥.០០០ រៀល ជារបស់ធនាគារនោះទេ ។**

រាត្រីថ្ងៃសៅរ៍កន្លងផុតទៅ, ទិវាអាទិត្យក៏ចាប់ផ្ដើមឡើង ។ លោក ធុនស្លៀកពាក់ស្អាតបាត ទំនងជារៀបចេញដំណើរទៅទីណា ប៉ុន្តែអស់ពេលជាង ១០ នាទីទៅហើយ លោក ធុន នៅតែវិលវល់ក្នុងផ្ទះ ហាក់ដូចជាចង់និយាយអំពីបញ្ហាអ្វីមួយជាមួយសុមាលី ប៉ុន្តែពុំហ៊ាននិយាយ ។ សុមាលីដឹងអធ្យាស្រ័យ ក៏សួរទៅស្វាមីថា:

— បងស្លៀកពាក់រៀបចេញដំណើរទៅណាឬ ?

— មិនទាន់ដឹងថាទៅណាទេ ប៉ុន្តែបងចង់និយាយរឿងមួយប្រាប់អូន ។

— រឿងអីបង មានប្រសាសន៍ទៅ !

លោក ធុនទាញដៃភរិយាទៅអង្គុយទន្ទឹមគ្នារួចក៏និយាយថា :

— **បងមានការណ៍មួយ ដែលស្ទើរតែមិនហ៊ាននិយាយប្រាប់អូន ខ្លាចអូនព្រួយចិត្ត ប៉ុន្តែបើមិននិយាយឃើញថាពុំកើត ព្រោះជាបញ្ហាឆ្នាំងបាយសម្រាប់គ្រួសារយើង ។**

— បងមានប្រសាសន៍ទៅ! កុំខ្លាចខ្ញុំព្រួយ! ព្រោះរឿងព្រួយហើយនឹងខ្ញុំ វាចៀមចិត្តអស់ទៅហើយ !

—បងមានជំពាក់ប្រាក់ចៃណៃហើយគាត់បង្ខំតឹង ទារខ្លាំងពេក ហួសដល់ ទៅគិតប្ដឹងពីបងផង ។ ដោយចង់ដោះខ្លួនឲ្យបានរួចមួយគ្រានោះ បងក៏យកប្រាក់ធនាគារ ១៥.០០០ រៀលសងគេសិនទៅ ឥឡូវនេះធនាគារតម្រូវឲ្យយកប្រាក់ទៅដាក់ឃ្លាំងក្នុងកំណត់ ១០ ថ្ងៃ យ៉ាងយូរ បងសុំឲ្យអូនជួយដោះស្រាយបង

កូនរឿងនេះ ។

សុមាលីហួសចិត្ត ទៅជាអង្គុយធ្មឹងដូចមនុស្សគ្មានវិញ្ញាណ ព្រោះនាងនឹកឃើញថា មានតែឪពុក-ម្ដាយនាងទេ ដែលអាចជួយដោះស្រាយបាន ប៉ុន្តែឲ្យជួយដោះស្រាយដល់ណាទៀត បើសព្វថ្ងៃនេះគាត់ធុញទ្រាន់ខ្លួនខ្លាំងណាស់ទៅហើយ ដោយសារតែរូបនាងម្នោះហើយនាងទៅជាគរកពាក្យឆ្លើយនឹងប្ដីពុំបាន មានតែគំណក់ទឹកភ្នែកហូរសស្រាក់ជាសញ្ញានៃការឆ្លើយតបទៅវិញ ។

លោកឌុងឃើញដូច្នោះ អាចដឹងទុំមួនខ្ទុករបស់ប្រពន្ធក៏យកដៃត្រកង ហើយនិយាយលួងលោមថា :

— អូនសម្លាញ់សម្លុតចិត្តរបស់បង បងដឹងនូវទំហំទុក្ខរបស់អូនហើយ ហើយទុក្ខទាំងនោះគឺរូបបងនេះឯង ដែលជាអ្នកផ្ដល់ឲ្យអូន ។ បងសូមសារភាពថា បងខុសធំណាស់ ខុសដោយសេពគប់នឹងមនុស្សពាលខុសដោយប្រព្រឹត្តល្បែងស៊ីសងនិងសប្បាយហួសហេតុ, បងភ្លេចគិតដល់ប្រពន្ធដែលចេញចាកម៉ែ-ឪមករួមរស់ជាមួយប្ដី, ភ្លេចគិតដល់កូនដែលមកចាប់កំណើតផ្ញើអាយុជីវិត និងភ័ព្វព័សនាក្រោមម្លប់ឪពុក ។ ឥឡូវនេះបងដឹងខ្លួនហើយ បងលែងប្រព្រឹត្តដូចមុនទៀតហើយ! **នេះជាមេរៀនមួយ** ដែលបងត្រូវតែចេះនិងចាំអស់មួយជីវិត ប៉ុន្តែបងសុំឲ្យអូនជួយរកប្រាក់សងរាជការឲ្យទាន់ពេលវេលាសិន បើរកមិនបានទេ បងមុខជាត្រូវជាប់គុក ហើយរាជការនឹងបណ្ដេញបងពីមុខតំណែង ព្រមទាំងឲ្យបងរកប្រាក់សងទៀតផង

រឿងនេះបងយល់ថា ពុកនិងម៉ែប្រហែលជាអាចជួយយើងបាន ហើយយើងមិនឲ្យគាត់ជួយទទេនោះទេ គឺបើយើងសងអ្នកឯទៀតៗ រួចកាលណា យើងនឹងសងជូនគាត់វិញ ព្រោះប្រាក់ខែយើងក៏គ្រាន់គ្រាន់ដែរ បើបងឈប់ប្រព្រឹត្តអបាយមុខទៅហើយ មិនយូរប៉ុន្មានមុខជានឹងបានសល់ប្រាក់ទុកសងជូនពុក-ម៉ែពុំខាន ។

ក្រោយដែលបានស្ដាប់ពាក្យប្ដីសព្វគ្រប់ហើយ សុមាលីយល់ថា **បើសេះជាប់ត្រូវយកសេះតាម** រួចក៏និយាយនឹងប្ដីថា មិនអីទេ ចាំខ្ញុំជួយដោះស្រាយលមើល ។

ដោយមានការអៀនខ្មាស មិនចង់ឲ្យអ្នកស្រុកដែលនៅជិតខាងផ្ទះឪពុក - ម្ដាយរបស់នាងឃើញមុខនាងនោះ សុមាលីមិនហ៊ានទៅជួបផ្ទាល់ខ្លួនទេ គឺនាងសរសេរសំបុត្រមួយមានសេចក្ដីដូចតទៅ៖

ភ្នំពេញ ទៅថ្ងៃទី . . .

កូនសូមប្រណិបតន៍ចូលលោកឪពុកលោកម្ដាយដ៏ជាទីគោរព

សូមទានជ្រាប ។

ប្ដីរបស់កូនគេមកសុំជានានឹងកូនវិញហើយ ហើយគេបានស្បថស្បែថាលែងប្រព្រឹត្តអបាយមុខដូចមុនៗទៀត ។

ចំណែកកូនក៏បានយល់ព្រមជានានឹងគេវិញដែរ ប៉ុន្តែ មានបញ្ហាមួយទៀតដែលត្រូវដោះស្រាយជាបន្ទាន់ គឺគាត់ចំពាក់ប្រាក់រាជការចំនួន ១៥.០០០រៀល ហើយត្រូវរកសងវិញឲ្យទាន់ក្នុងរវាង ៦-៧ ថ្ងៃនេះ បើមិនបានសងទេ ប្ដីកូនមុខជាត្រូវមានទោស និងត្រូវរាជការបណ្ដេញមុខពីតំណែង ។

ហេតុនេះ សូមលោកដ៏មានគុណទាំងពីរ មេត្តាជួយរកប្រាក់ឲ្យកូនបានចំនួន ១៥.០០០រៀល ដើម្បីកូនយកទៅសងរាជការ ។ កូនសូមសន្យាថានេះជាលើកក្រោយបំផុត ដែលកូនមករំខានលោកឪពុកលោកម្ដាយ ហើយប្រាក់នេះកូននឹងសងជូនវិញ នៅពេលដែលកូនសងអ្នកឯទៀតៗរួច ។ បើបានហើយ សូមមេត្តាផ្ញើតាមមីងចាបឲ្យផង ។

សូមលោកដ៏មានគុណមេត្តាអភ័យទោសដល់កូន ។

ហត្ថលេខា

**សុមាលី**

សរសេរសំបុត្រនេះរួចហើយ សុមាលីបទដាក់ក្នុងស្រោមរួចប្រើមីងចាបនាំយកទៅជូនឪពុកម្ដាយស្ងួនជាបន្ទាន់ ។

**ម៉ែន-ធន់**




**អៃសិនហាវ័រ៖ គេមិនត្រូវវ៉ាំងប្រយ័ត្នហួសពេកទេ កូនសំឡាញ់...**

**IKE:** On n'est jamais tro[illegible] prudent, fil[illegible]

## កំណាព្យជាភាសាអង់គ្លេស និពន្ធដោយ សហជីវិ ននី-ប៊ុនហ៊ាង ដើម្បីឧទ្ទិសថ្វាយ ចំពោះសម្ដេចឪ

# OF SAMDECH EUV

*In the middle of a night, on my flight around the moon,
A little child, two of age dreamed so wild woke me soon
Sounded «CHEY-YO SAMDECH EUV!» suddenly in delight
Looked at young face hailest his «EUV» I bid good night.
Oh! little child, innocent in age, God sent to pay homage
To a Prince that Khmers are proud under his patronage.
He who serves Buddha so well servest his nation,
And we love Buddha with might adore him with devotion*

*Of him, King and Prince of praise by Buddha's holiest
Charge thousands of masterpieces could not depitch at best;
Pious, great, just, beneficient, firm, indulgent,
Sagacious, strong, serene, sincere, benevolent,
Courageous, wise, equal to all and loved by all.
There are more to mark, but short of might I must stall.*

*Pious — for having payed tribute to Lord Buddha,
Frocking himself, seek the truth midst his frolic youth;
Building pagodas and temples willing to smooth
His life and of subjects enlightened by Dhammapada.*

*Great — to lead people without least weigh to be felt,
Enough to drive Dragon and blood drunken Eagle
To hell; to make ink around earth corners spilt,
At politic as playwright, greatness as bright sun.*

*Just — words and actions revealed, virtue from within,
From people's voice. Justice to overcome jungle's law,
The woefully frighten to be near foremost to draw;
Whether to forgive or to play the sword and spear.*

*Beneficient — goodness in action to give
When needs present, when pardon was asked to forgive.
To wage a war against malice, to cleanliness
Change squalor; beneficience in God manifests.*

*Firm and constant in his fight against Lucifer,
In his vow to keep his kingdom as prime mover
Of peace in this region burning in fire, neutral
Is the road, to Great Teacher adhere and behold.*

*Indulgent — everywhere on his path people appear
To quench their thirst with shower of indulgences;
His heart's an unexhausted fountain of compassion;
Erecting houses of good will, down the prison.*

*Sagacious — in his manner to meet all events,
Shrewd in way of thought, genious in sleep or awaken.
Strong — his hands, heart and soul by Indra's command
To defy time with rice grow on plain af sand.*

*Serene — at peace, in war to sow the seeds of progress,
To perpetuate love in beauty or ugliness.
As graceful manners of bamboo bush in the wind;
Serenity, silencing the vice, uplift his kin.*

*Sincere — if God's blessing be honest and truthful
So are his generous tongue and heart bountiful;
Sincere in his friendship, smile, cry, laugh and love
And in his counsel, reproch, sincerety from above.*

*Benevolent — by God's will, in him lodge lofty
Altruistic ego to yield more kindness less creed,
To give utmost offering and kill Satan for his greed,
To fashion our life crowning with rose and honey.*

*Courageous — not only brave in right conviction,
Not swayed by pain or pleasure, by desire or fear
Courage in grain from Norodom's vein, most dear
Unrivalled royalty courage to preserve nation*

*Wise — of Buddha's wisdom, in Plato's and Tao's book.
Wisdom as revealed in human live daily
That makes life of all Khmers large and lovely,
That the most reviled exclame « Ah! we are all crook! »*

*Equal to all — his lustrous crown methought lofty,
Himself stepped down, lowering to live with lion and bee,
To better serve and work with them, hoe in hands earth
Loosening, trees cut down; equal in way unmatched in work.*

*Loved by all — just as the Khmers call him «Samdech Euv!»,
From mouth to mouth adoration flow from clean heart;
They applaud and embrace him with divinest art;
This love that knits national union nests the Dove.*

*Of Samdech-Euv, Sihanouk of Norodom's blood;
Of Samdech-Euv, plenty of water on Khmer's field;
Of Samdech-Euv, miracle's performed by Khmer's will;
Of Him, of considerations the nation's a flood.*

**Ny Bunheang**
**(Summer 1968)**

# ពិធីបំពាក់គ្រឿងឥស្សរិយយស ជូនចំពោះលោកវេជ្ជបណ្ឌិត រ៉ឺណេរ-ឌេលិន-ហ្សាំងហ្ស៊ូ



សហជីវិន ចាន់-យូក៉ាន់ ថតជាមួយភ្ញៀវខ្លះ ដែលមានលោកសាស្ត្រាចារ្យ រ៉ឺណេ-ឌេរលិន-ហ្សាំងហ្ស៊ូផង គឺរូបទី ២ រាប់ពីខាងឆ្វេង

កាលពីថ្ងៃទី ១៧ កុម្ភៈ ១៩៦៩ សហជីវិនចាន់-យូក៉ាន់ការធារីប្រទេសកម្ពុជាប្រចាំទីក្រុងដាការ បានរៀបចំចាត់ចែងពិធីបដិសណ្ឋារកិច្ចដ៏ស្និទ្ធស្នាលមួយ នៅក្នុងស្ថានទូតខ្មែរយើង ដើម្បីជូនជាកិត្តិយសដល់លោកសាស្ត្រាចារ្យ រ៉ឺណេ-ឌេរលិន-ហ្សាំងហ្ស៊ូ ។

ភ្ញៀវចំនួនម្ភៃប្រាំបីនាក់ បានអញ្ជើញទៅរួបរួមក្នុងពិធីនោះ គឺមានជាអាទិ៍លោកសាកលវិទ្យាធិការនៃសាកលវិទ្យាល័យ នៅទីក្រុងដាការ, លោកព្រឹទ្ធបុរសនៃមហាវិទ្យាល័យវិជ្ជាពេទ្យ, លោកហង់រី-ឌុយប័រ ដែលធ្លាប់មានមេដាយសេនានៃព្រះរាជាណាចក្រកម្ពុជា និងលោកអារម៉ង់-សេរ៉ូឌី ដែលធ្លាប់មានមេដាយអស្សឫទ្ធិ នៃព្រះរាជាណាចក្រកម្ពុជា ។

នៅពេលនោះ ក្នុងព្រះបរមនាមដ៏ខ្ពង់ខ្ពស់នៃសម្តេចឪ សហជីវិនចាន់-យូក៉ាន់បានបំពាក់នូវមេដាយធិបឌិន នៃព្រះរាជាណាចក្រកម្ពុជាជូនលោកសាស្ត្រាចារ្យរ៉ឺណេ ឌេរលិន-ហ្សាំងហ្ស៊ូ ដែលធ្លាប់មានគុណបំណាច់ចំពោះប្រទេសកម្ពុជាយើង ។

ο

ο ο



បុគ្គលិកស្ថានទូតនិងភ្ញៀវជាច្រើនរូបថតទុកជាអនុស្សាវរីយ៍ ក្រោយពិធីបដិសណ្ឋារកិច្ចដ៏ស្និទ្ធស្នាលនេះ



ពីឆ្វេងទៅស្តាំ ៖
លោកព្រឹទ្ធបុរសនៃមហាវិទ្យាល័យវិជ្ជាពេទ្យនិងលោក រ៉ឺណេ-ឌេរលិនហ្សាំងហ្ស៊ូ



ឥស្សរជនទាំងបីរូបដែលបានទទួលនូវគ្រឿងឥស្សរិយយសនៃប្រទេសកម្ពុជា

# ទស្សនាចរនៃឯកឧត្តម ឧត្តមសេនីយឯកញ៉ឹក-ជូឡុង



ផ្លូវថ្នល់ពីថ្មពួក ទៅបន្ទាយឆ្មា ដែលកងយោធពលខេមរភូមិន្ទស្ថាបនាឡើង តាមការដឹកនាំនៃឯកឧត្តមឧត្តមសេនីយឯក ញ៉ឹក-ជូឡុង



ឯកឧត្តម ឧត្តមសេនីយឯក ញ៉ឹក-ជូឡុង បានធ្វើអំណោយជាប្រាក់ដល់ប្រជាពលរដ្ឋ និងកុមារ-កុមារីអស់ជាច្រើនពាន់រៀល

កាលពីថ្ងៃទី២៧កុម្ភៈ១៩៦៩ ឯកឧត្តមឧត្តមសេនីយឯកញ៉ឹក-ជូឡុងអគ្គមេបញ្ជាការនាយអគ្គសេនាធិការយោធពលខេមរភូមិន្ទ ដែលមានលោកវរសេនីយឯក សាក់-ស៊ុតសាខន នាយរងនៃអគ្គសេនាធិការ លោកវរសេនីយឯកអ៊ឹង-គាត ទីប្រឹក្សាបច្ចេកទេស ព្រមទាំងនាយទាហានជាន់ខ្ពស់ ជាសហការីឯទៀតជាច្រើន ដែលយើងសូមអភ័យទោស ដោយពុំបានកត់នាមក្នុងទីនេះអមដំណើរផង បានអញ្ជើញតាមអាកាសយានជាគូតា ១គ្រឿង ទៅធ្វើទស្សនាចរក្នុងយោធភូមិភាគទី៣ និងទី៤ ។

នៅវេលាអញ្ជើញដល់ក្រុងបាត់ដំបង ក្រោយពីបានទទួលគារវកិច្ចអំពីលោកវរសេនីយទោ សេក-សំអៀត អភិបាលខេត្តបាត់ដំបង និងមេបញ្ជាការយោធភូមិភាគទី៣ អំពីនាយទាហាន និងមន្ត្រីរាជការគ្រប់ក្រុមក្នុងខេត្តហើយ ឯកឧត្តមឧត្តមសេនីយឯកនិងវរជនទាំងអស់ បានអញ្ជើញចូលទស្សនាគេហដ្ឋាន សម្រាប់ភ្ញៀវអស់ពេលយ៉ាងយូរ ។ ក្រោយពីការទស្សនាគេហដ្ឋានសម្រាប់ភ្ញៀវរួចហើយ ឯកឧត្តមឧត្តមសេនីយឯកនិងសហការីទាំងអស់ បានបន្តដំណើរតាមរថយន្តឆ្ពោះទៅកាន់ផ្នែកសិករងថ្មពួក ដែលនៅទីនោះ ឯកឧត្តមបានឲ្យបញ្ញើផ្សេងៗដល់មេបញ្ជាការជាច្រើន ព្រមទាំងចែកអំណោយជាប្រាក់ដល់កុមារ កុមារីជាច្រើនទៀតផង ។ ទើបឯកឧត្តមនិងសហការីអញ្ជើញទៅទស្សនាកន្លែងយកគ្រួស ត្រង់ផ្លូវចូលទៅកាន់បន្ទាយឆ្មា ។ ក្រោយពីឯកឧត្តមបានទស្សនាផ្លូវទៅកាន់បន្ទាយឆ្មា និងក្រោយពីបានធ្វើអំណោយជាប្រាក់ដល់កុមារ កុមារីហើយ ទើបនិវត្តមកកាន់ថ្មពួកវិញ ដោយបានឆ្លៀតអញ្ជើញទៅទស្សនាកន្លែងបម្រុងនឹងស្ថាបនាទំនប់ទឹក ដែលស្ថាបនាឡើងដោយគោរពតាមព្រះនយោបាយដ៏ខ្ពង់ខ្ពស់នៃសម្តេចសហជីវិន ព្រះប្រមុខរដ្ឋ ដែលព្រះអង្គទ្រង់ដឹកនាំកូនចៅឲ្យចាប់អារម្មណ៍ទៅលើនយោបាយទឹកនេះ ។

ថ្ងៃទី២៨ កុម្ភៈ ឯកឧត្តមឧត្តមសេនីយឯកនិងសហការីទាំងអស់បានធ្វើដំណើរតាមឧទ្ធម្ភាគចក្រឆ្ពោះទៅកាន់ក្រុងសៀមរាប នៅទីនោះឯកឧត្តមបានទទួលបដិសណ្ឋារកិច្ចអំពីអភិបាលខេត្ត និងមន្ត្រីរាជការស៊ីវិល-ទាហានដែលនៅរង់ចាំទទួល ទើបឯកឧត្តមនិងសហការី អញ្ជើញទៅទស្សនាការដ្ឋាននៅបន្ទាយស្រី និងនៅស្រែណូយ ដែលនៅទីនោះ ឯកឧត្តមបានឲ្យបញ្ជាដល់អ្នកទទួលខុសត្រូវនៅទីនោះជាច្រើន ។

ថ្ងៃទី១មីនា ឯកឧត្តមនិងសហការីទាំងអស់បានធ្វើដំណើរតាមអាកាសយានជាគូតា ១គ្រឿង និវត្តមកកាន់ក្រុងភ្នំពេញវិញដោយសុវត្ថិភាព ។



ត្រាក់ទ័រកំពុងឈូសឆាយដីស្ថាបនាផ្លូវថ្នល់ពីថ្មពួកទៅបន្ទាយឆ្មា



ឯកឧត្តមឧត្តមសេនីយឯក ញ៉ឹក-ជូឡុង កំពុងពិនិត្យមើលកន្លែងសម្រាប់ស្ថាបនាទំនប់ទឹកនៅថ្មពួក



ការពិនិត្យផែនទី និងឲ្យបញ្ជាដល់អាជ្ញាធរយោធា ចំពោះការស្ថាបនាផ្លូវថ្នល់នៅស្រែណូយ ខេត្តសៀមរាប

# លិខិតថ្លែងអំណរគុណ
# ចំពោះ ឯកឧត្តម ឧត្តមសេនីយឯក ញឹក-ជូឡុង



ឯ.ឧ.ឧត្តមសេនីយឯក ញឹក-ជូឡុង កំពុងចែកអំណោយដល់ពួកខ្មែរលើ



ចំនួនសំលៀកបំពាក់ត្រីអ៊ុទុកចែកជូនកងអាសាស្ម័គ្រនៅតំបន់នោះ

កាលពីថ្ងៃទី១ ដល់ថ្ងៃទី៧ កុម្ភៈ ១៩៦៩ ឯកឧត្តម ឧត្តមសេនីយឯក ញឹក-ជូឡុង អគ្គមេបញ្ជាការ នាយកអគ្គសេនាធិការយោធពលខេមរភូមិន្ទ ដែលមានសហការីជិតស្និទ្ធជូនដំណើរផង បានអញ្ជើញទៅកាន់ខេត្តរតនគិរី ដើម្បីទស្សនាការដ្ឋាននានា និងឲ្យបញ្ជាផ្សេងៗ ។

ក្នុងរយៈវេលានៃការទស្សនានេះ ឯកឧត្តមបានអញ្ជើញទៅទស្សនាចំការកៅស៊ូរដ្ឋ នៅឡាបានសៀក កាលពីថ្ងៃទី ៦ កុម្ភៈ ដើម្បីធ្វើការប្រស្រ័យជាមួយយុវជន-យុវតី កងអាសាស្ម័គ្រ និងបុគ្គលិកចំការកៅស៊ូរដ្ឋ ដែលក្នុងពេលនោះឯកឧត្តម បានធ្វើអំណោយសំលៀកបំពាក់ត្រីអ៊ុ ចំនួន១០០ សម្រាប់ និងប្រាក់១.០០០រៀលដល់កងអាសាស្ម័គ្រ និងប្រាក់១.០០០រៀលទៀត ដល់សិស្សានុសិស្សជាកូនកម្មករ ដែលរៀននៅសាលាបឋមសិក្សាបំពេញវិជ្ជាចំការកៅស៊ូរដ្ឋ ។

ក្រោយពីបានទទួលអំណោយទាំងអស់នេះហើយ សហជីវិនមិន-សារឹម អគ្គនាយកចំការកៅស៊ូរដ្ឋ សហជីវិនប្រាក់-សំអុល នាយកសាលារៀន និងជាប្រធានគណៈកម្មាធិការ សហជីវិន ញ៉ែម-ហេង នាយកចំការកៅស៊ូរដ្ឋ និងជាប្រធានកិត្តិយសនៃគណៈកម្មាធិការ បានផ្ញើលិខិតថ្លែងអំណរគុណ ១ ច្បាប់ចុះថ្ងៃទី២៤ កុម្ភៈ១៩៦៩ មកជូនឯកឧត្តម ឧត្តមសេនីយឯក ញឹក-ជូឡុង មានសេចក្ដីទាំងស្រុងដូចតទៅនេះ :

## សេចក្ដីថ្លែងអំណរគុណ

សូមក្រាបប្រណិប័តន៍ចូលមកឯកឧត្តម ឧត្តមសេនីយឯកអគ្គមេបញ្ជាការ នាយអគ្គសេនាធិការយោធពលខេមរភូមិន្ទ ។

ក្នុងទស្សនកិច្ច ប្រកបដោយអត្ថប្រយោជន៍ដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម នៅចំការកៅស៊ូព្រះសីហនុ នាថ្ងៃទី ៦ កុម្ភៈ ១៩៦៩ ក្រៅពីការសន្ទនា និងដំបូន្មាន ដ៏មានខ្លឹមសារ ដែលឯកឧត្តម បានប្រស្រ័យ ជាមួយ យុវជន-យុវតីកងអាសាស្ម័គ្រអ្នកតស៊ូក្នុងករណីយកិច្ចការពារជាតិមក ឯកឧត្តមបានធ្វើអំណោយដ៏សប្បុរស នូវឯកសណ្ឋាន ១០០ សំរាប់ និងប្រាក់ ១.០០០រៀលដល់កងអាសាស្ម័គ្រ និង ១.០០០ រៀលទៀត ដល់សិស្សានុសិស្សជាកូនចៅកម្មករ រៀននៅសាលាបឋមសិក្សាបំពេញវិជ្ជា ចំការកៅស៊ូព្រះសីហនុ ។ កងអាសាស្ម័គ្រ បានព្រមព្រៀងគ្នាថា នឹងយកប្រាក់អំណោយ ១.០០០រៀលនេះទៅធ្វើកត្រីសមោសរមួយ ដើម្បីជាសក្ខីភាពដល់ការលើកទឹកចិត្ត នៃក្រុមរបស់ខ្លួន ឯអំណោយ ១.០០០រៀលទៀត គណៈកម្មាធិការជំនួយអមកជការ ក្នុងគ្រឹះស្ថានសិក្សាប្រចាំចំការកៅស៊ូព្រះសីហនុ បានចែកដល់សិស្សានុសិស្ស២៩៣ នាក់ រួចជាស្រេចហើយ ។

ព្រហ្មវិហារធម៌របស់ឯកឧត្តម ឧត្តមសេនីយឯកនេះ ធ្វើឲ្យយើងខ្ញុំទាំងឡាយ មានចិត្តរំភើបជាខ្លាំងមហិមា ហើយតាំងចិត្តថានឹងពុះពារគ្រប់ឧបសគ្គ ដើម្បីពង្រីក និងថែរក្សាចំការកៅស៊ូជាសម្បត្តិរដ្ឋ តាមព្រះឱវាទដ៏មហាប្រសើរនៃសម្ដេចឪព្រះបិតាកសិកម្មជាតិ ដរាបអស់អាយុជីវិតរៀងៗខ្លួន ។

ក្នុងនាមនៃកងអាសាស្ម័គ្រ សិស្សានុសិស្ស បុគ្គលិកកម្មករគ្រប់រូបក្នុងចំការកៅស៊ូព្រះសីហនុទាំងមូល យើងខ្ញុំសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិទាំងពួងក្នុងត្រៃលោក មានព្រះរតនត្រ័យដ៏មហាវិសេស និងទេវតាឆ្ពង់មហិទ្ធិមហិស្សរមហាតេជោ រក្សាព្រះមហាស្វេតច្ឆត្រជាប្រធាន ព្រមទាំងទេពធិតាបវរសុគន្ធាទាំងឡាយ សូមទេព្ដាផ្សព្វផ្សាយព្រះតេជៈបារមីប្រសិទ្ធពរជ័យសិរីមង្គលវិបុលសុខ ជូនឯកឧត្តម ឧត្តមសេនីយឯក អគ្គមេបញ្ជាការនៃកងទ័ពជាតិ ឲ្យបានប្រកបដោយព្រះពុទ្ធពរទាំង៤ប្រការ ឈ្នះអស់ពួកឧទ្ទាមមារសត្រូវគ្រប់ទិសទីក្នុងបេសកកម្មដផ្ទៃតាមព្រះមាគ៌ាដឹកនាំដ៏មហារុងរោចន៍ នៃសម្ដេចឪជាអម្ចាស់ជីវិត ដើម្បីរក្សាការពារឯករាជ្យ អព្យាក្រឹត ជាតិសាសនា និងព្រះរាជបល្ល័ង្កឲ្យបានគង់វង្សឋិតថេរអស់កាលជាអង្វែងតទៅកុំបីឃ្លៀងឃ្លាតឡើយ ។

នាយកចំការកៅស៊ូរដ្ឋ<br>និងជា<br>ប្រធានកិត្តិយសនៃគណៈ<br>កម្មាធិការ<br>ហត្ថលេខា: ញ៉ែម-ហេង

ឡាបានសៀក នៅថ្ងៃ<br>ទី ២៤ កុម្ភៈ ១៩៦៩<br>នាយកសាលារៀន<br>និងជា<br>ប្រធានគណៈកម្មាធិការ<br>ហត្ថលេខា: ប្រាក់-សំអុល

អគ្គនាយកចំការកៅស៊ូរដ្ឋ<br>ហត្ថលេខា: មិន-សារឹម

o<br>o o

# កិច្ចការនៅក្រុងនិងខេត្តនានាជាប្រយោជន៍ជាតិ



## ខេត្តតាកែវ

កាលពីថ្ងៃទី ៧ មករា ១៩៦៩ សហជីវិន អភិបាលស្រុក គិរីវង់ លោកមេបញ្ជាការសង្កាត់សិករង់ លោកអនុវិទ្យាល័យ មេបញ្ជាការផ្នែកកងពលតម្រួត នាយមណ្ឌលកសិកម្មស្រុក នាយកបឋមសិក្សា ចៅសង្កាត់ព្រៃអំពក គណៈកម្មការភូមិឃុំនិងប្រជាពលរដ្ឋមកពីភូមិសុបិននិងព្រៃអំពក បានមករួបរួមគ្នាធ្វើការហត្ថកម្មពេញមួយថ្ងៃ នៅសង្កាត់ព្រៃអំពកស្រុកគិរីវង់ "តាកែវ" ដែលមានហត្ថករចំនួន ៤០ នាក់ ។

ឯលទ្ធផល បានមកពីការហត្ថកម្មនេះ មានដូចខាងក្រោម :

ច្រូតស្រូវបានផ្ទៃដីស្រែ ១៦ ៣២ ម៉ែត្រក្រឡា :

ស្រូវច្រូតចងផលបាន : ១៤ ថាំង ។

សូមបញ្ជាក់ថា : ក្រុមហត្ថករមិនគ្រាន់តែជួយច្រូតស្រូវប៉ុណ្ណោះទេ គឺបាននាំគ្នាបោកបែនកណ្តាលលំហាលស្រែនិងអុំពេយជញ្ជូនដាក់រទេះរួចដឹកដល់ជង្រុកអ្នកម្ចាស់ស្រែផងទៀត ។

បន្ទាប់មកភ្នាក់ងារកសិកម្មប្រចាំស្រុកក៏បានបញ្ជាដល់កសិករ ឲ្យភ្ជួរបង្កប់គល់ជញ្ជ្រាំង ដើម្បីឲ្យពុករលួយនិងដាំសណ្តែកអង្គុយទុកធ្វើជាដីស្រស់ សម្រាប់ដំណាំស្រូវនារដូវឆ្នាំក្រោយទៀត ។

កិច្ចប្រតិបត្តិការនេះយើងបានប្រព្រឹត្តទៅចាប់ពីម៉ោង ៨ ព្រឹករហូតដល់ម៉ោង ១៤ រសៀលប្រកបដោយបរិយាកាសដ៏សែនរីករាយជាទីបំផុត ។



កាលពីថ្ងៃទី ១១ មករា ១៩៦៩ សហ-កុប គិមគីន អភិបាលស្រុកគីរីវង់ និងលោកស្រី លោកមេបញ្ជាការផ្នែកសិករង់ និងលោកស្រី លោកបាឡាត់ស្រុក និងលោកស្រី លោកមេបញ្ជាការកងពលតម្រួត លោកនាយកអនុវិទ្យាល័យ លោកនាយកបឋម-សិក្សានិងសិស្សានុសិស្ស លោកនាយមណ្ឌលកសិកម្មស្រុក និងប្រជាពលរដ្ឋខ្មែរចិនយួនចំនួន ៤០០ នាក់ បានរួបរួមធ្វើការហត្ថកម្មជីកប្រឡាយទឹកពេញមួយថ្ងៃ នៅសង្កាត់ព្រៃរំដេង បណ្តោយប្រវែងជាង ១.០០០ម ទទឹង ៤ម និងជំរៅ ២ម ហើយកិច្ចការនេះនិងបន្តទៅទៀតលុះត្រាតែបានសំរេចជាស្ថាពរ ។ សូមបញ្ជាក់ថា: ការហត្ថកម្មជីកប្រឡាយទឹកនេះ គឺជាកន្លែងការដ្ឋានហត្ថកម្មសម្រាប់ឆ្នាំ ១៩៦៩ ផង ។

សហជីវិន អភិបាលស្រុកបានសម្រេចថា: និងចាប់ធ្វើការហត្ថកម្មជីកប្រឡាយទឹកនេះមួយសប្តាហ៍ម្តងៗរៀងរាល់ថ្ងៃសៅរ៍តទៅ ។

## ខេត្តកំពង់ធំ

កាលពីថ្ងៃទី ១៣ ធ្នូ ១៩៦៨ ពេលម៉ោង ១០ ព្រឹក នៅកន្លែងសាលាស្រុកកំពង់ស្វាយចាស់ជាប់នឹងមន្ទីរពេទ្យកំពង់ធំក្រុង មានធ្វើពិធីបញ្ចុះបឋមគ្រឹះ នៃការស្ថាបនាមន្ទីរពេទ្យព្រះសង្ឃ ក្រោមអធិបតីភាពនៃសហជីវិន ពូ-គុងហាវ អភិបាលខេត្ត ដោយមានព្រះគ្រូមេគណខេត្ត-ព្រះគ្រូអនុគណគ្រប់ស្រុក ព្រះគ្រូធម្មចរិយាព្រឹទ្ធកែវ-អ៊ុំ និងចៅអធិការគ្រប់វត្ត នាយក្រុមរាជការគ្រប់ក្រុមបានចូលរួមផង ។

បន្ទាប់ពីបានជួបជុំហើយ សហជីវិន អភិបាលខេត្ត បាននិមន្តព្រះគ្រូមេគណខេត្ត អនុគណ និងព្រះសង្ឃទាំងអស់ចំនួន ២០៨ អង្គ ស្វាធ្យាយធម៌ជយន្តោ បើកពិធីបញ្ចុះបឋមគ្រឹះជានិមិត្តរូបនៃការស្ថាបនាមន្ទីរពេទ្យព្រះសង្ឃនេះ ។ លុះចប់ពិធីនេះហើយ ដល់ម៉ោង ១១ សហជីវិនអភិបាលខេត្ត និងលោកស្រី ព្រមទាំងអ្នករាជការនិងពុទ្ធ-បរិស័ទក្នុងទីក្រុងកំពង់ធំចូលរួមផង បានរៀបចំប្រគេនចង្ហាន់ព្រះសង្ឃចំនួន ២០៨ អង្គ នៅសណ្ឋាគារខេត្ត ក្នុងបរិយាកាសដ៏អ៊ឹកធឹកយ៉ាងក្រៃលែង ។

ក្រោយពីបានប្រគេនចង្ហាន់ថ្ងៃត្រង់ចំពោះព្រះសង្ឃគ្រប់អង្គនៅសណ្ឋាគារខេត្តរួចហើយ ការប្រជុំក៏បានចាប់ផ្តើមនៅម៉ោង ១៥ នៅក្នុងសាលាធម្មវិន័យវត្តស្រយូវ ដោយមានព្រះគ្រូមេគណខេត្ត - ព្រះគ្រូធម្ម-ចរិយាព្រឹទ្ធកែវ-អ៊ុំ ព្រះគ្រូអនុគណគ្រប់ស្រុក ចៅអធិការគ្រប់វត្ត .. និងនាយក្រុម



រាជការក្នុងខេត្តគ្រប់ក្រុម ព្រមទាំងឧបាសកឧបាសិកាចំណុះជើងវត្តជាច្រើន បានអញ្ជើញមកចូលរួមផង ។

លុះថ្វាយបង្គំព្រះសង្ឃរួចហើយសហ-ជីវិនអភិបាលខេត្ត បាននាំនូវសេចក្ដីនឹករលឹកនៃសម្ដេចព្រះមាតាជាតិ និងសម្ដេចឪ មកថ្វាយបង្គំព្រះសង្ឃ និងជំរាបដល់ប្រជាពលរដ្ឋជាកូនចៅរបស់ព្រះអង្គ ។ រួចទើបផ្ដើមធ្វើសន្និសីទស្ដីអំពីបញ្ហាទាំងឡាយដែលមានចុះក្នុងរបៀបវារៈមានជាអាទិ៍ :

១– ការរៀបចំលំអស្រុក-ភូមិ

២– រក្សានិងការពារព្រៃឈើ និងដាំឡើងវិញ

៣– បង្កើនផលិតផលកសិកម្ម

៤– ពង្រីកនយោបាយទឹក

៥– ការពង្រីកកីឡា

៦– ពង្រីកគមនាគមន៍

៧– ការជួយរៀបចំ និងពន្យល់អំពីករណីយកិច្ចមេឃុំ ១០ ខ្ទង់

៨– ការតែងតាំងលោកគ្រូចៅអធិការគ្រប់វត្ត ដើម្បីជួយអប់រំប្រជាពលរដ្ឋក្នុងកិច្ចកសាងសមិទ្ធិនិងវិស័យផ្សេងៗ

៩– បញ្ហាសេដ្ឋកិច្ច

១០– សង្គមកិច្ច

សហជីវិនអភិបាលខេត្ត បានធ្វើអត្ថាធិប្បាយវែងញែកក្នុងបញ្ហានីមួយៗយ៉ាងក្បោះក្បាយ ព្រមទាំងទាញយកឧទាហរណ៍សំខាន់ៗនៃការលូតលាស់គ្រប់វិស័យដែលក្រសួងនីមួយៗបានវិតខំបំរើជាតិ ដោយអនុវត្តតាមព្រះរាជនយោបាយដ៏ខ្ពង់ខ្ពស់នៃសម្ដេចឪ ។

- នៅទីបញ្ចប់ សហជីវិនអភិបាលខេត្ត បានលើកយកបុញ្ញរាសី ដែលកើតឡើងអំពីពិធីនេះថ្វាយចំពោះសម្ដេចព្រះមាតាជាតិ និងសម្ដេចឪ សូមព្រះអង្គទ្រង់ប្រកបដោយជោគជ័យសិរីមង្គលវិបុលសុខគ្រប់ប្រការ និងមានព្រះជន្មាយុយឺនយូររាប់រយព្រះវស្សា ឈ្នះអស់មារសត្រូវគ្រប់ទិសទី ដើម្បីទ្រង់គង់ជាម្លប់ដ៏ត្រជាក់នៃប្រជាពលរដ្ឋជាកូនចៅតរៀងទៅ ។

❖



កាលពីថ្ងៃទី៧មករា១៩៦៩សហជីវិនពូ-គុនហាវ អភិបាលខេត្តកំពង់ធំ ដោយមានសហជីវិនម៉ែន-ស៊ុមៀក អភិបាលខេត្តរងទី២ សហជីវិនតា-ស៊ុន្ទារិទ្ធិ នាយផ្នែកសាធារណការ សហជីវិនមាស-ចាន់ស៊ុណ្ហូ នាយតំបន់បសុពេទ្យជូនដំណើរផង ទៅពិនិត្យគំរោងការប្រឡាយទឹកនៅតំបន់តាំងគោក និងដោយមានសហជីវិនប៊ុច-សាន ចៅតំបន់រដ្ឋបាលតាំងគោក អនុសេនីយត្រី ជា-ស៊ុន្ទីមេ បញ្ជាការ ក-វ-ត សហជីវិនអ៊ុម-ហ៊ុំបដិគ្គាហកប្រៃសណីយ៍, សហជីវិនគិម-ស៊ុយ៉ង់ នាយកវិទ្យាល័យព្រះបិតាអប់រំជាតិតាំងគោក, សហជីវិនម៉ម-ញ៉ុកអធិការកិច្ចតំបន់តាំងគោក ចូលរួមផង បានទៅពិនិត្យគំរោងការប្រឡាយទឹក នៅសង្កាត់ជ្រលង, សង្កាត់សូយោង, ស្វាយក្លើង, សង្កាត់ពង្រ ដែលប្រជាពលរដ្ឋក្នុងស្រុកកំពុងតែធ្វើការហត្ថកម្មជីកប្រឡាយទឹកទាំងអស់នេះ ជារៀងរាល់ថ្ងៃ, ពិសេសសហជីវិនអភិបាលខេត្តបានទាំងធ្វើអំណោយចំនួន១០.០០០រៀលដល់គណៈកម្មការ នៅសង្កាត់ជ្រលង ដើម្បីការពារទំនប់និងធ្វើឲ្យបានស្រេចក្នុងពេលឆាប់ៗនេះ ។

ម្យ៉ាងទៀត ប្រជាកស្ត្រនៅសង្កាត់សូយោង-ពង្រ-ស្វាយក្លើង បានធ្វើសំណូមពរចំពោះសហជីវិនអភិបាលខេត្តឲ្យបានជីកប្រឡាយទឹកតាមបណ្ដោយថ្នល់ជាតិ ដើម្បីបានទឹកប្រើប្រាស់តទៅ ។ សហជីវិនអភិ-បាលខេត្តបានសន្យាថា និងជួយ១០.០០០រ ថែមលើសំណូមពរនេះទៀតផង ក្នុងការស្ថាបនាជីកប្រឡាយទឹកនេះ ។

o

o o

កាលពីថ្ងៃទី ១១ មករា ១៩៦៩ ព្រះតេជព្រះគុណមេគណខេត្ត ព្រះតេជព្រះគុណអនុគណស្រុកកំពង់ស្វាយនិងភិក្ខុសាមណេរជាច្រើនអង្គទៀត ហើយនិងមានមន្ត្រីរាជការគ្រប់ក្រុមក្នុងខេត្ត ប្រជាពលរដ្ឋចិន-យួនចំនួន ៧ ភូមិ រួមទាំងអស់ចំនួន៤.០០០នាក់ ក្រោមការដឹកនាំនៃសហជីវិនពូ-គុនហាវ អភិបាលខេត្តបានធ្វើការហត្ថកម្មជីកប្រឡាយទឹកមានបណ្ដោយ ១.១០០ ទទឹង ៤ម. ជម្រៅបាតក្រោម ២ម.។ ក្រុមហត្ថករទាំងនេះធ្វើការជីកប្រឡាយទឹក បានលទ្ធផលបណ្ដោយ៧០០ម ហើយនៅសល់ខ្លះទៀត បានសន្យាថានឹងធ្វើបន្តទៅថ្ងៃក្រោយ លុះត្រាតែបានបានហើយស្រេចជាស្ថាពរ ។

o

o o



# សកម្មភាពនៃក្រុមអន្តរាគមន៍កសិកម្មសម្ដេចឪ

**កំណត់ការិយាល័យនិពន្ធ.** - យើងសូម ចុះផ្សាយខាងក្រោមនេះ នូវសេចក្ដីរបាយការណ៍របស់សហជីវិន និន-នីរ៉ុម នាយក្រុមអន្តរាគមន៍កសិកម្មនៃសម្ដេចឪ ផ្ញើទៅជូនសហជីវិន អ៊ឹង-ហុងសាត ឧបនាយករដ្ឋមន្ត្រីទី២ ទទួលបន្ទុកក្រសួងមហាផ្ទៃ រៀបរាប់អំពីសកម្មភាពនៃ ក្រុមអន្តរាគមន៍នេះនៅក្នុងខេត្តពោធិ៍សាត់ ។

**សូមក្រាបប្រណិប័តន៍ចូល មក សហជីវិន ឧបនាយករដ្ឋមន្ត្រីទី២, នាយកក្រុមអន្តរាគមន៍កសិកម្មនៃសម្ដេចឪ**

**សូមធានថ្វាយ**

កាលពីថ្ងៃទី ១០ ទៅ ១១ កុម្ភៈ ១៩៦៩ ខ្ញុំបាទ បានទៅប្រជុំ ជាមួយ សហជីវិន អភិបាលខេត្ត ពោធិ៍សាត់ ក្នុងការអនុវត្តន៍នយោបាយទឹក :

**១– នៅភូមិធំរំសៀម សង្កាត់ផ្សារលើ ស្រុកបាកាន**

មានការជួបជុំព្រះសង្ឃសមាជិកសហករណ៍ មានចំនួនប្រមាណជាមួយរយនាក់ ដើម្បីពិភាក្សាគម្រោងបាយដីកប្រឡាយទឹកមួយពីស្ទឹងពោធិ៍សាត់កាត់ទៅរនាមគោក ដែលមានបណ្ដោយប្រវែង ៣.០០០ ម៉ែត្រ ឯប្រឡាយទឹកនេះអាចនឹងធ្វើស្រែបានចំនួន ៤០០ ហិកតារ ។ ក្នុងអង្គប្រជុំគេសង្កេតឃើញលោកគ្រូស៊ិន-សួន ចៅអធិការវត្តហង្ស លោកគ្រូអ៊ុំ-ពៀប ចៅអធិការវត្តពោធិ៍មានបុណ្យ និងសហជីវិនឈឹម-ឆាន់ ប្រធានសហករណ៍ត្រកៀបក្ដាម ។ សហជីវិនរូបនេះបានជម្រាបអង្គប្រជុំថា ប្រជាកសិករជាកូនចៅសម្ដេចឪ ទាំងព្រះសង្ឃ ទាំងប្រជារាស្ត្រ បានប្ដេជ្ញាថានឹងចាប់ដីកប្រឡាយទឹកនេះនៅថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ១៩៦៩ ។

**២.– នៅបឹងព្រះពន្លៃ សង្កាត់ព្រះពន្លៃ ស្រុកលាច** នៅទីនោះ ក៏មានការប្រជុំព្រះសង្ឃ និងប្រជាកសិករ ចំនួនប្រមាណ ១.៥០០ នាក់ បានរួបរួមគ្នាធ្វើការហត្ថកម្មស្ថាបនាទំនប់ទឹកមួយ ហៅថាទំនប់ទឹកព្រះ [illegible] ត្រូវមានបណ្ដោយ ៣០០ ម៉ែត្រ កំពស់ ៣ ម៉ែត្រ បាតក្រោម ១៦ ម៉ែត្រ និងខ្នងលើប្រវែង ៨ ម៉ែត្រ ។ ទំនប់ទឹកនេះអាចនឹងទុកទឹកបានចំនួន ៥.០៤០.០០០ ម៉ែត្រគូប ហើយអាចនឹងធ្វើស្រែបានចំនួន ៤០០ ហិកតារ ។ នៅក្នុងចំណោមព្រះសង្ឃគេសង្កេតឃើញលោកគ្រូកែវ-សំអ៊ុន ចៅអធិការវត្តកំពង់ដំរី, លោកគ្រូសែន-តែម ចៅអធិការវត្តព្រះជ័យចេស្ដា លោកគ្រូ ប៉ែន-សួន វត្តព្រះហស្តក្បាល លោកគ្រូសំ-សារ៉ាន់ វត្តសិរីមានជ័យ ដែលជាប្រធានគណៈកម្មការលើកទំនប់ទឹកនេះ ។

**៣– ភូមិចាប់ផ្ទាំង សង្កាត់តាលោ ស្រុកបាកាន**

ព្រះសង្ឃនិងប្រជាកសិករចំនួនប្រមាណ ១.៣០០នាក់បានធ្វើការហត្ថកម្មលើកទំនប់ទឹកមួយឈ្មោះហៅថាទំនប់ទឹកអូរចាប់ផ្ទាំងដែលមានបណ្ដោយ ១.២០០ ម៉ែត្រ កំពស់២ម៉ែត្រ បាតក្រោម ៦ ម៉ែត្រ និងខ្នងលើ ៣ ម៉ែត្រ ។ ទំនប់ទឹកនេះបានផ្ដល់ទឹកឲ្យធ្វើស្រែបានចំនួនប្រមាណជា៣០០ ហិកតារ ហើយទំនប់ទឹកនេះអាចធ្វើជាផ្លូវលំភ្ជាប់ពីវត្តមហាត្រុក្ខាកមទៅតាលោ លោកគ្រូផូ-ឡុង ចៅអធិការវត្តព្រៃពេង និងលោកគ្រូ អ៊ុំ ង៉ួន ចៅអធិការវត្តមហាត្រុក្ខាកម ហៅព្រាបបជា ជាប្រធានគណៈកម្មការធ្វើទំនប់ទឹកនេះ ។

**៤– ភូមិតាលោ សង្កាត់តាលោ ស្រុកបាកាន**

នៅភូមិតាលោ លោកគ្រូ ឌុង-ប៉ៃ ចៅអធិការវត្តតាលោ កំពុងតែស្ថាបនា:

ក– ផ្ទះពេទ្យមួយខ្នងអំពីឥដ្ឋប្រក់ក្បឿង មានបណ្ដោយ ១៦ ម និងទទឹង ១០ម៉ែត្រ ។

ខ– ស្រះ ២ គឺមួយមានទំហំ ១៥០ ម៉ែត្របណ្ដោយ និងទទឹង ៨០ ម៉ែត្រ ហើយស្រះមួយទៀតមានបណ្ដោយ ៨០ ម៉ែត្រ និង



កិច្ចប្រជុំការងារស្ដីអំពីបញ្ហាជីកប្រឡាយទឹកពីស្ទឹងពោធិ៍សាត់ទៅរនាមគោក



▲ ប្រឡាយទឹកដែលត្រូវជីក



▲ ការចូលរួមប្រជុំជាមួយព្រះសង្ឃនិងគណៈកម្មការលើកទំនប់ទឹក



ដំរំហត្ថករស្ម័គ្រចិត្តសម្រាប់ឈប់សម្រាកយកកម្លាំង ▲



ហត្ថករស្រី ប្រុសកំពុងធ្វើការហត្ថកម្មដោយសេចក្តីរីករាយ ▲



ទិដ្ឋភាពទំនប់ទឹកមើលពីក្រោយបឹងព្រះពន្លៃ ▲



ទិដ្ឋភាពនៃការដ្ឋានជីកទំនប់ទឹកនាថ្ងៃទី ១១ កុម្ភៈ ១៩៦៩ ▲

ទទឹង ៥០ ម៉ែត្រ ។

## ៥– នៅវត្តស្រោង សង្កាត់តាលោ ស្រុកបាកាន

ព្រះគ្រូចៅអធិការវត្តស្រោង សង្កាត់តាលោ កំពុងតែស្ថាបនាផ្លូវលំមួយដែលមានបណ្តោយ ៤.០០០ ម៉ែត្រ ទទឹង ៤ ម៉ែត្រ និងកំពស់ កន្លះម៉ែត្រ ។

ការស្ថាបនាសមិទ្ធិផលទាំងនេះ គឺជាស្នាដៃរបស់សហជីវិនវរសេនីយ៍ទោ ផែង-ឡៃ យ៉ុម អភិបាលខេត្តពោធិ៍សាត់ ជាអ្នកដឹកនាំ ដោយធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ជាមួយនឹងព្រះសង្ឃ មន្ត្រីក្នុងខេត្ត និងប្រជាកសិករគ្រប់ឋានៈ ។

ខ្ញុំសូមជំរាបបញ្ជាក់ថា ខេត្តពោធិ៍សាត់ គ្មានគ្រឿងចក្រកសិកម្មមួយទាល់តែសោះ ឯសមិទ្ធិទាំងប៉ុន្មានកើតឡើងដោយសារកម្លាំងញើសនិងចប-បង្គីរបស់ហត្ថករស្ម័គ្រចិត្តតែមួង ។

អាស្រ័យហេតុនេះ ហត្ថករស្ម័គ្រចិត្តទាំង ៥ ការដ្ឋាន សុំឲ្យខ្ញុំជម្រាបសហជីវិន ដើម្បីឲ្យទូលសុំសម្តេចឪជាអម្ចាស់នូវព្រះរាជអំណោយដូចតទៅនេះ គឺ :

ចបកាប់ចំនួន ៥០០ សម្រាប់ ៥ ការដ្ឋាន

បង្គី ចំនួន ៥០០ គូ សម្រាប់ ៥ ការដ្ឋាន ។

តាមទំហំនិងចំនួនទំនប់ទឹក ប្រឡាយទឹកដែលត្រូវស្ថាបនានៅខេត្តពោធិ៍សាត់នោះ គួរណាស់តែខេត្តនេះ ត្រូវមានយ៉ាងហោចណាស់ *TRACTEUR-EXCAVATEUR* មួយគ្រឿង ដើម្បីការដ្ឋានខ្លះអាចនឹងបង្ហើយការមុនរដូវភ្លៀង ។

នៅការដ្ឋានទីមួយ ៗ សហជីវិន ផែង-ឡៃ យ៉ុម បានពន្យល់រាស្ត្រឲ្យរួបរួមគ្នាក្នុងការធ្វើនយោបាយទឹក ដែលសម្តេចឪជាអម្ចាស់បានដឹកនាំ ។

បំណែកខ្ញុំបាទ ខ្ញុំបាទបាននាំសេចក្តីនឹករលឹករបស់សម្តេចព្រះមហាក្សត្រិយានីព្រះមាតាជាតិ និងសម្តេចឪជាអម្ចាស់ទៅប្រគេនព្រះសង្ឃ និងប្រជាកសិករទាំងអស់គ្នា ហើយនិងបានបញ្ជាក់ថា សម្តេចឪជាអម្ចាស់ស្រឡាញ់កូនចៅ ព្រះអង្គស្មើនឹង ព្រះមាតាព្រះអង្គ ខ្ញុំបាទក៏បានរំលឹកនូវព្រះរាជបណ្តាំដ៏ថ្លៃថ្លា គឺបញ្ចសីលា :

១ – ឯករាជភាព

២ – បូរណភាពទឹកដី

៣ – អព្យាក្រឹតភាព

៤ – អ្នកជាតិនិយម

៥ – សង្គមរាស្ត្រនិយម និយមព្រះពុទ្ធសាសនា

នៅគ្រប់ទីកន្លែង ព្រះសង្ឃនិ



▲

ព្រះសង្ឃសូត្រធម៌ជ័យមង្គល ព្រះពុទ្ធមន្តជាកិច្ចប្រសិទ្ធីបើកការដ្ឋានទំនប់ទឹកនៅភូមិចាប់ផ្ទាំង



▲

ព្រះសង្ឃក៏ស្ម័គ្រព្រះទ័យចូលរួមក្នុងការហត្ថកម្មនេះដែរ

ពលរដ្ឋ មានសេចក្ដីត្រេកអរជាអតិបរមានូវព្រះរាជបណ្ណាំដែលខ្ញុំបាទបាននាំទៅប្រគេន និងជូនៗ ហើយព្រះសង្ឃ និងប្រជាពលរដ្ឋបានសុំឲ្យខ្ញុំបាទនាំសេចក្ដីនឹករលឹក សេចក្ដីស្មោះត្រង់ក្នុងការដឹងគុណព្រះរាជនយោបាយមកថ្វាយសម្ដេចព្រះមហាក្សត្រិយានី ព្រះមាតាជាតិ និងសម្ដេចឪជាអម្ចាស់ ហើយបានប្ដេជ្ញាថានឹងគាំទ្រលុះត្រាអវសាននៃជីវិតបង់ នូវព្រះរាជបល្ល័ង្កជាតិ ព្រះពុទ្ធសាសនា និងមហាចលនាសង្គមរាស្ត្រនិយម ដែលសម្ដេចឪជាអម្ចាស់ទ្រង់ជាប្រធាន ។ ក្មួនចៅព្រះអង្គទាំងអស់គ្នាបានដឹងច្បាស់ថា ចលនាខៀវ-ក្រហម ជាចលនាក្បត់ជាតិ នាំជាតិឲ្យធ្លាក់ទៅក្នុងមហន្តរាយ និងទាសភាពរបស់មហាយក្ស ចំណែកឯចលនាសង្គមរាស្ត្រនិយមគឺជាចលនានាំឲ្យជាតិសុខចំរើនគ្រប់បែបយ៉ាងៗ

សូមសហជីវិនទទួលសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។




▲

ផែនទីនៃទំនប់នានាដែលត្រូវធ្វើឲ្យសម្រេចឡើងក្នុងពេលឆាប់ៗនេះ

# ការនាំចូលនូវទំនិញតាមរបៀប
# «ការដូរដោយបង់ពន្ធ»

**កំណត់ក្រុមអ្នកនិពន្ធ:** យើងសូមចុះផ្សាយខាងក្រោមនេះ នូវលិខិតរបស់ សហជីវិន ស្រី-ប៊ុង រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មនិងផែនការ ផ្ញើជូនចំពោះរដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ ដែលបានស្នើនូវវិធានការ ដើម្បីទប់កុំឲ្យមានការរំលោភ នាំឲ្យខូចប្រយោជន៍នៃសេដ្ឋកិច្ចជាតិ មកពីរបៀប «ការដូរដោយបង់ពន្ធ»នេះទៅថ្ងៃមុខ ។

*ខ្ញុំសូមជំរាបសហជីវិនថា របៀប"ការដូរដោយបង់ពន្ធ"ដែលបានប្រព្រឹត្តមកទល់សព្វថ្ងៃនេះ នាំឲ្យមានការនាំចូលមកក្នុងប្រទេសកម្ពុជាយើង នូវផលិតផលដែលប្រណាំងប្រជែងយ៉ាងខ្លាំង ជាមួយនឹងផលិតផលនៃឧស្សាហកម្មជាតិ ហើយជាផលិតផលដែលត្រូវហាមឃាត់មិនឲ្យនាំចូលក្នុងកិច្ចការពារផលិតកម្មជាតិ ដូចជាកំណាត់សំពត់ ផ្ទួយ កំណាត់សំពត់ធ្វើដំបូលរថយន្ត បំពង់ កំណាត់ និងស្បែកធ្វើពីជាតិផ្លាស្ទិក ឬកំណាត់ដែលមានបញ្ចូលជាតិផ្លាស្ទិក និងផលិតផលផ្សេងទៀត ដែលប្រណាំងនឹងផលិតផលនាំចូល តាមរបៀបការទូទាត់ "ម៉ូតូ" ។*

*ដើម្បីនឹងបន្ថយឲ្យពេញទំហឹងដែលអាចនឹងធ្វើបាននូវផលអាក្រក់ខាងផ្នែកសេដ្ឋកិច្ច ដែលបណ្ដាលមកពីរបៀបការដូរនេះ ខ្ញុំសូមសហជីវិនមេត្តាលុបចោលនូវបញ្ជីលើកមុននៃផលិតផល ដែលហាមឃាត់ពុំឲ្យនាំចូលតាមរបៀប "ការដូរដោយបង់ពន្ធ"* **ហើយឱ្យយកបញ្ជីថ្មី នៃផលិតផលដែលអនុញ្ញាតឲ្យនាំចូល តាមរបៀបការដូរដោយបង់ពន្ធមកវិញ** *ដែលមានសេចក្ដីស្នើមកជាមួយនេះ ។*

*វត្ថុធាតុទាំងអស់ បានត្រូវហាមឃាត់មិនឲ្យនាំចូលនិងនាំចេញពីប្រទេសកម្ពុជា តាមព្រះរាជក្រមលេខ ៩២៩ ន.ស. ចុះថ្ងៃទី ១០ កុម្ភៈ ១៩៥៥ "មាត្រា ២" ស្ដីអំពីពាណិជ្ជកម្មក្រៅប្រទេសនិងការប្ដូរប្រាក់ ហើយត្រូវតែធ្វើតាមវត្ថុធាតុ ដែលអនុញ្ញាតឲ្យនាំចេញតាមរបៀបប្ដូរ របស់ដោយយកពន្ធ ដើម្បីលុបចោលការហាមឃាត់ទូទៅ អាចសម្រេចបានក្នុងក្របខ័ណ្ឌនៃរបៀបប្ដូរប្រាក់ ។*

*តាមការអនុវត្តទូទៅ អាជ្ញាប័ណ្ណឬសំបុត្រអនុញ្ញាតលុបចោលការហាមឃាត់ជាទូទៅ ។ តែប្រសិនបើគេមិនទម្លាប់ហាមឃាត់វត្ថុធាតុដដែល ដោយប្រើប្រកាសឬច្បាប់ណាមួយនោះ គឺក្នុងគោលបំណងដើម្បីចៀសវាងការកេងប្រវ័ញ្ចរបស់អ្នកជំនួញ ដែលជឿខុសថាខ្លួនអាចនាំចូលឬនាំចេញ នូវទំនិញទាំងអស់តាមពាក្យសុំរបស់ខ្លួនតែប៉ុណ្ណោះ ។*

ο

ο ο




និចសុន: «ទេ ! ទេ ! ទេ ! ខ្ញុំមិនចង់ធ្វើអាជ្ញាកណ្ដាលទេ ! »
**NIXON:** «Non! non! non! je ne veux pas être arbitre»

# ពិធីបើកការដ្ឋានទំនប់ទឹក

## «អូរអំពាន» (ព្រៃវែង)

សម្តេចឪព្រះបិតាកសិកម្មជាតិ ទ្រង់បានប្រោសព្រះរាជទាន នូវព្រះរាជទ្រព្យចំនួន ៥០.០០០រ.០០ ជាជំនួយដល់កូនចៅព្រះអង្គ ក្នុងការកសាងទំនប់ទឹក នៅអូរអំពាន (ព្រៃវែង) ។ កិច្ចចាត់ចែងការនេះ គឺសហជីវិន យឹម-ឌិត ដែលបានទទួលព្រះរាជបញ្ជា បានអញ្ជើញទៅជាអធិបតី ដោយមានសហប្រតិបត្តិការយ៉ាងជិតស្និទ្ធ ពីព្រះសង្ឃ, មន្ត្រីរាជការ យុវជន, យុវតីនិងប្រជាពលរដ្ឋ គ្រប់ជាន់ថ្នាក់នៅក្នុងខេត្ត ។ ក្នុងឱកាសដែលព្រះសង្ឃ ប្រជាពលរដ្ឋ-មន្ត្រី-អ្នករាជការ-ទាហាន ស៊ីវិល បានអញ្ជើញមកជួបជុំ ហើយមានពិធីគោរពទង់ជាតិ រួចទើបសហជីវិនយឹម-ឌិត បានថ្លែងសុន្ទរកថាមួយ អំពីព្រះមហាវិរិយភាពនៃសម្តេចឪ ដែលទ្រង់ពុំដែលមានល្ហែ ក្នុងពេលណាមួយសោះ ក្នុងការជួយកូនចៅកសិករឲ្យមានទឹកធ្វើស្រែ-ចំការ-ច្បារដំណាំគ្រប់ប្រភេទ ។ ឧទាហរណ៍ដូចជាទ្រង់បានប្រោសព្រះរាជទាន នូវព្រះរាជទ្រព្យ ចំនួន ៥០.០០០រ០០មកបងប្អូនរួមជាតិ ក្នុងការកសាងទំនប់ទឹកនេះ ។ សហជីវិនយឹម-ឌិត បានថ្លែងនូវសេចក្តីផ្តាំផ្ញើនៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូងនិងសម្តេចឪ មកសួរសុខទុក្ខបងប្អូនរួមជាតិទាំងអស់ដែលនៅទីនេះ ថាព្រះអង្គទ្រង់នឹករលឹកមកកូនចៅខ្លាំងណាស់ - ព្រះអង្គទ្រង់ប្រសិទ្ធិពរ



ពិធីគោរពទង់ជាតិ មុនកិច្ចប្រតិបត្តិការហត្ថកម្មជីកទំនប់ទឹកអូរអំពាន



សហជីវិន យឹម-ឌិត ថ្លែងសុន្ទរកថារៀបរាប់អំពីព្រះមហាវិរិយភាពនៃសម្តេចឪក្នុងការជួយកូនចៅកសិករឲ្យមានទឹកធ្វើស្រែចំការច្បារដំណាំ



សហជីវិនព្រះរាជបំរើដោយមានសហជីវិន តឹក-ប៊ូ អភិបាលខេត្តព្រៃវែងជូនដំណើរផង បាននិមន្តព្រះសង្ឃទៅទស្សនាការដ្ឋានជីកទំនប់ទឹកនេះ



ការធ្វើដំណើរទៅកាន់ការដ្ឋានជីកទំនប់ទឹកនៅអូរអំពាន



ការហត្ថកម្មកំពុងតែប្រព្រឹត្តទៅយ៉ាងសកម្ម



ទិដ្ឋភាពដ៏ធំធេងដែលហាក់សន្ធឹងនៅជុំវិញទំនប់ទឹកដ៏សំខាន់នេះ



ហត្ថករស្ម័គ្រចិត្តទាំងឡាយបានប្រកបកិច្ចការនេះដោយសប្បាយរីករាយឥតឧបមា

ផ្ញើមកជូនកូនចៅថា : សូមឲ្យប្រកបដោយពុទ្ធពរ ៤ ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

នៅទីបញ្ចប់ សហជីវិន យឹម-ឌិត បានថ្វាយកុសលកសិ ចំពោះសម្តេចព្រះមហាក្សត្រិយានីជាម្ចាស់ជីវិតលើត្បូង និងចំពោះសម្តេចព្រះប្រមុខរដ្ឋ សូមព្រះអង្គទ្រង់ប្រកបដោយពុទ្ធពរទាំង ៤ ប្រការ គឺព្រះទីឃាយុ ព្រះឆវិវណ្ណ ព្រះសុខមាលភាព ព្រះពលភាព និងព្រះបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

សូមជ្រាបថា ទំនប់ទឹកនេះមាន ៖

បណ្តោយ . . . ៧៤០ម០០

ទទឹងខាងខ្នង . . . ៤ម០០

ទទឹងជើងក្រោម ១២ម០០

កំពស់ ៣/២

ចំនួនអាចម៍ដី ៤.១៤០ម$^{៣}$

ទំនប់ទឹកនេះកាលណាស្ថាបនាហើយ អាចផ្តល់ទឹកដល់ស្រែចំនួន ២០០ ហិកតា

អាចផ្តល់ទឹកប្រើប្រាស់ សម្រាប់កសិករនិងសត្វពាហនៈ អាចផ្តល់នូវការដឹកនាំតាមដើងទឹកក្នុងរដូវទឹកជំនន់ អាចផ្តល់នូវជីវភាពចំពោះដំណាំចំការផ្សេងៗទៀតក្នុងរដូវ ហើយនិង អាចផ្តល់នូវផ្លូវគមនាគមពីភូមិមួយទៅភូមិមួយតាមអូរអំពាននេះ ។

ទិដ្ឋភាពនៃការដ្ឋានជីកទំនប់ទឹកនាថ្ងៃទី ១០ កុម្ភៈ ១៩៦៩

អ្នកជាតិនិយម សូមប្រសិទ្ធិឲ្យទឹកន្លែងដទៃទៀតជាច្រើន ដូចទន្លេតូច និងរំលេចបារ រលាំង-ដូង-កញ្ចំ ជាដើម បានទទួលនូវស្ថាបនកម្ម ដូចជាអូរអំពាន (ព្រៃវែង) នេះកុំបីឃ្លៀងឃ្លាតឡើយ ព្រោះទន្លេតូចរំលេចអស់ទាំងនេះសុទ្ធតែមានប្រយោជន៍ធំដល់កសិកម្ម និងដល់គមនាគមន៍ ព្រមទាំងដល់មច្ឆវប្បកម្មផង ។

o

o o

# សមិទ្ធិថ្មី នៃសង្គម

# នៅ

# ខេត្តកណ្ដាល



មណ្ឌលសុខភាពនៅគគី ស្រុកកៀនស្វាយ ខេត្តកណ្ដាលដែលទើបនឹងស្ថាបនាហើយក្នុងពេលថ្មីៗនេះ គឺជាសមិទ្ធិដ៏សំខាន់មួយទៀតនៃសង្គមរាស្ត្រនិយម សំរាប់រក្សាការពារសុខភាពប្រជាពលរដ្ឋទូទៅឥតរើសមុខ ។

*អគារដ៏ទាន់សម័យនេះគឺជាអគារមណ្ឌលសុខភាពគគីមើលពីចំហៀង*

▼





▲

អគារមណ្ឌលសុខភាពនៅគគី (មើលចំពីខាងមុខ)



បន្ទប់សម្រាលកូននេះ មាន សភាពយ៉ាងស្អាតស្អំ ប្រកប ដោយគ្រឿងប្រើប្រាស់ គ្រប់សព្វ ▶





◀ ឱសថស្ថាននៃមណ្ឌលសុខភាពគគីប្រកបដោយគ្រឿងបរិក្ខារគ្រប់គ្រាន់

# លិខិតថ្លែងអំណរចំពោះព្រះមហាករុណាទិគុណនៃសម្តេចឪ





# លិខិតថ្លែងអំណរគុណចំពោះព្រះមហាករុណាធិគុណរបស់សម្តេចឪ

សូមព្រះរាជទានក្រាបបង្គំទូលថ្វាយ សម្តេចព្រះបិតាជាតិ

សូមទ្រង់ជ្រាប ។

តាមរយៈអគ្គរដ្ឋទូតខ្មែរប្រចាំសហភាពសូវៀត - មូស្គូ ។

បពិត្រសម្តេចព្រះបិតាជាទី[illegible]! ទូលព្រះបង្គំមានការរំភើបយ៉ាងក្រៃលែង ដោយទើបនឹងបានទទួលព្រះរាជសារលិខិតលេខ ១៣០១ SPu ព្រមទាំងព្រះរាជទាន [illegible] ចំនួនពីរពាន់រៀល ដើម្បីរក្សាជីវភាពខ្មែរប្រកបដោយ [illegible] មួយរូប-(ក្រោយៗ សហភាពសូវៀត) ។

ទូលព្រះបង្គំសូមថ្លែងអំណរព្រះគុណដ៏ក្រៃលែងចំពោះព្រះបិតាដោយស្មោះអស់ពីដួងចិត្ត ។

ជាពិសេសក្នុងឱកាសនេះ ទូលព្រះបង្គំសូមថ្វាយពាក្យជូនព្រះពរដល់ ទូលព្រះបង្គំបានជួបលោក យ៉ារ៉ូស្លាវ គាមីល យ៉ារ៉ូស្លាវិច ដែលជាគ្រូក្នុងឱកាសបរទេសស្នាក់នៅក្នុង [illegible] ខ្មែរភាសាយន្ត នៅភ្នំពេញ ។ លោក យ៉ារ៉ូស្លាវ គាមីល យ៉ារ៉ូស្លាវិច មានការរំភើបយ៉ាងក្រៃលែង ចំពោះសម្តេចព្រះបិតាជាតិ ដល់ព្រះរាជា ដល់ព្រះរាជរោងកម្ម ដល់ព្រះនរោត្តម ដល់ព្រះបរមរាជវាំង ចំពោះប្រជារាស្ត្រខ្មែរ ។ ចំពោះប្រវត្តិរូបរបស់គាត់ នៅក្នុងពេលដែលគាត់ដល់ការត្រឡប់របស់គាត់មកដល់ទីក្រុងប្រាក គាត់បានធ្វើការងារស្រាវជ្រាវយ៉ាងសកម្មដើម្បីដល់ប្រទេសកម្ពុជាក្នុងវិស័យសិល្បៈ-សង្គម-វប្បធម៌ [illegible] ព្រមទាំងបុរាណវត្ថុ ក្នុងវិស័យផ្សេងៗ យ៉ាងច្រើន ដល់ការទទួលរបស់ព្រះរាជាចំពោះគាត់ ក្រោយពីសហការីរបស់គាត់ក្នុងឱកាសបង្រៀននៅវិទ្យាស្ថានភាសាយន្តនេះ ។ គាត់បញ្ចប់ហើយ បញ្ចប់ទៀតនូវព្រះរាជហឫទ័យ ចំពោះ [illegible] ព្រះរាជដំណើរនៅ [illegible] - ដើម្បីដល់ព្រះបរម ព្រះរាជករណីយកិច្ចក្នុងវិទ្យាស្ថានភាសាយន្តខ្មែរ ហើយវិទ្យាស្ថានភាសាយន្ត ព្រះរាជកុសល គាត់បានហៅថា ឪពុកទើបក្នុងក៏ព្រះរាជបុត្ររបស់ព្រះរាជា ។

ក្រៅពីនេះ នៅសាលាភាសារុស្ស៊ីនៃទីក្រុងបឺគីស្លាវ-[illegible] របស់សហភាពសូវៀត មាននិស្សិតជាតិខ្មែរ [illegible] ប្រទេសកម្ពុជា-ជាភាសារុស្ស៊ីផ្សេងៗ ហើយ ទូលព្រះបង្គំបានសួរមើលអ្នកទាំងនោះ [illegible] ដែលធ្លាប់ខ្សែ ទូលព្រះបង្គំសិក្សានូវការដោះស្រាយ [illegible] វិទ្យាស្ថានភាសាយន្ត "ព្រះរាជកុសល" ក្នុងឱកាសបង្ហាញនូវ [illegible] ភាសាយន្តនៅប្រទេសកម្ពុជា ហើយនិងការដែលបាន ១៥ ឆ្នាំមកហើយ ក្រោយពីពេលដែល [illegible] ព្រះបិតា-ព្រះរាជា-ព្រះបរមរាជវាំង-ព្រះ [illegible] ព្រះភាសាខ្មែរ ។

ការគោរពសូមព្រះរាជទានព្រះរាជគុណ ។

ក្រាបបង្គំទូលថ្វាយនៅ ប្រាក ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ ១៩៦៩

ភាសាវិទូ - [illegible]

និស្សិតខេមរៈ បណ្ឌិត [illegible]

[illegible]

ប្រាក.

# សមាជិកថ្មី នៃមហាចលនាជាតិ សង្គមរាស្ត្រនិយម

Québec le 17 Novembre 1968

A Sahachivin San Yun
Secrétaire Général du "Sangkum Reastr Niyum"

s/c Son Excellence Huot Sambath
Représentant Permanent du Cambodge
Aux Nations Unies.

Excellence,

Pour l'amour de la Patrie, pour l'amour de la Paix, pour l'amour de l'Indépendance et pour l'amour de l'Unité Nationale, j'ai l'honneur de venir par la présente, solliciter Sahachivin Secrétaire Général du Sangkum de bien vouloir m'accepter au sein de votre Parti.

Mon Nom : Diep Oubonn
Né le 26 Novembre 1942 à Prey Veng (ville)
Etudiant en 3ième Année de l'Ecole des Gradués
de l'Université Laval (Canada).
Titulaire de :
-Baccalauréat es Sciences Agronomiques (Vivres)
-Diplôme de l'Ecole Normale Supérieure

Ce serait un grand honneur et un grand plaisir pour moi d'ajouter mon modeste appui au Sangkum, car je suis persuadé, malgré mon ignorense en matière de politique, qu'en le faisant, je servirais l'Unité Nationale.

En espérant que ma demande recevrait une réponse favorable, je prie Votre Excellence d'accepter mes voeux très sincères pour la réussite du Mouvement.

Diep Oubonn

Diep Oubonn
Faculté d'Agriculture
Département des Vivres
Université Laval
Québec 10, Canada

សូមក្រាបបង្គំទូលថ្វាយ សម្តេចព្រះប្រមុខរដ្ឋ ប្រធានសង្គម
រាស្ត្រនិយម សូមទ្រង់ជ្រាប។

ខ្ញុំព្រះបង្គំជាខ្ញុំ នាម យក ចន់ថា ជាតិខ្មែរ កើត
នៅថ្ងៃទី ៨ កញ្ញា ឆ្នាំ១៩៤៦ នៅក្រុងភ្នំពេញ ជានិស្សិត
រៀនថ្នាក់ វិទ្យាសាស្ត្រ ប្រវិយម នៅសាកលវិទ្យាល័យ មិត្តភាព
ប្រជាជាតិ នៅ មហានគរ មូស្គូ ។ ខ្ញុំព្រះបង្គំ-ការបរិញ្ញា
បត្រ ថ្នាក់វិទ្យាសាស្ត្រ ប្រវិយម ហើយសព្វថ្ងៃនេះ
រៀន បន្តទៀត ដើម្បីយកថ្នាក់បណ្ឌិត។

សូមទ្រង់មេត្តាជ្រាប

ខ្ញុំព្រះបង្គំជាខ្ញុំយល់ឃើញថា ចលនាសង្គមនិយម
ជាចលនា បង្រួបបង្រួមជាតិ។ គឺនៅក្រោមព្រះមគ្គុទ្ទេសក៍
នៃសម្តេចព្រះប្រមុខរដ្ឋនេះ ហើយ ធ្វើឲ្យប្រទេសកម្ពុជា
យើង បានប្រកបដោយសន្តិភាព និងវឌ្ឍនភាពគ្រប់ប្រការ
ហើយមានឈ្មោះល្បីល្បាញ ក្នុងសាកលលោកផង។

ដើម្បី សំដែង នូវសេចក្តី ស្មោះត្រង់ របស់ខ្ញុំព្រះ
បង្គំ ចំពោះជាតិ និងសម្តេចព្រះមហាក្សត្រ ខ្ញុំព្រះបង្គំជាខ្ញុំ
សូមក្រាបជម្រាប សុំចូលជាសមាជិក នៃចលនាសង្គម
រាស្ត្រនិយម ដើម្បីបំរើប្រទេសជាតិយើង តាមសមត្ថភាព
ចាប់តាំងពីពេលនេះតទៅ។

សេចក្តី [illegible] សូមទ្រង់មេត្តាជ្រាប

សូមខ្ញុំថ្វាយនៅក្រុង មូស្គូ ថ្ងៃទី ៦ វិច្ឆិកា ១៩៦៨

ហត្ថលេខា: -យកចន់ថា-





# សមាជិកថ្មី នៃ
# មហាចលនាជាតិ សង្គមរាស្ត្រនិយម

Prague le 19 Décembre 1968

A Samdech Sahachivin, fondateur du
Sangkum Reastr Niyum

Phnom Penh

S/C Son Excellence Monsieur l'Ambassadeur
du Cambodge en Tchécoslovaquie

Prague

Samdech,

Je, soussigné Som Phannath né le 1 Janvier 1940 à Srang /Kompong Speu/ titulaire du diplome de Master of Science in Civil Engineering and Architecture des Hautes Ecoles Tchèques d'Enseignement Technique Supérieur à Prague.

Ai l'honneur de venir très respectueusement solliciter de la Haute Bienveillance de Samdech la faveur de bien vouloir m'accepter comme membre du Sangkum Reastr Niyum.

Daignez agréer, Samdech, l'expression de mes respects et de ma profonde gratitude.

Som Phannath
Spartakiádní 5 Blok VIII/508
Prague 6



Prague le 20 Décembre 1968

A Samdech Sahachivin, Fondateur du
Sangkum Reastr Niyum

Phnom Penh

S/C Son Excellence Monsieur l'Ambassadeur
du Cambodge en Tchécoslovaquie

Prague

Samdech,

Je, soussigné Pith Tha, né le 27 Octobre 1942 à Phnom Penh, titulaire du diplome de Master of Science /Chemistry/ de la Haute Ecole Chimique et de Technologie à Prague.

Ai l'honneur de venir très respectueusement solliciter de la Haute Bienveillance de Samdech la faveur de bien vouloir m'accepter comme membre du Sangkum Reastr Niyum.

Daignez agréer, Samdech, l'expression de mes respects et de ma profonde gratitude.

Pith Tha
Zikova 13
Prague 6
Tchécoslovaquie



# សមាជិកថ្មី នៃមហាចលនាជាតិសង្គមរាស្ត្រនិយម

S/C

de l'Ambassade Royale

du Cambodge à Prague

Bratislava le 15 Decembre 1968

A Samdech Sahachivin

Chef de l'Etat

President du Sangkum Reastr Niyum

Samdech Sahachivin

Je soussigné Sun Chhoan, de Nationalité Cambodgienne, né le 8 Juin 1942 à Battambang, etudiant de la Faculté Technologique de Chimie à Bratislava, Tchecoslovaquie.

Ai l'honneur de venir très respectueusement solliciter de la très Haute Bienveillance de Samdech Euv la faveur de bien vouloir me faire admettre comme membre du Sangkum Reastr Niyum, la Grande Communauté socialiste bouddhique, symbol de notre union nationale, qui sous la Haute Clairvoyance de Samdech Sahachivin et avec le soutien total du peuple khmer a profondement transformé notre pays dans tous les domaines, a apporté à notre peuple une paix privilegiée dans une region troublée, et dont les principes de neutralité et d'independance totale ont montré au monde entier le visage d'un peuple fier, libre et maitre de soi-même.

Veuillez agréer, Samdech Euv, l'expression de mes sentiments les plus respectueux et dévoués.



Sun Chhoan

## ព្រឹត្តិប័ត្រឧតុនិយមជូនចំពោះប្រជាកសិករ

ព្យាករណ៍អាកាសកំណត់ ៣០ ថ្ងៃ ចាប់តាំងពីថ្ងៃទី ១០ មីនា ដល់ថ្ងៃទី ១០ ខែមេសា ឆ្នាំ ១៩៦៩ ។

ក្នុងថិរវេលាប្រមាណទុកនេះ គេសង្កេតឃើញបរិយាកាសស្រឡះល្អជាទីគាប់ ។ ចាប់តាំងពីថ្ងៃទី ២០ ខែមីនា ១៩៦៩ នេះទៅ ស្ថានភាពឧតុនិយមនឹងប្រែប្រួលដោយសារការវិវត្តន៍នៃមណ្ឌលវិសម្ពាធឧណ្ហភាព នៅលើភាគខាងជើងនៃប្រទេសកម្ពុជា ។ មណ្ឌលសកម្មនេះ នឹងស្រូបយកខ្យល់ក្តៅដែលបក់លើសមុទ្រឲ្យចូលកាត់ប្រទេសកម្ពុជាយើង ហើយក៏នឹងបណ្តាលឲ្យមានពពកគគីរជលធរ ហើយនិងភ្លៀងផ្គររន្ទះនៅពេលព្រលប់ "តាមពាក្យចាស់ទុំហៅថាភ្លៀងព្រះឥន្ទលាងស្លឹក" ។

ចំនួនថ្ងៃដែលមានភ្លៀងផ្គរប្រមាណទុក : ពីរឬបីថ្ងៃ

សីតុណ្ហភាពអប្បបរមាប្រមាណទុក : ២០ អង្សា

សីតុណ្ហភាពអតិបរមាប្រមាណទុក : ៣៤ អង្សា

ធាតុទឹកក្នុងអាកាសអប្បបរមានឹងមានកំរិត : ៤៣ ភាគរយ

ពេលវេលាដែលព្រះធរណីទទួលកាំរស្មីព្រះអាទិត្យ ពី ៧ ទៅ ៨ ម៉ោងក្នុងមួយថ្ងៃ ។

ទឹកហួតក្នុងមួយថ្ងៃ នឹងមានកំរិត : ៨ មីលីម៉ែត្រ ។

ខ្យល់បក់មកពីទិសអាគ្នេយ៍ ឬទិសបូព៌ាមានល្បឿនមធ្យម ១៥ គ.ម ក្នុងមួយម៉ោង ។

ក្នុងវិស័យកសិកម្ម វត្តមាននៃភ្លៀងកក់ខែក្នុងរដូវក្តៅ នឹងបណ្តាលឲ្យមានកើតសត្វល្អិតចង្រៃនិងជម្ងឺសត្វទៀតផង ។ អាស្រ័យដោយហេតុនេះសូមបងប្អូនកសិករទាំងឡាយរិះរកមធ្យោបាយជាបន្ទាន់ ប្រឆាំងនឹងបាតុភូតទាំងនេះក្រោយពេលមានភ្លៀងធ្លាក់ ។

ចំពោះអ្នកចូលចិត្តថតរូបតាមអាកាសយានវិញ ជាឱកាសមួយយ៉ាងប្រពៃបំផុតក្នុងចន្លោះម៉ោង ៨ និងម៉ោង ១០ ដែលផ្ទៃមេឃស្រឡះល្អ គឺក្រោយពេលរលាយផ្សាំងភូមិកា "អ័ព្ទស្តើង ៗ ហើយមុនពេលកើតពពកឥពាក ។

ពោធិចិនតុង ថ្ងៃទី ១០ មីនា ឆ្នាំ ១៩៦៩

នាយការិយាល័យព្យាករណ៍អាកាស,

**ហេង-ទូច**




### ការចេញឆ្នោតជាតិ

ឆ្នោតជាតិលើកធម្មតាចេញដោយទៀងទាត់

នៅថ្ងៃទី ១១-១៧-២៣ និង ២៩ «ឬថ្ងៃទី ២៨ សម្រាប់ខែកុម្ភៈ ដែលមាន ២៨ ថ្ងៃ» រៀងរាល់ខែ ។

លើកក្រោយឆ្នោតជាតិលើកទី ១១ នឹងចេញនៅថ្ងៃទី ២៣ មីនា ឆ្នាំ ១៩៦៩

វេលាម៉ោង ៨ ព្រឹក នៅក្លឹបវត្តភ្នំ ក្រុងភ្នំពេញ ។

តម្លៃឆ្នោតមួយសន្លឹក : ១០ រៀល

ក្នុងជំពូកនីមួយៗ មានរង្វាន់ : ៩០០.០០០៛០០ មួយសន្លឹក

រង្វាន់ដទៃទៀត : ១០០.០០០៛០០ — ៥០.០០០៛០០ — ១០.០០០៛០០

៥.០០០៛០០ — ១.០០០៛០០ — ៥០០៛០០

និង ១០០៛០០



# ការសហ្វត់

## សម័យប្រជុំលើកទី ៧៥ នៃក្រុមប្រឹក្សាជាន់ខ្ពស់ខាងផែនការនិងវឌ្ឍនភាពជាតិ

កាលពីថ្ងៃទី ៧ ធ្នូ ១៩៦៨ វេលាម៉ោង ៩ មានការបើកសម័យប្រជុំលើកទី ៧៥ នៃក្រុមប្រឹក្សាជាន់ខ្ពស់ខាងផែនការ និងវឌ្ឍនភាពជាតិនៅទីស្តីការរដ្ឋមន្ត្រីក្រសួងផែនការ ក្រោមអធិបតីភាពសហជីវិន ស្រី-ប៊ុន រដ្ឋលេខាធិការក្រសួងផែនការ ជាតំណាងសហជីវិននាយករដ្ឋមន្ត្រីស្តីទី ។

ឥស្សរជនដែលបានអញ្ជើញមកប្រជុំ គឺមាន ៖

– សហជីវិនផ្លុក-គីន តំណាងរដ្ឋសភាជាតិ សមាជិក

– អ្នកអង្គម្ចាស់នរោត្តម-ម៉ុងតាណា តំណាងក្រុមប្រឹក្សាព្រះរាជាណាចក្រ –ដ–

– សហជីវិនយ៉ែម-សារ៉ុង រដ្ឋមន្ត្រីក្រសួងហិរញ្ញវត្ថុ –ដ–

– – គាត-ឈន រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម –ដ–

– – ហ៊ុក-ប៉េងហ៊ាង តំណាងក្រសួងស.ក. និង ទ.គ.ប. –ដ–

– – អ៊ុង ស៊ីហៃគិមគេង តំណាងក្រសួងកសិកម្ម –ដ–

– – ឡុង ស៊ីថៃ តំណាងទេសាភិបាលធនាគារជាតិនៃប្រទេសកម្ពុជា –ដ–

– – ហូ តាយ សេង តាង ហ្វាង់ជាតិមន្ទីរបូរប្រាក់ –ដ–

– – ញ៉ឹក ជុន តំណាងក្រុមចំរុះពាណិជ្ជកម្ម និងកសិកម្ម –ដ–

– – សេង ប៊ុនគន អគ្គនាយកនៃផែនការ សមាជិកអ្នកកាយ-ការណ៍ ។

ឥស្សរជនដែលបានអញ្ជើញមកចូលរួម គឺមាន៖

សហជីវិន ងិន និព្វផា, ហេង ឡុង, កាវ ណាត, សៅ លាង ផន ធុល, នូវ គិមឆាំង, ដោម សារឿន, អ៊ុម ព្រឿង, និង ឈឿន យ៉ែម សាក់ន, និងប៊ុន ឈឿម ។

នៅពេលបើកសម័យប្រជុំ សហជីវិនប្រធានបានអញ្ជើញអង្គប្រជុំពិនិត្យរបៀបវារៈ ។

សហជីវិនប្រធានបានរំលឹកថា សេចក្តីរាយការណ៍ជូនមកក្រុមប្រឹក្សាជាន់ខ្ពស់នៃផែនការដែលមានមាត្រាធំៗ ស្តីពីការអនុវត្តន៍ផែនការប្រាំឆ្នាំ ទី ១ បានរៀបចំឡើងដោយប្រញាប់ប្រញាល់ពេក ដើម្បីតម្រូវតាមពាក្យសុំនៃរដ្ឋសភាជាតិ ។ កាលពីក្នុងសម័យមហាសន្និបាតរបស់ខ្លួនថ្ងៃទី ២៥ វិច្ឆិកា ១៩៦៨ រដ្ឋសភាជាតិបានពន្យារពេលពិនិត្យផែនការប្រាំឆ្នាំ ទី ២ ដោយរង់ចាំសេចក្តីរាយការណ៍ ដែលត្រូវមានការយល់[illegible]មពីក្រុមប្រឹក្សាជាន់ខ្ពស់នៃផែនការនិងយល់ព្រមពីគណៈរដ្ឋមន្ត្រី ។ សហជីវិនប្រធានសុំឲ្យសមាជិកទាំងអស់ ផ្តល់យោបល់ពីសេចក្តីសង្កេតឃើញរបស់ខ្លួន ដើម្បីអាចឲ្យក្រសួងផែនការធ្វើសេចក្តីព្រាងនេះឲ្យបានស្អាតដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យជាសម្រេច ។

ក្រោយពីបានប្តូរយោបល់គ្នាយ៉ាងយូរមក, ក្រុមប្រឹក្សាជាន់ខ្ពស់នៃផែនការបានសំរេចជាឯកច្ឆន្ទទុកជាបានការ នូវសេចក្តីរាយការណ៍ស្តីពីការអនុវត្តន៍ផែនការប្រាំឆ្នាំ ទី ១ ឆ្នាំ ១៩៦០-១៩៦៤ ហើយនឹងដាក់ជូនសេចក្តីរាយការណ៍នេះឲ្យគណៈរដ្ឋមន្ត្រីពិនិត្យ ។

## គម្រោងការរៀបចំរោងឧស្សាហកម្មយានកម្មត្រី នៅក្រុងព្រះសីហនុ ដោយក្រុមហ៊ុន casacrus

សហជីវិន សេង-ប៊ុនគន បញ្ជាក់ថា: ការនេសាទនិងការនាំចេញបង្គាតោទជាបញ្ហាយ៉ាងច្រើន ដែលបានដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យ ដើម្បីសុំសេចក្តីសំរេចគឺ :

– បញ្ហាហិរញ្ញវត្ថុទាក់ទងនឹងការទូទាត់ទំនិញដែលត្រូវដាក់ទៅលើបង្គានាំចេញ ។

– បញ្ហាសារពើពន្ធទាក់ទងនឹងពាក្យសុំខាងអត្ថប្រយោជន៍ ។

– បញ្ហានីតិកម្មដែលត្រូវកែប្រែ ។

– បញ្ហាបច្ចេកទេសទាក់ទងនឹងការកំណត់ចំនួនអ្នកនេសាទ ។

– បញ្ហាសង្គមកិច្ចជាប់នឹងការសំរុះសំរួលដែលត្រូវធ្វើជាមួយនឹងអ្នកនេសាទបច្ចុប្បន្ន ដើម្បីឲ្យការនេសាទមានដំណើរប្រព្រឹត្តទៅបានស្រួល ។

– បញ្ហាទាំង ៣ ខ ខាងក្រោយនេះ ហាក់ដូចជាបានដោះស្រាយរួចហើយ ពីព្រោះក្រុមហ៊ុន *Casacrus* អាចទទួលយល់ព្រមជាមួយក្រសួងកសិកម្មហើយ ។ នៅតែបញ្ហា ២ ខ ដំបូង ដែលត្រូវតែមានយោបល់ពីក្រសួងនិងក្រុមមានសមត្ថកិច្ចដែលទទួលភារៈក្នុងរឿងនេះ។

ក្រោយពីបានប្តូរយោបល់យ៉ាងយូរមក ក្រុមប្រឹក្សាជាន់ខ្ពស់នៃផែនការបានសំរេចជាឯកច្ឆន្ទយកសេចក្តីព្រាងនេះ ដោយស្នើសុំឲ្យក្រុមហ៊ុននេះផ្តល់នូវឯកសិទ្ធិនិងអត្ថប្រយោជន៍ដូចតទៅ ៖

– ការទូទាត់ទំនិញ ( *péréquation* ) ៣៦% សំរាប់ការនាំចេញនៅតំបន់ "រូបិយវត្ថុដទៃទៀត" ។

ប៉ុន្តែ ការទូទាត់ទំនិញនេះ អាចត្រឡប់មកតិចវិញ នៅតំបន់រួពន្ធ (គេនឹងតាត់វិធានការដូចគ្នា) ។ អត្រានៃការទូទាត់ទំនិញនឹងពិនិត្យឡើងវិញក្នុងរយៈ ៣ ខែម្តង ក្នុងករណីទាំងពីរនេះ ហើយនិងភាគនៃមាឌបង្គានេសាទបាន ។

– ធានាកំប៉ុងទល់នឹងគ្រោះថ្នាក់នៃជាតូបនិយកម្មចំនួន ២៥ ឆ្នាំ ។

— ការផ្ទេរប្រាក់ចំណេញចំនួន ១៥ % លើប្រាក់ទុនបរទេសដែលធ្វើវិនិយោគ ។

— ការឲ្យរួចពន្ធប្រថាប់ត្រា និងតែមប្រ៍ចំពោះលិខិតបង្កើតក្រុមហ៊ុន និងការបន្ថែមជាយថាហេតុ នូវប្រាក់ទុន ។

— ការឲ្យរួចពន្ធទាំងអស់ចំពោះទ្រព្យសម្បត្តិខាងបរិក្ខារ, គ្រឿងផ្លាស់ប្តូរនិងសម្ភារៈនេសាទ ក្នុងរយៈកាល ២ ឆ្នាំកន្លះ គិតពីថ្ងៃបង្កើតក្រុមហ៊ុន ។

ក្រុមប្រឹក្សាជាន់ខ្ពស់នៃផែនការផ្តាំផ្ញើឲ្យក្រុមហ៊ុននេះ ទាក់ទងជាមួយក្រសួងកសិកម្ម ដើម្បីដោះស្រាយបញ្ហា ៣ ខាងក្រោយ ដែលសហជីវិនសេង ប៊ុនគន បានរៀបរាប់ខាងលើ ។

## បញ្ហាផ្សេងៗ

### ឥណទានខាងបរិក្ខាចំនួន ៦.០០០.០០០ រ សំរាប់ទីពិសោធន៍ជាតិនៃជលគតិវិជ្ជា ស្នើដោយក្រសួងកសិកម្ម

ក្រោយពីបានស្តាប់សេចក្តីថ្លែងនៃអ្នកតំណាងក្រសួងកសិកម្មនិងសាធារណការមក ក្រុមប្រឹក្សាជាន់ខ្ពស់នៃផែនការ បានផ្តាំផ្ញើដល់ក្រសួងទាំងពីរឲ្យយល់ព្រមការចែកឥណទាននេះ ដោយយោលទៅតាមការត្រូវការជាបន្ទាន់ ហើយឲ្យដំណឹងជាខាងក្រោយទៅក្រុមប្រឹក្សាជាន់ខ្ពស់នេះ ។ ក្រោយពីបានរាយការណ៍ជំរាបមេក្រសួងរបស់ខ្លួនហើយ អ្នកតំណាងក្រសួងសាធារណការ បានឲ្យដំណឹងទៅក្រសួងផែនការថា ក្រសួងសាធារណការមិនអាចទទួលខុសត្រូវជាមួយក្រសួងកសិកម្ម ក្នុងការចែកឥណទាន ៦.០០០.០០០រ បានទេ ដោយយល់ឃើញថា ផែនការប្រតិបត្តិត្រូវបានមូលនិធិពិសេសនៃអគ្គការសហប្រជាជាតិចុះហត្ថលេខារួចហើយ ហើយដោយមកពីមានឥណទាននេះតំកល់ទុកផង ។

សម័យប្រជុំបានចប់សព្វគ្រប់នៅវេលាម៉ោង ១៣ និង៣០នាទី ។

° ° °

## រឿងកែបំបាត់ប្រាក់សាធារណៈនៅសាលាស្រុកកំពង់ស្វាយ «កំពង់ធំ»

កំណត់ក្រុមអ្នកនិពន្ធ— បន្ទាប់ពីបានឃើញមានការកេងបំបាត់ប្រាក់នៅកំពង់ធំមក សហជីវិន អ៊ុង ហ៊ុងសាធ បានក្រាបបង្គំទូលសម្តេចឪ ព្រះប្រមុខរដ្ឋ នូវវិធានការដែលសហជីវិនបានចាត់ គឺសូមឲ្យបន្ថែមកម្លាំងទៅលើកិច្ចត្រួតពិនិត្យបលទ្ធនៃប្រាក់ទាំងឡាយ ដោយអាជ្ញាធរខេត្ត ព្រមទាំងបានធ្វើសេចក្តីសូមឲ្យបញ្ឈប់ភ្នាក់ងាររាជការមានកំហុសទាំងពីររូបនេះលែងឲ្យធ្វើការផង ។

ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលសម្តេចសហជីវិនសូមទ្រង់ជ្រាបថា ការបាត់ប្រាក់ចំនួន ៣៩៦.០០០ រៀល ដែលជាប្រាក់បៀវត្សនៃចៅសង្កាត់ទាំងឡាយនិងជាប្រាក់ពន្ធ ព្រមទាំងជាប្រាក់សោហ៊ុយផ្តល់ពូជគញ្ជាតិនិងដីទាំងឡាយ បានត្រូវកើតមាននៅសាលាស្រុកកំពង់ស្វាយ "កំពង់ធំ" ។

មានភ្នាក់ងាររាជការពីររូប បានត្រូវជាប់ចោទក្នុងរឿងនេះ គឺលោក គាត-សារុន ក្រមការដើមថ្នាក់លេខ ២ ជាអតីតចៅហ្វាយស្រុកកំពង់ស្វាយ និងលោក ប៉ែន-សេង ជាលេខាធិការនៃការិយាល័យនិងខេត្តថ្នាក់លេខ ២ ធ្វើជាបាឡាត់ស្រុកនៃស្រុកកំពង់ស្វាយ ។

លុះអធិការខាងកិច្ចការនយោបាយ និងរដ្ឋបាលបានធ្វើអង្កេតទៅភ្នាក់ងាររាជការជាប់ពិរុទ្ធទាំងពីររូបនោះ បានទទួលសារភាពចំពោះកំហុសរបស់ខ្លួន ហើយទឹកប្រាក់ដទៃព្រមទាំងប្រាក់បៀវត្សនៃចៅសង្កាត់ទាំងឡាយ ក៏បានត្រូវសាមីខ្លួនយកមកដាក់សងវិញ ព្រមទាំងបានបើកឲ្យទៅចៅសង្កាត់នោះគ្រប់ចំនួនទាំងអស់ហើយ ។

លោក គាត-សារុន មិនបានបើកប្រាក់បៀវត្សឲ្យចៅសង្កាត់ទាំងនោះ ព្រោះសំគាល់ថាខ្លួនឈឺ ហើយបានទៅដេកនៅមន្ទីរពេទ្យពីថ្ងៃទី ៨ មីនា មកទល់នឹងថ្ងៃ ៣០ សីហា ១៩៦៨ ។ ដោយហេតុមានការលំបាកខាងហិរញ្ញវត្ថុ បណ្តាលមកពីជម្ងឺរបស់ខ្លួននោះ លោកគាត-សារុន ក៏បានយកប្រាក់នោះមកប្រើបណ្តោះអាសន្នសិន ។ ម្យ៉ាងទៀតភ្នាក់ងាររាជការចាស់នេះនឹងត្រូវចូលនិវត្តនៅថ្ងៃទី ៩ មករា ១៩៧០ ក្រោយនេះផង ។

នៅចំពោះមុខស្ថានការណ៍បែបនេះ ក្រសួងក៏បានចាត់វិធានការដូចតទៅ :

១— បានធ្វើសារាចរបញ្ជូនទៅគ្រប់អភិបាលខេត្តនិងក្រុងទាំងឡាយឲ្យជួយត្រួតពិនិត្យឲ្យបានដិតដល់នូវភ្នាក់ងារទាំងឡាយដែលទទួលភារៈខាងទទួលទុកប្រាក់ចំណូលផ្សេងៗ ។

២— បានស្នើឲ្យគណៈរដ្ឋមន្ត្រីបញ្ឈប់លោកគាត-សារុន និងលោកប៉ែន-សេង លែងឲ្យធ្វើការ ហើយសេចក្តីស្នើបែបនេះគឺធ្វើឡើងអនុលោមតាមព្រះរាជបញ្ញាដ៏ខ្ពង់ខ្ពស់ក្រៃលែងនៃសម្តេចឪជាអម្ចាស់ ។

° ° °

### លេខបូកកំសាន្តចិត្ត

សូមអ្នកនាងធ្វើលេខបូកខាងក្រោមនេះ ដោយយកលេខពី ១ ទៅ ៩ ដាក់ជំនួសចំណុចខ្មៅ ហើយឲ្យឃើញចំនួនសរុបទាំងអស់ត្រឹម ១៤ ។ លេខនីមួយៗ នឹងអាចដាក់បានតែម្តងជំនួសចំណុចខ្មៅ ។

● + ● + ●/● + ●/● + ●/●● = ១៤

# ការសម្ងាត់

## ចំពោះរឿងចាប់ខ្លួនឈ្មោះលែរប៉េ-អូស្សប្រួន

ដូចយើងបានផ្សាយរួចមកហើយថា កាលពីថ្ងៃទី ១២ ខែកុម្ភៈ កន្លងទៅនេះ កងការពារព្រំដែនយើងនៅស្វាយរៀង បានបាញ់ធ្លាក់យន្តហោះនៃកងកម្លាំងអាមេរិកាំងយៀកណាមខាងត្បូងមួយគ្រឿង ក្នុងពេលដែលយន្តហោះនេះ ហោះរំលោភចូលមកដែនអាកាសយើង ។

នៅពេលនោះ អ្នកបើកបរយន្តហោះឈ្មោះលែរប៉េ-អូស្សប្រួន ជាព្រិន្ទបាលឯកបានត្រូវកងកម្លាំងយើងចាប់ខ្លួនបានធ្វើជាឈ្លើយ ។ កាលពីដំបូងឈ្មោះ លែរប៉េ-អូស្សប្រួននេះ បានប្រកាន់អាកប្បកិរិយាយ៉ាងលាក់លៀមប្រកែកពុំព្រមប្រាប់យើង អំពីចំនួនសមាជិកនៃអាកាសយានិកនោះ និងអំពីបេសកកម្មរបស់ពួកវា ។ លុះគ្រាតែកងការពារព្រំដែនយើងបង្ហាញនូវផលអាក្រក់ផ្សេង ៗ ទើបឈ្លើយអាមេរិកាំងរូបនេះ បានរាយការណ៍ប្រាប់យើងគ្រប់សព្វ ។

o

o o



◀ ព្រិន្ទបាលឯក លែរ-ប៉េ-អូស្សប្រួន ជាអ្នកបើកបរយន្តហោះធុន UIA «OTTER»

o

o o

កំទេចយន្តហោះ ដែលកងការពារព្រំដែនយើង បាញ់ធ្លាក់នៅស្វាយរៀង (ទាហានយើងម្នាក់យាមនៅទីនោះ) ▼



## ប្រកាសជូនដំណឹងអំពីការបើកឱ្យ ចូលប្រជែងតម្លៃ នៃតាស៊ីខេត្តនិងឃុំសម្រាប់ឆ្នាំ១៩៦៩

ឧកញ៉ាកជាមេត្រី ប្រតិភូរាជរដ្ឋាភិបាលប្រចាំខេត្តកណ្ដាល សូមជូនដំណឹងដល់សាធារណជនឲ្យបានជ្រាបថា នៅថ្ងៃទី ១៧ ខែមីនា គ.ស ១៩៦៩ វេលាម៉ោង ៩ ព្រឹក នៅការិយាល័យសាលាខេត្តកណ្ដាលនឹងមានបើកឱកាសឲ្យសាធារណជនទាំងឡាយចូលប្រជែងតម្លៃតាស៊ីខេត្ត និងឃុំដូចមានរាយខាងក្រោមនេះ សម្រាប់ឆ្នាំ ១៩៦៩ ។

| លេខរៀង | តំបន់តែងដាក់ឲ្យជេញថ្លៃ | តម្លៃដាក់សម្រាប់១ឆ្នាំ | ប្រាក់ធានាបណ្ដោះអាសន្ន |
|---|---|---|---|
| ១ | ផ្សារតាក់អង្រែ | ៤៥៦.០០០៛០០ | ៤៥.៦០០៛០០ |
| ២ | — កំពង់ហ្លួង | ១៨៣.០០០៛០០ | ១៨.៣០០៛០០ |
| ៣ | — ព្រែកដាច់ | ១០០.០០០៛០០ | ១០.០០០៛០០ |
| ៤ | សត្តឃាតកម្មស្រុកខ្សាច់កណ្ដាល | ៩០.០០០៛០០ | ៩.០០០៛០០ |
| ៥ | ទីសត្តឃាតផ្សារអំពៅ | ២៣១.០០០៛០០ | ២៣.១០០៛០០ |
| ៦ | កន្លែងផ្ញើរទោចក្រយាននៅផ្សារតាខ្មៅ | ១០.០០០៛០០ | ១.០០០៛០០ |

ពាក្យសុំចូលប្រជែងតម្លៃត្រូវជូនទៅសាលាខេត្តកណ្ដាលនៅតាខ្មៅ "ក្រុមហិរញ្ញវត្ថុ" ឲ្យបានមុនថ្ងៃទី ១៥ ខែមីនា គ.ស ១៩៦៩ ជាកំហិត ។

ពាក្យសុំជេញថ្លៃទាំងឡាយត្រូវឲ្យមានភ្ជាប់នូវ : វិញ្ញាបនប័ត្រកជការ ដែលក្រុមទ្រព្យរាជការចេញឲ្យធ្យាប់ដើម ឬ លិខិតធានាអះអាងដែលធនាគារចេញឲ្យធ្យាប់ដើម ឬ វិញ្ញាបនប័ត្របញ្ជាក់ធនធានរបស់សាមីខ្លួននិងអ្នកធានា "ធ្យាប់ដើម" ដែលមានកំណត់ពេលតិចជាង ៣ ខែ ព្រមទាំងបង្កាន់ដៃដាក់ប្រាក់ធានាបណ្ដោះអាសន្ន ។

ពាក្យសុំចូលប្រជែងតម្លៃណាដែលពុំបានភ្ជាប់នូវលិខិតផ្សេងៗគ្រប់មុខដូចបានរាយមកខាងលើនេះទេ ឬ ជូនទៅសាលាខេត្តកណ្ដាលក្រោយថ្ងៃទី ១៥ ខែមីនា គ.ស ១៩៦៩ ត្រូវគណៈកម្មការទុកចោលជាអសារឥតការ ហើយមិនអនុញ្ញាតឲ្យចូលប្រជែងតម្លៃឡើយ ។

ពេលចូលប្រជែងតម្លៃសាមីជនអ្នកឈរឈ្មោះ ជេញថ្លៃនិងអ្នកធានាត្រូវចូលមកបង្ហាញខ្លួនផ្ទាល់ព្រមទាំងត្រូវឲ្យចុះហត្ថលេខាលើសេចក្ដីកត់ហេតុជាបន្ទាន់ផង ។

ការចូលជេញថ្លៃជួសនឹងមិនអនុញ្ញាតឲ្យធ្វើឡើយ ។ សាធារណជនអាចនឹងសុំមើលសៀវភៅបន្ទុកស្ដីពីការចូលប្រជែងតម្លៃតំបន់តែងផ្សេងៗ ខាងលើនេះបានរៀងរាល់ថ្ងៃធ្វើការ នៅសាលាខេត្តកណ្ដាល "ក្រុមហិរញ្ញវត្ថុ" និងនៅក្រសួងហិរញ្ញវត្ថុ "ក្រុមចំណូល ។

តាខ្មៅ នៅថ្ងៃទី ៣ ខែមីនា គ.ស-១៩៦៩

**ធីម-ជុំ**

# ដំណឹងអ្នកចងក្រង

នៅឱកាសព្រះរាជពិធីចំរើនព្រះជន្មវស្សា នៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ថ្ងៃទី ៩ មេសា ១៩៦៩ និងក្នុងឱកាសចូលឆ្នាំរកា ថ្ងៃទី ១៣-១៤-១៥ មេសា ១៩៦៩ នេះ "អ្នកជាតិនិយម" នឹងចេញលេខពិសេស នៅថ្ងៃទី ៦ មេសាខាងមុខនេះ ដើម្បីជាទីតបស្នងសងព្រះមហាករុណាធិគុណ នៃសម្តេចព្រះមាតាជាតិផង និងជាគ្រឿងតង្វាយជូនចំពោះទេវតាឆ្នាំថ្មីផង ។

លេខពិសេស "អ្នកជាតិនិយម" នឹងជប់លៀងចក្ខុន្ទ្រិយ៍មិត្តអ្នកអាននូវអារម្មណាហារដ៏ឆ្ងាញ់ៗ គឺ :

- អំពីព្រះជីវប្រវត្តិនៃសម្តេចព្រះមហាក្សត្រិយានីជាអម្ចាស់ជីវិតលើត្បូង ។
- ការស្រាវជ្រាវនិងទំនៀមទម្លាប់,អំពីពិធីព្រះពុទ្ធសាសនា,អំពីពិធីចូលឆ្នាំថ្មី, អំពីប្រក្រតិទិន, អំពីចំរើនព្រះជន្មវស្សា, អំពីជំនឿខាងអ្នកតា ។
- អំពីផ្ទេរតំណែងរក្សាទេវតាចាស់និងទេវតាថ្មី ។
- អំពីវិស័យខាងវិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រ ។
- រូបភាពផ្សេងៗ ខាងវិស័យកសាងជាតិ ។
- រូបតុក្កតាដែលមានអ្នកដើរតួប្លែកៗពីគ្នា ។

ក្រៅអំពីនេះ នៅមានអត្ថបទដ៏ឆ្ងាញ់ក្នែកច្រើនទៀត ដែលញ៉ាំងលោក-អ្នកនាងឲ្យកើតបញ្ញាផង ឲ្យនឹកចង់សើចផង ។

បើលោក-អ្នក-នាងមានភ័ព្វសំណាង បានអានលេខពិសេស "អ្នកជាតិនិយម" នោះ លោកអ្នកនាងនឹងបានជ្រាបអំពីព្រះជីវប្រវត្តិនៃសម្តេចព្រះមាតាជាតិ, បានជ្រាបអំពីការស្រាវជ្រាវនិងទំនៀមទម្លាប់ តើពិធីនីមួយៗ កើតឡើងពីត្រឹមណា ? ហេតុអ្វីបានជាត្រូវធ្វើ? ហើយធ្វើរបៀបយ៉ាងណាខ្លះ? ។

មិនតែប៉ុណ្ណោះ លោកអ្នកនាងនឹងបានសប្បាយរីករាយជាមួយនឹងពិធីផ្ទេរតំណែងរក្សាទេវតាចាស់និងទេវតាថ្មី ដែលនៅក្នុងឱកាសនោះ លោកអ្នកនាងនឹងបានឃើញទេវមាន់ សួរដេញដោលទេវស្វា អំពីព្រឹត្តិការណ៍ដែលកន្លងទៅក្នុងឆ្នាំចាស់ ។ ពេលនោះយើងនឹងបានស្តាប់ទេវពានរ ដែលធ្លាប់តែក្រមាច់ក្រមើម តើព្រះអង្គនឹងឆ្លើយយ៉ាងណាខ្លះ? ។

ក្រៅអំពីនេះ លោក-អ្នក-នាងនឹងបានឃើញទៀត នូវរូបតុក្កតា ដែលមានអ្នកប្រដាល់ដ៏ល្បីឈ្មោះចេញមកប្រកួតថ្វាយទេវតា តើគូប្រដាល់នោះគឺលោកណាខ្លះ? ។

នៅមានរឿងគួរឲ្យចប់សំណើចពុំបានជាច្រើនទៀត ប៉ុន្តែយើងសូមលាក់ទុកសិន ពុំទាន់ជម្រាបក្នុងពេលនេះឲ្យអស់ទេ ចាំដល់ពេលអាន"អ្នកជាតិនិយម" លេខពិសេស សឹមយើងសើចព្រមគ្នាតែម្តង ។

សួស្តី ! មិត្តអ្នកអាន

សួស្តី ! លេខពិសេស

## ប្រកាសជូនដំណឹង

គណៈកម្មការឆ្នោតវត្ថុខេត្តព្រៃវែង សូមជូនដំណឹងដល់សាធារណជនថា: នៅថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៦៩ វេលាម៉ោង ៩ ព្រឹក នៅមន្ទីរឃោសនាការខេត្តព្រៃវែង នឹងមានដាក់ដេញថ្លៃដោយមាត់ទទេជាលើកទី ២ នូវវត្ថុដែលសល់អំពីការចេញឆ្នោត ដូចកាយនាមខាងក្រោមនេះ ៖

- រថយន្តស៊ីមការ ១.០០០, ស្ទេអិលអែសកាត់ថ្លៃ . . - . . . ២០០.០០០រ០០
- [illegible]ចក្រយានស្រីសញ្ញាប៉ាតែរ កាត់ថ្លៃ . . . . . ២.៩០០រ០០

ជនណាដេញថ្លៃបាន ត្រូវបង់ប្រាក់ធានាចំនួន ១០ ភាគរយនៃតម្លៃវត្ថុ ហើយត្រូវមកយករបស់ក្នុងរយៈ ៧ ថ្ងៃដោយបង់តម្លៃគ្រប់ចំនួន បើផុតពីពេលកំណត់នេះ ប្រាក់ធានានឹងរឹបអូសជាប្រយោជន៍ដល់ហិបប្រាក់នៃគណៈកម្មការឆ្នោតវត្ថុ ។

ព្រៃវែងថ្ងៃទី ៨ ខែមីនា ឆ្នាំ ១៩៦៩

ជ.ប្រធានគណៈកម្មការ និង គ-ប

អនុប្រធាន,

សោម-ផាន្នី

# ពិធីសម្ពោធព្រះត្រៃបិដក ជាផ្លូវការ

ដោយទទួលព្រះបរមរាជានុញ្ញាតតំកល់លើត្បូង រាជរដ្ឋាភិបាល នឹងចាត់ចែងធ្វើពិធីសម្ពោធព្រះត្រៃបិដកជាផ្លូវការ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់ នៃសម្តេចព្រះមហាក្សត្រិយានី ជាអម្ចាស់ជីវិតលើត្បូង និងសម្តេចព្រះប្រមុខរដ្ឋ ចំនួន ២ ថ្ងៃ ដែលត្រូវធ្វើពិធីដង្ហែក្បួននៅម៉ោង ៧ ព្រឹក សម្ពោធម៉ោង ១៧,០០ នៃថ្ងៃអង្គារទី ១ មេសា ត្រូវនឹងថ្ងៃ ១៤ កើតខែចេត្រ ឆ្នាំ ១៩៦៩ ដោយមានការចំរើនព្រះបរិត្ត និងទេសនាសង្គាយនា ហើយព្រឹកឡើងរាប់បាត្រធ្ងន់ ។

ពិធីសម្ពោធជាផ្លូវការនេះ មានធ្វើនៅរាជធានី នៅគ្រប់ក្រុង គ្រប់ខេត្ត គ្រប់ស្រុកក្នុងព្រះរាជាណាចក្រទាំងមូល ហើយត្រូវពេលគ្នា និងមានរបៀបដូចគ្នា តាមកម្មវិធីជាផ្លូវការមួយ ៗ ចំណែកវត្តទាំងអស់ក្នុងព្រះរាជាណាចក្រ ក៏ត្រូវធ្វើពិធីសម្ពោធនេះក្នុងពេលជាមួយគ្នាដែរ ។

គួរកត់សំគាល់ថា ព្រះត្រៃបិដកប្រែនេះ ទើបនឹងមានជាដំបូងបំផុតនៅប្រទេសកម្ពុជាក្នុងចំណោមប្រទេស កាន់ព្រះពុទ្ធសាសនាទាំងឡាយ ។

ព្រះករុណា ព្រះបាទសម្តេចព្រះមុនីវង្ស បានទ្រង់បង្កើតក្រុមសង្គីតិកាចារ្យមួយក្នុងឆ្នាំ ១៩២៩ ផ្ទៀងផ្ទាត់ព្រះត្រៃបិដក និង ប្រែជាភាសាជាតិ ហើយទ្រង់ដាក់នាមកិច្ចការនេះជា ឆដ្ឋសង្គាយនា ។ ព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះបាទសម្តេចព្រះនរោត្តម សុរាម្រិត បានទ្រង់ឧបត្ថម្ភបន្តកិច្ចការនេះរហូតដល់ឆ្នាំ ១៩៦៨ ទើបចប់សព្វគ្រប់ គឺធ្វើអស់រយៈពេល ៣៩ ឆ្នាំដែលមានតម្លៃដូចគ្នានឹងប្រាសាទអង្គរវត្ត ដែលព្រះមហាក្សត្រខ្មែរបានឧទ្ទិសថ្វាយចំពោះព្រះពុទ្ធសាសនានោះដែរ ។

ដោយពិធីសម្ពោធនេះ មានតែម្តងប៉ុណ្ណោះក្នុងមួយអាយុផែនដី នៃប្រទេសកម្ពុជា ទើបក្រសួងធម្មការ សូមអំពាវនាវឲ្យពលរដ្ឋខ្មែរគ្រប់សញ្ជាតិ ជួយធ្វើវិភាគទានសម្រាប់ការចាត់ចែងពិធីនេះ ឲ្យបានរុងរឿងបំផុត ដោយយកបច្ច័យមកចូលចាប់មគ្គផល នៅការិយាល័យ ធម្មការ នៃ ក្រសួង ធម្មការ មុខព្រះបរមរាជវាំង ឲ្យបានទាន់មុនថ្ងៃទី ១ មេសា ១៩៦៩ ។

o
o o




ដាយ៉ាន់.— ដោយជំនួយយ៉ាងសំបើមពីសហរដ្ឋអាមេរិក ប្រទេសអ៊ីស្រាអែល អាចនឹងកំទេចប្រទេសអារ៉ាប់ទាំងអស់នេះបានដោយងាយ

**Dayan.—** Avec toutes ces aides des USA, l'Israel pourrait écraser facilement ces pays arabes.

សូមអស់លោកអ្នកអញ្ជើញជួយលើកតម្កើងសេដ្ឋកិច្ចជាតិ

ឲ្យស្របទៅតាមព្រះរាជនយោបាយរបស់សម្តេចឪ

ដោយយកប្រាក់ទំនេររបស់លោកអ្នកទៅផ្ញើទុកនៅ :

# ធនាគារខ្មែរសម្រាប់ពាណិជ្ជកម្ម

**BANQUE KHMERE POUR LE COMMERCE**

ដែលជាធនាគាររដ្ឋដ៏ធំ ខាងពាណិជ្ជកម្ម

សូមអញ្ជើញទៅទាក់ទងនៅ :

ទីស្នាក់ការ នៅភ្នំពេញ លេខ ២៦ ផ្លូវវិថីព្រះម្លូនស ទូរស័ព្ទលេខ : ២-២៤៣៣ ២-២៤៣៧ ២-២៤៣៩ ប្រអប់សំបុត្រលេខ : ៦២៣

សាខានៅភ្នំពេញ លេខ ៣៩-៤៣ វិថីបទូអាក ទូរស័ព្ទលេខ : ២-២០១០ ២-២០១១

សាខានៅខេត្ត :

- បាត់ដំបង លេខ ១-២ វិថីព្រះបាទនរោត្តម ទូរស័ព្ទលេខ : ២២
- ក្រុងព្រះសីហនុ លេខ ២៧ វិថីកម្មករ ទូរស័ព្ទលេខ : ២៤១៩
- តាខ្មៅ «កណ្តាល» លេខ ៤២ វិថីលេខ ១០ ទូរស័ព្ទលេខ : ៣០
- កំពង់ធំ លេខ ៥ វិថីសុធារស ទូរស័ព្ទលេខ : ៤៣
- កំពត ឡូលេខ ៧ ជិតនៅផ្លូវបំបែកកំពត-ភ្នំពេញ ទូរស័ព្ទលេខ : ២៣៣៩

ធនាគារនេះមានការប្រស្រ័យទាក់ទងជាមួយប្រទេសនានាក្នុងពិភពលោក ។

សូមអញ្ជើញពិសា

“ ស្រាបៀរ ”

របស់ជាតិ







ដែលជាភេសជ្ជៈកើតឡើងដោយស្នាព្រះហស្តនៃសម្តេចឪយើង ។

យើងជាខ្មែរត្រូវតែស្រឡាញ់របស់ខ្មែរ បើធ្វើឲ្យចំណេញ ក៏ត្រូវឲ្យចំណេញទៅក្រុមហ៊ុនជាតិខ្មែរយើងដែរ ។

ស្រាបៀរខ្មែរមានគុណភាពដូចគ្នាឬលើសពីស្រាបៀរមកពីបរទេសទៅទៀត គឺមានរសជាតិឆ្ងាញ់ ពិសាទៅធ្វើឲ្យត្រជាក់ខ្លួន ស្រួលខ្លួន ពិសាបាយបាន ពាត់ធំ សុខភាពល្អ ។

ពិសាស្រាបៀរខ្មែរ មានន័យថា ជួយជ្រោមជ្រែងក្រុមហ៊ុនជាតិខ្មែរ មានន័យថា ជង្ហែសម្តេចឪយើងក្នុងការកសាងសេដ្ឋកិច្ចជាតិ ។

## រាជាយស្ម័យយាន កម្ពុជា



ស្ថានីយកំពត

ធ្វើដំណើរគ្មានគ្រោះថ្នាក់
ប្រកបដោយ ផាសុកភាព
មាន ល្បឿនរួសរាន់ទាន់ចិត្ត
ហើយទៀងទាត់ពេលផង ។

**ទៀងទាត់ចុងសប្តាហ៍**

សូមអញ្ជើញទៅលំហែកាយនៅមាត់សមុទ្រ ទីក្រុងកែប

រាជាយស្ម័យយានកម្ពុជានៅរង់ចាំរៀបចំដំណើរ របស់លោក-អ្នក-នាងឲ្យបានស្រួល ហើយសុខសប្បាយដូចបំណង ។

**មានរយស្ម័យរថធ្វើដំណើររាល់ថ្ងៃ**




# ឥណទានជាតិ

# INADANA JATI

## ធនាគារពាណិជ្ជកម្មរបស់រដ្ឋ

មានឧបសម្ពន្ធ ៣ នៅភ្នំពេញ

មានសាខា ៩ នៅតាមខេត្តនានា

មានការទាក់ទងជាមួយធនាគារធំៗ សាកលលោក សម្រាប់បំរើគស់លោក-អ្នក ខាងកិច្ចការធនាគារ ក្នុងព្រះរាជាណាចក្រផង នៅឯបរទេសផង ។



លេខ 2020



**សមិទ្ធិថ្មី នៃសង្គម**

**ព្រះវិហារ វត្តជម្ពូព្រឹក្ស**
**ស្រុកព្រែកតាមាក់ ខេត្តកណ្ដាល**